**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

**Université Royale de Droit et des Sciences Économiques**

**ROYAL UNIVERSITY OF LAW AND ECONOMICS**

# សារណាបញ្ចប់ការសិក្សា

# នីតិវិធីនៃការចាត់ចែងជាបណ្ដោះអាសន្ន ចំពោះអចលនវត្ថុ

ស្រាវជ្រាវចាប់ពីថ្ងៃទី០៨ ខែមេសា ដល់ថ្ងៃទី១០ ខែសីហា ឆ្នាំ២០២៤

ស្រាវជ្រាវដោយ

និស្សិតឈ្មោះ **លោក នាង ទិដ្ឋិភា**

**កញ្ញា សុខ រចនា**

ណែនាំដោយ

លោកគ្រូ **ហេង មូរ៉ា**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី ២៤

ឆ្នាំចូលសិក្សា ២០២០

ឆ្នាំសរសេរសារណា ២០២៤

**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

**Université Royale de Droit et des Sciences Économiques**

**ROYAL UNIVERSITY OF LAW AND ECONOMICS**


# សារណាបញ្ចប់ការសិក្សា

# នីតិវិធីនៃការចាត់ចែងជាបណ្ដោះអាសន្ន ចំពោះអចលនវត្ថុ

ស្រាវជ្រាវចាប់ពីថ្ងៃទី០៨ ខែមេសា ដល់ថ្ងៃទី១០ ខែសីហា ឆ្នាំ២០២៤


ស្រាវជ្រាវដោយ

និស្សិតឈ្មោះ **លោក នាង វិឆ្ឆិកា**

**កញ្ញា សុខ រចនា**

ណែនាំដោយ

លោកគ្រូ **ហេង មូរ៉ា**


ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ឆ្នាំចូលសិក្សា ២០២០

ជំនាន់ទី ២៤

ឆ្នាំសរសេរសារណា ២០២៤

# សេចក្តីថ្លែងអំណរគុណ

នាងខ្ញុំ **សុខ រចនា** និងខ្ញុំបាទ **នាង វិច្ឆិកា** ជានិស្សិតថ្នាក់បរិញ្ញាបត្រជំនាញនីតិសាស្ត្រ ជំនាន់ទី២៤ ក្រុម L4C1 នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។ យើងខ្ញុំសូមគោរពសម្តែងនូវការដឹងគុណ និងថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ៖

លោកឪពុក អ្នកម្តាយ ដែលលោកទាំងពីរបានផ្តល់កំណើតឱ្យកូនៗ និងបានពលិកម្មគ្រប់សព្វបែបយ៉ាងដើម្បីចិញ្ចឹមបីបាច់ថែរក្សា ផ្តល់ភាពកក់ក្តៅ ផ្តល់ក្តីស្រលាញ់ យោគយល់អធ្យាស្រ័យ អនុគ្រោះព្រមទាំងមាននូវព្រហ្មវិហាធម៌ អប់រំប្រៀនប្រដៅទូន្មានកូនឱ្យប្រព្រឹត្តទៅតាមគន្លងធម៌ ដើម្បីក្លាយខ្លួនទៅជាធនធានដែលប្រទេសជាតិ និងសង្គមជាតិត្រូវការ ហើយជាពិសេសបានផ្តល់ឱកាសឱ្យកូនៗបានសិក្សារៀនសូត្រតាំងពីបឋមសិក្សារហូតមកដល់ឧត្តមសិក្សា ព្រមទាំងជួយទំនុកបម្រុងជាថវិកា ធនធាន និងសម្ភារៈសិក្សាជាច្រើនរកគណនាពុំបាន។

**ឯកឧត្តមបណ្ឌិត សាកលវិទ្យាធិការ** សាកលវិទ្យាធិការរង សាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូ ព្រមទាំងបុគ្គលិកទាំងអស់នៃ សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានចំណាយនូវពេលវេលាដ៏មានតម្លៃ ដើម្បីផ្តល់នូវចំណេះដឹងសម្រាប់ជាមូលដ្ឋាននៃការចងក្រងអត្ថបទនេះឡើង។

**លោកមេធាវី ហេង ម៉ូរ៉ា** ដែលបាន ចំណាយពេលវេលាដ៏មានតម្លៃ ខិតខំអស់ពី កម្លាំងកាយចិត្ត ក្នុងការបង្ហាត់បង្រៀន ពន្យល់ អប់រំ ណែនាំ ចែករំលែកនូវបទពិសោធន៍ និង ចំណេះដឹង សំខាន់ៗជាច្រើនសម្រាប់ឱ្យយើងខ្ញុំទាំងពីរយកជាដើមទុនដើម្បីអាចសិក្សាស្រាវជ្រាវចងក្រងនូវស្នាដៃនេះឡើង។

បងប្អូន សិស្សច្បង មិត្តរួមថ្នាក់ និងមិត្តភក្តិទាំងអស់ ដែលបានចំណាយនូវពេលវេលាដ៏មានតម្លៃចូលរួមជាមតិណែនាំល្អៗ ផ្តល់នូវកម្លាំងកាយ កម្លាំងចិត្ត ដល់រូបយើងខ្ញុំនាពេលកន្លងមក។

ជាចុងក្រោយយើងខ្ញុំទាំងអស់គ្នា សូមប្រសិទ្ធិពរជ័យ សិរីមង្គល វិបុលសុខមហាប្រសើរ ជូនចំពោះអ្នកមានគុណ ឯកឧត្តមសាកលវិទ្យាធិការ សាកលវិទ្យាធិការរង សាស្ត្រាចារ្យ បុគ្គលិក លោក លោកស្រី អ្នកនាង កញ្ញា ទាំងអស់ឱ្យទទួលបាននូវពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លាងឃ្លៀតឡើយ។

# **អារម្ភកថា**

ជាកិច្ចចាប់ផ្ដើមយើងខ្ញុំសូមស្វាគមន៍លោកគ្រូ អ្នកគ្រូ និស្សិត ប្រិយមិត្តមិត្តអ្នកអាន ព្រមទាំងអ្នកសិក្សាស្រាវជ្រាវទាំងអស់ជាទីរាប់អានក្នុងការអាន និងសិក្សាអំពីអត្ថបទសារណាក្រោមប្រធានបទ "**នីតិវិធីនៃការចាត់ចែងជាបណ្ដោះអាសន្នចំពោះអចលនវត្ថុ**" ដែលជាវណ្ណកម្មរបស់យើងខ្ញុំដែលជានិស្សិតថ្នាក់បរិញ្ញាបត្រជំនាញ នីតិសាស្ត្រ ជំនាន់ទី២៤ ក្រុម L4C1 នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។ យើងខ្ញុំពិតជាមានកិត្តិយស និងមានសេចក្ដីសោមនស្សរីករាយណាស់ ក្នុងការទទួលបានឱកាសក្នុងការចូលរួមចែករំលែកនូវសមិទ្ធផលដែលទទួលបានពីការខិតខំសិក្សាស្រាវជ្រាវក្រោមការណែនាំរបស់លោកគ្រូ **មេធាវី ហេខ មូរ៉ា** ដើម្បីបន្សល់ទុកជាស្នាដៃសម្រាប់ឱ្យអ្នកទាំងឡាយទុកជាមូលដ្ឋានសម្រាប់ធ្វើជាការស្រាវជ្រាវឈ្វេងយល់បន្ថែមឱ្យបានកាន់តែស៊ីជម្រៅ។

ដើម្បីយល់ឲ្យកាន់តែច្បាស់ពាក់ព័ន្ធទៅនឹងការអនុវត្តនីតិវិធីរដ្ឋប្បវេណីអំពីការចាត់ចែងរក្សាការពារនៅក្នុងប្រទេសកម្ពុជា ថាតើអ្វីជាការចាត់ចែងរក្សាការពារ ហើយសិទ្ធិទាំងនឹងអនុវត្តដូចម្ដេច? ត្រូវបានគេបែងចែកជាប៉ុន្មានប្រភេទ មានបុគ្គលណាខ្លះដែលត្រូវបានគេកំណត់ថាជាកូនបំណុល និងម្ចាស់បំណុល ហើយការអនុវត្តសិទ្ធិរបស់ម្ចាស់បំណុលត្រូវបានគេអនុវត្តបែបណា ហើយគេយកច្បាប់មួយណាមកអនុវត្តចំពោះសិទ្ធិចាត់ចែងរក្សាការពារនេះ ដើម្បីក្លាយទៅជាប្រយោជន៍ដល់បុគ្គលដែលជាម្ចាស់បំណុល។ ដូច្នេះនៅក្នុងអត្ថបទស្រាវជ្រាវនេះនឹងធ្វើការបង្ហាញពាក់ព័ន្ធទៅនឹងចម្លល់ដែលបានចោទសួរខាងលើ។

អត្ថបទនេះគ្រាន់ជាការបកស្រាយនូវបញ្ហា និងដំណោះស្រាយមួយចំនួន ស្របទៅតាមមូលដ្ឋាននៃចំណេះដឹងដែលទទួលបានពីការសិក្សាមេរៀនកន្លងមក និងស្រាវជ្រាវនៅតាមបណ្ណាល័យ ក៏ដូចជាតាមប្រភពសៀវភៅ តាមបណ្ដាញសង្គមអ៊ីនធឺណេត និងឯកសារពាក់ព័ន្ធមួយចំនួនប៉ុណ្ណោះ។ យើងខ្ញុំសុំការអធ្យាស្រ័យនិងយោគយល់ទុកជាមុនពីសំណាក់លោកគ្រូ អ្នកគ្រូ និងអ្នកអានគ្រប់ៗរូបចំពោះកំហុសឆ្គងគ្រប់ប្រការណាមួយដែលអាចមានកើតឡើងដោយអចេតនា។ ស្របនឹងគ្នានេះដែរ យើងខ្ញុំស្ម័គ្រចិត្តទទួលនូវការណែនាំ និងការរិះគន់ក្នុងអត្ថន័យស្ថាបនាទាំងឡាយ ដើម្បីទុកជាទុនសម្រាប់កែលម្អ អភិវឌ្ឍន៍ខ្លួន និងស្នាដៃទាំងឡាយដែលយើងខ្ញុំនឹងធ្វើការចងក្រងនាពេលអនាគតឱ្យកាន់តែប្រសើរជាងមុន។

ជាទីបញ្ចប់ យើងខ្ញុំសូមជូនពរដល់លោកគ្រូសាស្ត្រាចារ្យ មិត្តអ្នកអាន អ្នកស្រាវជ្រាវ និងមិត្តនិស្សិតទាំងអស់ ទទួលបាននូវពរទាំងឡាយបួនប្រការ ទទួលបានសំណាងល្អគ្រប់ពេលវេលា ជោគជ័យលើការសិក្សា និងជោគជ័យនូវគោលបំណងដែលប៉ងគ្រប់ៗគ្នាកុំបីខានឡើយ។

# មាតិកា

**ទំព័រ**

**សេចក្តីផ្តើម** ........................................................ ១

**ជំពូកទី១**

**សញ្ញាណទូទៅនៃការចាត់ចែងជាបណ្តោះអាសន្នចំពោះអចលនវត្ថុ**

**ផ្នែកទី១៖ ទិដ្ឋភាពទូទៅនៃការចាត់ចែងជាបណ្តោះអាសន្នចំពោះអចលនវត្ថុ** ............ ៣

១.១. អត្ថន័យនៃការចាត់ចែងជាបណ្តោះអាសន្នចំពោះអចលនវត្ថុ ............ ៣

១.២. ភាពចាំបាច់នៃការចាត់ចែងជាបណ្តោះអាសន្នចំពោះអចលនវត្ថុ ............ ៣

**ផ្នែកទី២៖ ប្រភេទនៃការចាត់ចែងជាបណ្តោះអាសន្ន** ............ ៥

២.១. ការចាត់ចែងជាបណ្តោះអាសន្នចំពោះវត្ថុដែលជាកម្មវត្ថុនៃវិវាទ ............ ៦

២.២. ការចាត់ចែងជាបណ្តោះអាសន្នដែលកំណត់ឋានៈជាបណ្តោះអាសន្ន ............ ៧

**ជំពូកទី២**

**លំហូរនីតិវិធីនៃការចាត់ចែងជាបណ្តោះអាសន្នចំពោះអចលនវត្ថុ**

**ផ្នែកទី១៖ ដំណើរការនីតិវិធីនៃការចាត់ចែងជាបណ្តោះអាសន្នចំពោះអចលនវត្ថុ** ....... ៩

១.១. ការដាក់ពាក្យសុំ ............ ៩

១.១.១. ចំណុចដែលត្រូវសរសេរនៅក្នុងពាក្យសុំ ............ ១០

១.១.១.១. ឈ្មោះ ឬនាមករណ៍ និងអាសយដ្ឋានរបស់ភាគី និង របស់អ្នកតំណាងដែលច្បាប់បានកំណត់ ............ ១០

១.១.១.២. ខ្លឹមសារនៃដីកាសម្រេចការពារ ............ ១០

១.១.១.៣. សិទ្ធិ ឬទំនាក់ទំនងគតិយុត្ត ដែលត្រូវបានរក្សាការពារ ............ ១១

១.១.១.៤. ភាពចាំបាច់នៃការចាត់ចែងរក្សាការពារ ............ ១២

១.១.២. សោហ៊ុយនៃការចាត់ចែងរក្សាការពារ ............ ១២

១.២. យុត្តាធិការដែលមានសមត្ថកិច្ច ............ ១២

១.៣. ការត្រួតពិនិត្យពាក្យសុំ ............ ១៣

**ផ្នែកទី២៖ ការដាក់ប្រាតិភោគ** ........................................................ ១៤
២.១ មូលហេតុដែលនាំឱ្យដាក់ប្រាតិភោគ ........................................................ ១៤
២.១.១. ប្រាតិភោគសម្រាប់ដីកាសម្រេចរក្សាការពារ ........................................................ ១៤
២.១.២. ប្រាតិភោគសម្រាប់ផ្អាកការអនុវត្តរក្សាការពារ ........................................................ ១៤
២.១.៣. ប្រាតិភោគសម្រាប់លុបចោលដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្នដោយសារស្ថានភាពពិសេស ........................................................ ១៥
២.២. ដំណើរការនៃការដាក់ប្រាតិភោគ ........................................................ ១៥
២.២.១. វិធីដាក់ប្រាតិភោគ ........................................................ ១៦
២.២.២. ទីកន្លែងដាក់ប្រាតិភោគ ........................................................ ១៦
២.២.៣. ពេលវេលាដាក់ប្រាតិភោគ ........................................................ ១៦
២.២.៤. ចំនួនទឹកប្រាក់នៃប្រាតិភោគ ........................................................ ១៦
២.២.៥. ករណីដែលដាក់ ប៉ុន្តែតុលាការអាចបង្គាប់ឱ្យប្តូរប្រាតិភោគ ........................................................ ១៧
២.៣. សិទ្ធិអាទិភាពចំពោះប្រាតិភោគ ........................................................ ១៧
២.៤. ហេតុដែលនាំអោយរំលត់ប្រាតិភោគ ........................................................ ១៨
២.៤.១. ហេតុដែលបានកំណត់ឱ្យមានការដាក់ប្រាតិភោគបានរលត់ ........................................................ ១៨
២.៤.២. អ្នកមានសិទ្ធិប្រាតិភោគយល់ព្រមឱ្យលុបចោល ........................................................ ១៩
២.៤.៣. ការចាត់ទុកថាអ្នកមានសិទ្ធិលើប្រាតិភោគយល់ព្រមលុបចោល ........................................................ ១៩
**ផ្នែកទី៣៖ ដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្ន** ........................................................ ២១
៣.១. ទម្រង់នៃដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្ន ........................................................ ២១
៣.២. ខ្លឹមសារនៃនៃដីកាសម្រេចដែលអ្នកដាក់ពាក្យសុំធ្វើការទាមទារ ........................................................ ២២
**ផ្នែកទី៤៖ ការធ្វើឧបាស្រ័យចំពោះដីកាសម្រេចរក្សាការពារ** ........................................................ ២៩
៤.១. ពាក្យសុំតវ៉ាចំពោះដីកាសម្រេចរក្សាការពារ ........................................................ ២៩
៤.១.១. ពាក្យសុំតវ៉ាចំពោះការរក្សាការពារ ........................................................ ២៩
៤.១.១.១. អ្នកដែលមានសិទ្ធិដាក់ពាក្យសុំ ........................................................ ២៩

៤.១.១.២. សមត្ថកិច្ច ........ ២៩
៤.១.១.៣. ការវិនិច្ឆ័យ ........ ៣០
៤.១.១.៤. ដីកាសម្រេច ........ ៣០
៤.១.២. ការលុបចោលនូវរក្សាការពារ ........ ៣១
៤.១.២.១. ការលុបចោលរក្សាការពារដោយសារមិនដាក់ពាក្យបណ្តឹងអង្គសេចក្តី ........ ៣១
៤.១.២.២. ការលុបចោលការរក្សាការពារដោយសារការផ្លាស់ប្តូរស្ថានភាព ........ ៣១
៤.១.២.៣. ការលុបចោលការរក្សាការពារដោយសារស្ថានភាពពិសេស ........ ៣២
៤.១.៣. បណ្តឹងជំទាស់ ........ ៣៣
**ផ្នែកទី៥៖ ការអនុវត្តចាត់ចែងជាបណ្តោះអាសន្នចំពោះអចលនវត្ថុ** ........ ៣៤
៥.១. លក្ខខណ្ឌអនុវត្ត ........ ៣៤
៥.២. វិធី និង សមត្ថកិច្ចអនុវត្ត ........ ៣៤
៥.៣. អានុភាពនៃការអនុវត្តចាត់ចែងជាបណ្តោះអាសន្នចំពោះវត្ថុដែលជាកម្មវត្ថុនៃវិវាទ ........ ៣៦
៥.៤. ពាក្យសុំឱ្យអនុវត្តរក្សាការពារ ........ ៣៦
៥.៥. លំហូរនីតិវិធីនៃការចុះបញ្ជីដែលទាក់ទងនឹងការអនុវត្តចាត់ចែងជាបណ្តោះអាសន្ន ........ ៣៨
៥.៦. ការបញ្ជូន ........ ៤០

## ជំពូកទី៣
## បញ្ហាប្រឈម និងដំណោះស្រាយ

**ផ្នែកទី១៖ បញ្ហាប្រឈម** ........ ៤២
១.១ ភាពខ្វះចន្លោះនៃច្បាប់ ........ ៤២
១.២. ភាពយឺតយ៉ាវនៃដំណើរការនីតិវិធីសំណុំរឿងចាត់ចែងជាបណ្តោះអាសន្នចំពោះអចលនវត្ថុ ........ ៤៣
១.៣. បន្ទុកសោហ៊ុយចំណាយលើសលុបរបស់ម្ចាស់បំណុល ........ ៤៤
១.៤. ការបញ្ជូនដីការក្សាការពារខុសភូមិសាស្រ្តដែនដី ........ ៤៥
**ផ្នែកទី២៖ ដំណោះស្រាយ** ........ ៤៨
២.១. ការបង្កើត និងផ្សព្វផ្សាយច្បាប់ ........ ៤៨

២.២. ការពន្លឿននីតិវិធីនៃការអនុវត្តចាត់ចែងជាបណ្ដោះអាសន្នចំពោះអចលនវត្ថុ ............................. ៥០
២.៣. យន្តការក្នុងការកាត់បន្ថយសោហ៊ុយចំណាយ ............................................................. ៥៥
២.៤. ការពង្រឹងនូវការអនុវត្តដីកាបញ្ជូនឱ្យត្រឹមត្រូវតាមភូមិសាស្ត្រដែនដី ........................................ ៥៥
**សេចក្ដីសន្និដ្ឋាន** ................................................................................................ ៥៧
**អនុសាសន៍** ...................................................................................................... ៥៨
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

# សេចក្ដីផ្ដើម

## ១. លំនាំបញ្ហានៃការស្រាវជ្រាវ

នៅក្នុងសង្គមមួយរមែងតែងតែមានទំនាក់ទំនងរវាងបុគ្គលដែលរស់នៅក្នុងសង្គម នោះទំនាក់ទំនងទាំងនោះហើយដែលបានបង្កើតឱ្យមានស្ថានភាពគតិយុត្តជាច្រើន។ ដោយសារមានស្ថានភាពអសកម្មមួយចំនួនរបស់បុគ្គលដែលជាភាគី ទំនាក់ទំនងគតិយុត្តទាំងនោះ ដែលបង្កើតឱ្យមានបុគ្គលដែលមានសិទ្ធិ និងបុគ្គលដែលត្រូវបំពេញកាតព្វកិច្ចហើយនៅពេលដែលបុគ្គលដែលត្រូវបំពេញកាតព្វកិច្ចមិនព្រមបំពេញកាតព្វកិច្ចរបស់ខ្លួនដោយប្រការណាមួយនោះរវាងសិទ្ធិ និងកាតព្វកិច្ច និងកើតមានឡើងដើម្បីដោះស្រាយអំពីរបៀបដែលកើតចេញពីសិទ្ធិ និងកាតព្វកិច្ចដែលមានចែងក្នុងក្រមរដ្ឋប្បវេណីនេះ បុគ្គលដែលមានសិទ្ធិត្រូវតែដាក់ពាក្យបណ្ដឹងទៅកាន់តុលាការរដ្ឋប្បវេណីដើម្បីអនុវត្តសិទ្ធិរបស់ខ្លួន ក៏ដូចជាទាមទារភាគីម្ខាងទៀតឱ្យបំពេញកាតព្វកិច្ចចំពោះខ្លួនផងដែរ។ នៅក្នុងរឿងក្ដីរដ្ឋប្បវេណីអ្នកដែលមានសិទ្ធិហៅថាម្ចាស់បំណុល ចំណែកអ្នកដែលមានកាតព្វកិច្ចហៅថាកូនបំណុល។ ទំហំនៃការសម្រេចជាស្ថាពរនូវសិទ្ធិរបស់ម្ចាស់បំណុលត្រូវប្រើពេលវេលាវែង ជាហេតុនាំឱ្យសិទ្ធិដែលត្រូវអនុវត្តនាពេលអនាគតអាចនឹងត្រូវពិបាកក្នុងការអនុវត្ត ឬពេលខ្លះអាចនឹងអនុវត្តមិនបានថែមទៀតផង ព្រោះតែមានការ ប្រែប្រួលនៅពេលស្ថានភាពទ្រព្យសម្បត្តិរបស់កូនបំណុលក្នុងអំឡុងពេលនៃនីតិវិធីបណ្ដឹង ហេតុនេះដើម្បីសម្របសម្រួលស្ថានភាពបែបនេះក៏ដូចជាការពារនូវក្ដីរំពឹងរបស់អ្នកឈ្នះក្ដីថាក្រោយពីបានឈ្នះក្ដីហើយពួកគេអាចអនុវត្តសិទ្ធិរបស់ពួកគេបានដោយរលូននោះទើបក្រមនីតិវិធីរដ្ឋប្បវេណីបង្កើតឱ្យមានយន្តការក្នុងការរក្សាការពារនូវទ្រព្យសម្បត្តិរបស់កូនដើម្បីបង្កាទប់ស្កាត់ជាមុនកុំឱ្យមានការប្រែប្រួល ឬបាត់បង់ទាំងស្រុងនៅពេលទ្រព្យសម្បត្តិរបស់កូនបំណុលដែលជាហេតុធ្វើឱ្យម្ចាស់បំណុលមិនអាចអនុវត្តសិទ្ធិលើបំណុលរបស់ខ្លួនបាន។ បញ្ហាប្រឈមមួយទៀតដែលតម្រូវឱ្យមានប្រព័ន្ធនៃការរក្សាការពារនេះគឺបញ្ហាឋានៈរបស់បុគ្គល។ មានស្ថានភាពមួយចំនួនបុគ្គលដែលរងគ្រោះឬបុគ្គលមួយចំនួនដែលត្រូវការប្រព័ន្ធរក្សាការពារនេះជាចាំបាច់ដើម្បីកំណត់ឋានៈរបស់ពួកគេ ជាមុនដើម្បីការពារស្ថានភាពបន្ទាន់ដើម្បីទទួលបានការសង្គ្រោះឱ្យសមស្របនឹងពេលវេលា ព្រោះថាស្ថានភាពមួយចំនួនមិនអាចឱ្យពួកគេរង់ចាំរហូតមានសាលក្រម ឬ សាលដីកាស្ថាពរជាមុនសិនទៅទទួលបានសិទ្ធិនោះទេ។

## ២.ចំណោទបញ្ហានៃការស្រាវជ្រាវ

ខ្លឹមសារនៃអត្ថបទនេះបកស្រាយទៅលើចំណុចសំខាន់ៗជាមូលដ្ឋានមួយចំនួនរួមមាន៖

- តើនីតិវិធីនៃការចាត់ចែងជាបណ្ដោះអាសន្នចំពោះអចលនវត្ថុជាអ្វី? មានគោលបំណងអ្វី? អនុវត្តនៅពេលណា?
- តើលំហូរនីតិវិធីនៃការចាត់ចែងជាបណ្ដោះអាសន្នចំពោះអចលនវត្ថុប្រព្រឹត្តទៅបែបណា? មានការចូលរួមពីភាគី និងស្ថាប័នមានសមត្ថកិច្ចណាខ្លះ?

- តើបញ្ហាប្រឈមក្នុងការអនុវត្តនីតិវិធីនៃការចាត់ចែងជាបណ្ដោះអាសន្នចំពោះអចលនវត្ថុមានអ្វីខ្លះ? រីឯយន្តការសម្រាប់ដោះស្រាយបញ្ហាប្រឈមទាំងនោះមានអ្វីខ្លះ?

## ៣. គោលបំណងនៃការស្រាវជ្រាវ

ការស្រាវជ្រាវប្រធានបទពាក់ព័ន្ធនឹងប្រធានបទខាងលើ ត្រូវបានធ្វើឡើងក្នុងគោលបំណងដើម្បីសិក្សាស្វែងយល់បន្ថែមពាក់ព័ន្ធនឹងបទដ្ឋានគតិយុត្តិ បែបបទនៃការអនុវត្ត បញ្ហាប្រឈម និងភាពមិនប្រក្រតីពាក់ព័ន្ធនឹងការអនុវត្តនីតិវិធីនៃការចាត់ចែងជាបណ្ដោះអាសន្នចំពោះអចលនវត្ថុនៅតាមសាលាជម្រះក្តី ពិសេសតាមសាលាដំបូងរាជធានី-ខេត្ត។

## ៤. សារៈសំខាន់នៃការសិក្សាស្រាវជ្រាវ

អត្ថបទសារណានេះ នឹងរួមចំណែកជាឯកសារសម្រាប់ជំនួយស្មារតីដល់អ្នកអានគ្រប់រូប ព្រមទាំងដើម្បីតម្កល់ទុកជាឯកសារដល់សិស្សនិស្សិតជំនាន់ក្រោយៗ អាចយល់ដឹងកាន់តែច្បាស់អំពីនីតិវិធីនៃការចាត់ចែងជាបណ្ដោះអាសន្នចំពោះអចលនវត្ថុ។

## ៥. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ

ប្រធានបទស្រាវជ្រាវនេះ មានវិសាលភាពគ្របដណ្ដប់ទ្រឹស្តីភ្ជាប់នឹងការអនុវត្តជាក់ស្ដែងនៃដំណើរការនីតិវិធីនៃចាត់ចែងជាបណ្ដោះអាសន្នចំពោះអចលនវត្ថុដែលបានអនុវត្តក្នុងអំឡុងឆ្នាំ ២០១១ រហូតដល់ឆ្នាំ ២០២៤។

## ៦. វិធីសាស្ត្រនៃការសិក្សាស្រាវជ្រាវ

អត្ថបទនេះត្រូវបានចងក្រងឡើងដោយប្រើប្រាស់វិធីសាស្ត្របែបពណ៌នានិងវិភាគ។ ចំពោះការប្រមូលទិន្នន័យ និងឯកសារនានាដែលទាក់ទងនឹងការសិក្សាស្រាវជ្រាវនៃប្រធានបទនេះ យើងខ្ញុំបានស្វះស្វែងរកព័ត៌មាន និងដកស្រង់ចេញពីប្រភពច្បាប់ និងលិខិតបទដ្ឋានគតិយុត្តរបស់ព្រះរាជាណាចក្រកម្ពុជា ប្រភពសៀវភៅគេហទំព័រផ្លូវការ ក៏ដូចជាឯកសារដែលពាក់ព័ន្ធមួយចំនួនទៀតផងដែរ។

## ៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ដើម្បីបកស្រាយខ្លឹមសារមូលដ្ឋានខាងលើឱ្យបានក្បោះក្បាយ អត្ថបទសារណានេះនឹងត្រូវបានបែងចែកជា៣ជំពូករួមមាន៖

- **ជំពូកទី១៖** សញ្ញាណទូទៅនៃការចាត់ចែងជាបណ្ដោះអាសន្នចំពោះអចលនវត្ថុ។
- **ជំពូកទី២៖** លំហូរនីតិវិធីនៃការចាត់ចែងជាបណ្ដោះអាសន្នចំពោះអចលនត្ថុ។
- **ជំពូកទី៣៖** បញ្ហាប្រឈម និងដំណោះស្រាយ។

# ជំពូកទី១
# សញ្ញាណទូទៅនៃ
# ការចាត់ចែងជាបណ្ដោះអាសន្ន
# ចំពោះអចលនវត្ថុ

# ជំពូកទី១

# សញ្ញាណទូទៅនៃការចាត់ចែងជាបណ្តោះអាសន្នចំពោះអចលនវត្ថុ

## ផ្នែកទី១៖ ទិដ្ឋភាពទូទៅនៃការចាត់ចែងជាបណ្តោះអាសន្នចំពោះអចលនវត្ថុ

### ១.១. អត្ថន័យនៃការចាត់ចែងជាបណ្តោះអាសន្នចំពោះអចលនវត្ថុ

នីតិវិធីនៃការរក្សាការពារ គឺជានីតិវិធីមួយដែលមានគោលបំណងការពារ និងថែរក្សាស្ថានភាពបច្ចុប្បន្ន ដោយប្រើអំណាចរបស់រដ្ឋ ដើម្បីការពារនូវសិទ្ធិរបស់បុគ្គលណាម្នាក់ ប្រសិនបើមានការបារម្ភថាការអនុវត្តដោយបង្ខំនឹងមិនអាចធ្វើទៅបាន ឬនឹងមានការលំបាកយ៉ាងខ្លាំងក្នុងការអនុវត្តដោយបង្ខំ ដោយសារមានការប្រែប្រួលស្ថានភាពបច្ចុប្បន្ន នៃទ្រព្យសម្បត្តិរបស់កូនបំណុលនៃការអនុវត្ត ឬប្រសិនបើមានការបារម្ភថា នឹងមានការខូចខាតធ្ងន់ធ្ងរ ឬគ្រោះថ្នាក់បន្ទាន់ដល់ឋានៈរបស់ភាគីណាមួយ ដោយសារមានវិវាទអំពីទំនាក់ទំនងនៃសិទ្ធិបុគ្គលដែលមានបំណងចង់ការពារសិទ្ធិរបស់ខ្លួន អាចទាមទារការចាត់ចែងរក្សាការពារតាមបញ្ញត្តិនៃគន្ថីនេះលើកលែងតែក្នុងករណីដែលមានបញ្ញត្តិពិសេសក្នុងច្បាប់ផ្សេង។

នីតិវិធីនៃការចាត់ចែងរក្សាការពារគឺ ជានីតិវិធីដែលមានចរិតលក្ខណៈជាការបំពេញបន្ថែមទៅលើនីតិវិធីអនុវត្តដោយបង្ខំព្រោះថាការរក្សាការពារក៏ជានីតិវិធីអនុវត្តដោយបង្ខំមួយដែរ។ ប៉ុន្តែវាមានលក្ខណៈប្លែកពីការអនុវត្តដោយបង្ខំដោយសារនីតិវិធីនេះមានចែងជាដំណាក់កាលពីរដំណាក់កាលគឺ ៖ នីតិវិធីសម្រេចសេចក្តីដែលជាការវិនិច្ឆ័យទៅលើភាពត្រឹមត្រូវ ឬមិនត្រឹមត្រូវនៃពាក្យសុំ និងនីតិវិធីបន្ទាប់គឺការអនុវត្តដោយបង្ខំនូវខ្លឹមសារនៃដីកាសម្រេចរក្សាការពារដែលបានចេញដោយយកដីកាសម្រេចនេះធ្វើជាលិខិតអនុវត្ត។ នីតិវិធីនៃការអនុវត្ត ជាការសម្រេចដោយបង្ខំនូវខ្លឹមសារនៃដីកាសម្រេចរក្សាការពារដែលបានចេញ ដោយយកដីកាសម្រេចនេះមកធ្វើជាលិខិតអនុវត្ត។ នៅក្នុងនោះ ដំណាក់កាលទី១ ហៅថាការសម្រេចរក្សាការពារ ឯដំណាក់កាលទី២ ហៅថាការអនុវត្តរក្សាការពារ។ ការបែងចែកនេះមានលក្ខណៈដូចគ្នានឹងការបែងចែករវាងនីតិវិធីបណ្តឹង និងនីតិវិធីនៃការអនុវត្តដោយបង្ខំដែរ។ ហើយការចាត់ចែងរក្សាការពារមានប្រភពមកពីក្រមនីតិវិធីរដ្ឋប្បវេណីចាប់ពី មាត្រា ៥៣០ ដល់ មាត្រា ៥៨៦ ច្បាប់ស្តីពីរឿងក្តីបណ្តឹងទាក់ទងនឹងឋានៈបុគ្គល ឆ្នាំ២០១០ ច្បាប់ស្តីពីការបង្ក្រាបអំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះឆ្នាំ២០០៥ ពីមាត្រា ១៦ ដល់ ២០។

### ១.២.ភាពចាំបាច់នៃការចាត់ចែងជាបណ្តោះអាសន្នចំពោះអចលនវត្ថុ

ការចាត់ចែងរក្សាការពារ គឺជានីតិវិធីដែលមានគោលបំណងការពារ និងថែរក្សាស្ថានភាពបច្ចុប្បន្ន ការអនុវត្តដោយបង្ខំនឹងមិនអាចធ្វើទៅបាន ឬនឹងមានការលំបាកយ៉ាងខ្លាំងក្នុងការអនុវត្តដោយបង្ខំ ដោយសារមាន

ការប្រែប្រួលស្ថានភាព បច្ចុប្បន្ននៃទ្រព្យសម្បត្តិរបស់កូនបំណុលនៃការអនុវត្ត ឬនៅពេលដែលមានការបារម្ភថា នឹងមានការខូចខាតធ្ងន់ធ្ងរណាមួយដោយសារមានវិវាទអំពីទំនាក់ទំនងនៃសិទ្ធិ។

## ផ្នែកទី២៖ ប្រភេទនៃការចាត់ចែងជាបណ្ដោះអាសន្ន

ការចាត់ចែងរក្សាការពារត្រូវបានគេបែងចែកជា ៣ ប្រភេទ រួមមាន ការរឹបអូសជាបណ្ដោះអាសន្ន ការចាត់ចែងជាបណ្ដោះអាសន្នចំពោះវត្ថុដែលជាកម្មវត្ថុនៃវិវាទ និងការចាត់ចែងជាបណ្ដោអាសន្នដែលកំណត់ឋានៈជាបណ្ដោះអាសន្ន។

ចរិតលក្ខណៈពិសេសនៃការចាត់ចែងរក្សាការពារមាន ៤ រួមមាន លក្ខណៈបណ្ដោះអាសន្ន លក្ខណៈបន្ទាន់បង្ខំ លក្ខណៈបន្ទាប់បន្សំ និងលក្ខណៈសម្ងាត់។

- **លក្ខណៈបណ្ដោះអាសន្ន និងបន្ទាប់បន្សំ** មានន័យថាដំណើរការនៃនីតិវិធីរក្សាការពារ និងអាចសម្រេចអំពីសិទ្ធិរបស់ភាគីគឺជាស្ថាពរបានទេ វាគ្រាន់តែជាវិធានបណ្ដោះអាសន្នប៉ុណ្ណោះ ដើម្បីសម្រេចនៅសិទ្ធិបានភាគីត្រូវដាក់បណ្ដឹងអង្គសេចក្ដី។
- **លក្ខណៈបន្ទាន់បង្ខំ** គឺរក្សាការពារនឹងមិនមានន័យ បើកូនបំណុលចាត់ចែងទ្រព្យសម្បត្តិគេអស់ ឬស្ថានភាពណាមួយរបស់ម្ចាស់បំណុលមិនត្រូវបានការពារ។
- **លក្ខណៈសម្ងាត់** ជាការមានករណីខ្លះបើកូនបំណុលដឹងមុននោះ ការអនុវត្តរក្សាការពារ និងមិនអាចធ្វើបានដោយកូនបំណុលនឹងធ្វើការលាក់បាំង ឬចាត់ចែងទ្រព្យរបស់ពួកគេ។

ជារួមមកនីតិវិធីរក្សាការពារ មានលក្ខណៈបណ្ដោះអាសន្ន បន្ទាប់បន្សំ បន្ទាន់ និងសំងាត់ ដែលមានគោលបំណងធានាប្រសិទ្ធិភាពនៃការអនុវត្តដោយបង្ខំ និងបង្កាកុំឱ្យមានការប៉ះពាល់ដល់នីតិវិធីអនុវត្តដោយបង្ខំដោយសារមានការប្រែប្រួលស្ថានភាពនៃទ្រព្យ ឬការខូចខាតធ្ងន់ធ្ងរ ឬគ្រោះថ្នាក់បន្ទាន់ដល់ឋានៈភាគីណាមួយដែលធ្វើឱ្យខូចប្រយោជន៍ដល់ម្ចាស់បំណុលក្នុងការអនុវត្តសិទ្ធិរបស់ខ្លួន។

ចំណែកកម្មវត្ថុនៃការការចាត់ចែងរក្សាការពារ ត្រូវបានបែងចែកជា បីប្រភេទរួមមាន វត្ថុ សិទ្ធិលើបំណុល និងឋានៈបុគ្គល។

- វត្ថុ មានដូចជា អចលនវត្ថុ ចលនវត្ថុ នានា។
  - អចលនវត្ថុ រួមមាន ដីធ្លីរួមទាំងអគារ និងវត្ថុដែលនៅជាប់ដី អាគារ សហកម្មសិទ្ធិ បន្ទប់ខុនដូ
  - ចលនវត្ថុ រួមមាន រថយន្ត ម៉ូតូ គ្រឿងសង្ហារឹម គ្រឿងអលង្ការ ។ល។
- សិទ្ធិលើបំណុល សំដៅចំពោះសិទ្ធិលើទ្រព្យសម្បត្តិរបស់កូនបំណុល ដែលមានចំពោះតតិយជន។
- ឋានៈបុគ្គល រួមមាន រូបវន្តបុគ្គល និងនីតិបុគ្គល។

ឋានៈរបស់ភាគីនៃការចាត់ចែងរក្សាការពារ  មានកូនបំណុល និងម្ចាស់បំណុល។ ម្ចាស់បំណុល សំដៅលើបុគ្គលដែលដាក់ពាក្យសុំឱ្យតុលាការចេញដីកាសម្រេច។ កូនបំណុល សំដៅទៅលើបុគ្គលដែលត្រូវបានគេ

ដាក់ពាក្យសុំឱ្យចាត់ចែងរក្សាការពារ។ ឋានៈរបស់ភាគីក្នុងនីតិវិធីរដ្ឋប្បវេណីផ្សេងទៀតត្រូវបានកំណត់ដូចខាងក្រោម៖

- នីតិវិធីបណ្ដឹង ត្រូវបានហៅថា ដើមចោទ និងចុងចម្លើយ។
- ការអនុវត្តដោយបង្ខំ ហៅថា ម្ចាស់បំណុលនៃការអនុវត្ត និងកូនបំណុលនៃការអនុវត្ត។
- រឿងក្ដីមិនមែនបណ្ដឹង ហៅថា អ្នកដាក់ពាក្យសុំ និងភាគីម្ខាងទៀតនៃអ្នកដាក់ពាក្យសុំ។
- នីតិវិធីបណ្ដឹងឧទ្ធរណ៍ ហៅថា ដើមបណ្ដឹងឧទ្ធរណ៍ និងចុងបណ្ដឹងឧទ្ធរណ៍។

តុលាការអាចចេញដីការឹបអូសជាបណ្ដោះអាសន្នបានលុះត្រាតែទំនាក់ទំនងគតិយុត្តរវាងម្ចាស់បំណុល និងកូនបំណុល គឺជាសិទ្ធិទាមទារដែលមានគោលបំណងឱ្យសងជាប្រាក់។ យោងតាមមាត្រា ៥៣១ ចំណុច ក នៃក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាចែងថា ការរឹបអូសជាបណ្ដោះអាសន្នជាការចាត់ចែងដែលកម្រិតនូវការចាត់ចែងទ្រព្យសម្បត្តិរបស់កូនបំណុលដើម្បីរក្សាការពារការអនុវត្តដោយបង្ខំ ចំពោះសិទ្ធិលើបំណុលដែលមានគោលបំណងឱ្យសងជាប្រាក់។ មានន័យថា៖ការរឹបអូសជាបណ្ដោះអាសន្ន ជាវិធានការមួយចាត់ចែងរឹបអូសបណ្ដោះអាសន្នទៅលើទ្រព្យសម្បត្តិរបស់កូនបំណុល ដែលមានគោលបំណងអោយសងជាប្រាក់ ប្រសិនបើមានការបារម្ភថាការអនុវត្តដោយបង្ខំនឹងមិនអាចធ្វើបាន ឬ នឹងមានការលំបាកយ៉ាងខ្លាំងក្នុងការអនុវត្តដោយបង្ខំ។

**ឧទាហរណ៍៖** លោក ក ជំពាក់ប្រាក់ លោក ខ មិនព្រមសង។ លោក ខ ទទួលដំណឹងថា លោក ក ប្រកាសលក់ផ្ទះ។ លោក ខ មានការព្រួយបារម្ភថា លោក ក លក់ផ្ទះបានប្រាក់ហើយមិនយកប្រាក់មកសងខ្លួន។ លោក ខ ដាក់ពាក្យសុំដីកាសម្រេចរក្សាការពារទៅលើផ្ទះនោះ។

ការចាត់ចែងជាបណ្ដោះអាសន្ន ជាប្រភេទមួយនៃការចាត់ចែងរក្សាការពារ ហើយត្រូវបានគេបែងចែកជា ២ ប្រភេទ រួមមាន ការចាត់ចែងជាបណ្ដោះអាសន្នចំពោះវត្ថុដែលជាកម្មវត្ថុនៃវិវាទ និង ការចាត់ចែងជាបណ្ដោះអាសន្នដែលកំណត់ឋានៈជាបណ្ដោះអាសន្ន។

## ២.១.ការចាត់ចែងជាបណ្ដោះអាសន្នចំពោះវត្ថុដែលជាកម្មវត្ថុនៃវិវាទ

ការចាត់ចែងជាបណ្ដោះអាសន្នចំពោះវត្ថុដែលជាកម្មវត្ថុនៃវិវាទ ជាការចាត់ចែងដែលរក្សាទុកនូវស្ថានភាពបច្ចុប្បន្ន នៃវត្ថុដែលជាកម្មវត្ថុនៃវិវាទ ក្នុងករណីដែលមានការបារម្ភថា ម្ចាស់បំណុលនឹងមិនអាចអនុវត្តសិទ្ធិ ឬនឹងមានការលំបាកយ៉ាងខ្លាំងក្នុងការអនុវត្តសិទ្ធិដោយសារមានការប្រែប្រួលស្ថានភាពបច្ចុប្បន្ននៃវត្ថុនោះ។

ដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្ន ត្រូវបានចែកចេញជាពីរ គឺដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្នចំពោះវត្ថុដែលជាកម្មវត្ថុវិវាទ និងការចាត់ចែងជាបណ្ដោះអាសន្នដែលកំណត់ឋានៈជាបណ្ដោះអាសន្ន ហើយដីកាទាំងពីរប្រភេទនេះ គឺជាសិទ្ធិទាមទារដែលគ្មានគោលបំណងអោយសងជាប្រាក់។

ចំពោះវត្ថុដែលជាកម្មវត្ថុនៃវិវាទ ជាការចាត់ចែងដែលរក្សាទុកនូវស្ថានភាពបច្ចុប្បន្ននៃវត្ថុវិវាទសម្រាប់ការអនុវត្តដោយបង្ខំនាពេលអនាគត និងការពារវត្ថុដែលជាកម្មវត្ថុ កុំឱ្យខូចខាត ឬបាត់បង់ ពោល គឺរក្សាឱ្យបាននូវស្ថានភាពដើម។

**ឧទាហរណ៍៖** លោក ក លក់ដីឱ្យ ខ ហើយបានចុះបញ្ជីផ្ទេរកម្មសិទ្ធិឱ្យទៅ លោក ខ រួចរាល់។ ក្រោយមក លោក ក រំលាយកិច្ចសន្យាទិញលក់វិញ ដោយសារ លោក ខ មិនបានបង់ប្រាក់បង្គ្រប់។ ប៉ុន្តែ លោក ខ មិនបានចុះបញ្ជីផ្ទេរសិទ្ធិមកឱ្យលោក ក វិញទេ។ ហេតុដូច្នេះ ក បានសុំឱ្យតុលាការចេញដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្ន ព្រោះបារម្ភ ខ ធ្វើការផ្ទេរកម្មសិទ្ធិឱ្យអ្នកដទៃ។

## ២.២. ការចាត់ចែងជាបណ្ដោះអាសន្នដែលកំណត់ឋានៈជាបណ្ដោះអាសន្ន

ការចាត់ចែងជាបណ្ដោះអាសន្នដែលកំណត់ឋានៈជាបណ្ដោះអាសន្ន គឺជាការចាត់ចែង ដែលកំណត់ស្ថានភាពជាបណ្ដោះអាសន្នរហូតដល់សាលក្រម ឬ សាលដីកា ចូលជាស្ថាពរ ក្នុងករណីដែលមានភាពចាំបាច់ដើម្បីជៀសវាងការខូចខាតធ្ងន់ធ្ងរ ឬ គ្រោះថ្នាក់បន្ទាន់ ដែលនឹងកើតឡើងដល់ម្ចាស់បំណុល ចំពោះទំនាក់ទំនងគតិយុត្តដែលមានវិវាទ។ តុលាការ អាចចេញដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្ន ដែលកំណត់ឋានៈជាបណ្ដោះអាសន្ន ក្នុងករណីដែល មានភាពចាំបាច់ ដើម្បីជៀសវាង ការខូចខាតធ្ងន់ធ្ងរ ឬ គ្រោះថ្នាក់បន្ទាន់ ដែលនឹងកើតឡើង ដល់ម្ចាស់បំណុល ចំពោះទំនាក់ទំនងគតិយុត្ត ដែលមានវិវាទ។

**ឧទាហរណ៍៖** ការចាត់ចែងជាបណ្ដោះអាសន្ន ដែលរក្សាការពារ ឋានៈជាកម្មករ ឬ ការចាត់ចែងជាបណ្ដោះអាសន្ន ដែលបង្គាប់ឱ្យបង់ប្រាក់ខែ ជាបណ្ដោះអាសន្ន ក្នុងករណីដែល មានវិវាទ អំពីសុពលភាព នៃការដេញកម្មករនោះ។ ការចាត់ចែងជាបណ្ដោះអាសន្នដែលបង្គាប់ ឱ្យបង់ប្រាក់ខែ ជាបណ្ដោះអាសន្ននេះ គឺជាការចាត់ចែងរក្សាការពារ ដើម្បីឱ្យទទួលនូវការស្កប់ចិត្តជាបណ្ដោះអាសន្ន ចំពោះសិទ្ធិ ដែលត្រូវបានរក្សាការពារ ហេតុនេះហើយ បានជាគេហៅថា ការចាត់ចែងជាបណ្ដោះអាសន្ន។

តុលាការមិនអាចចេញដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្នដែលកំណត់ឋានៈជាបណ្ដោះអាសន្នបានឡើយ បើមិនឆ្លងកាត់កាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ ឬ តាមកាលបរិច្ឆេទនៃការសួរ ដែលកូនបំណុលអាចចូលរួមបាន។ ទោះបីជាមូលដ្ឋាន ការចាត់ចែងជាបណ្ដោះអាសន្ន ត្រូវធ្វើជាសម្ងាត់ដូចករណីនៃការរឹបអូសជាបណ្ដោះអាសន្នក៏ដោយ នៅក្នុងការចាត់ចែងជាបណ្ដោះអាសន្នដែលកំណត់ឋានៈជាបណ្ដោះអាសន្នផលប្រយោជន៍របស់ម្ចាស់បំណុលនៅតែត្រូវបានការពារទោះជាគ្មានការវិនិច្ឆ័យជាសម្ងាត់ក៏ដោយ ហើយ

ម្យ៉ាងទៀត បើនីតិវិធីនេះធ្វើឡើងដោយសម្ងាត់នោះនឹងនាំឱ្យមានការប៉ះពាល់ធ្ងន់ធ្ងរដល់កូនបំណុល។ ហេតុនេះហើយបានជាច្បាប់ផ្តល់ឱកាសឱ្យដល់កូនបំណុលក្នុងការការពារខ្លួន នៅក្នុងការចាត់ចែងជាបណ្តោះអាសន្នប្រភេទនេះ។ ក៏ប៉ុន្តែបើមានស្ថានភាពពិសេសដែលនាំអោយពុំអាចសម្រេចគោលបំណងនៃ ពាក្យសុំអោយចេញដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្ន ដោយសារឆ្លងតាមកាលបរិច្ឆេទនៃការទាញហេតុផលផ្ទាល់មាត់ជាអាទិ៍ នោះដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្នអាចចេញបានដោយមិនចាំបាច់ឆ្លងតាមកាលបរិច្ឆេទនៃការទាញហេតុផលផ្ទាល់មាត់ទេ។

# ជំពូកទី២
# លំហូរនីតិវិធីនៃ
# ការចាត់ចែងជាបណ្ដោះអាសន្ន
# ចំពោះអចលវត្ថុ

# ជំពូកទី២

# លំហូរនីតិវិធីនៃការចាត់ចែងជាបណ្តោះអាសន្នចំពោះអចលនវត្ថុ

មុននឹងចូលដល់នីតិវិធីក្នុងការចាត់ចែងជាបណ្តោះអាសន្ន មានសំណួរមួយចំនួនដែលគេអាចលើកឡើងបានរួមមាន៖ តើគោលបំណងរបស់ភាគីចង់អ្វី? មានគោលបំណងឱ្យចង់ប្រគល់ប្រាក់ ឬគ្មានគោលបំណងសងជាប្រាក់ ពោលគឺប្រគល់វត្ថុជាក់លាក់កំណត់មួយ?

នៅក្នុងនីតិវិធីនៃការចាត់ចែងជាបណ្តោះអាសន្នចំពោះវត្ថុដែលជាកម្មវត្ថុនៃវិវាទមានកម្មវត្ថុចម្បងពីរ រួមមានចលនវត្ថុ និងអចលនវត្ថុ។ ដោយក្រុមរបស់ខ្ញុំបាទធ្វើការជ្រើសរើស អំពីអចលនវត្ថុដែលជាកម្មវត្ថុនៃវិវាទបែបនេះហើយនៅក្នុងលំហូរនីតិវិធីតាំងពីដំណើរការនៃការដាក់ពាក្យសុំរហូតដល់ចេញដីកាសម្រេចគឺកម្មវត្ថុចម្បងគឺជាអចលនវត្ថុ។

## ផ្នែកទី១៖ ដំណើរការនីតិវិធីនៃការចាត់ចែងជាបណ្តោះអាសន្នចំពោះអចលនវត្ថុ

ផ្អែកតាមមាត្រា៥៣០នៃក្រមនីតិវិធីរដ្ឋប្បវេណី ការចាត់ចែងរក្សាការពារជានីតិវិធីមានគោលបំណងការពារនិងថែរក្សាស្ថានភាពបច្ចុប្បន្ន ដោយប្រើអំណាចរដ្ឋដើម្បីការពារសិទ្ធិស្របច្បាប់របស់បុគ្គលនៅពេលដែលមានការបារម្ភថាការអនុវត្តដោយបង្ខំនឹងមិនអាចធ្វើបានឬនឹងមានការលំបាកយ៉ាងខ្លាំងក្នុងការអនុវត្តដោយបង្ខំដោយសារមានការប្រែប្រួលស្ថានភាពបច្ចុប្បន្ននៃទ្រព្យសម្បត្តិរបស់កូនបំណុលនៃការអនុវត្ត ឬមានការបារម្ភថានឹងមានការខូចខាតធ្ងន់ធ្ងរ ឬគ្រោះថ្នាក់បន្ទាន់ដល់ឋានៈរបស់ភាគីណាមួយ ដោយសារមានវិវាទអំពីទំនាក់ទំនងនៃសិទ្ធិ បុគ្គលដែលមានបំណងចង់ការពារសិទ្ធិរបស់ខ្លួនអាចទាមទារការចាត់ចែងរក្សាការពារបាន។

នៅក្នុងបណ្តឹងអង្គសេចក្តី ចាប់ពីពេលដាក់ពាក្យបណ្តឹងរហូតដល់ពេលសាលក្រមស្ថាពរ ត្រូវចំណាយពេលវេលាច្រើន ក្នុងអំឡុងពេលនេះ កូនបំណុលអាចផ្ទេរទ្រព្យសម្បត្តិរបស់ខ្លួនឱ្យទៅតតិយជនបានតាមអំពើចិត្ត ហេតុនេះ ទោះបីជាម្ចាស់បំណុលឈ្នះក្តីក៏ដោយ អាចមានករណីដែលមិនអាចធ្វើការអនុវត្តដោយបង្ខំបាន។ វិធានការណ៍នេះ ជាវិធីតាមផ្លូវច្បាប់ដើម្បីការពារផលប្រយោជន៍របស់ម្ចាស់បំណុលក្នុងការរក្សានូវស្ថានភាពបច្ចុប្បន្ននៃវត្ថុ ដើម្បីធានាការអនុវត្តដោយបង្ខំនាពេលអនាគត។

### ១.១. ការដាក់ពាក្យសុំ

នៅក្នុងពាក្យសុំឱ្យចេញដីកាសម្រេចរក្សាការពារ ត្រូវធ្វើការបំពេញទម្រង់ដែលច្បាប់បានកំណត់ក្នុងបញ្ជាក់អំពីគោលបំណងដែលមកធ្វើការពឹងពាក់ឱ្យតុលាការធ្វើការដោះស្រាយវិវាទដែលកំពុងជួបប្រទះដោយប្រើអំណាចរបស់រដ្ឋ ដើម្បីការពារសិទ្ធិស្របច្បាប់របស់បុគ្គល នៅពេលដែលមានការបារម្ភថា ការអនុវត្តដោយបង្ខំនឹងមិនអាចធ្វើបាន។

តើកម្មវត្ថុដែលបានដាក់មកកាន់តុលាការ តើភាគីចង់បានអី ទើបឈានដល់អោយតុលាការក្នុងការជួយដោះស្រាយអំពីបញ្ហាកំពុងតែជួបប្រទះនឹង?

ដើម្បីអោយការទាមទាររបស់ខ្លួនមានប្រសិទ្ធិភាពតាមផ្លូវច្បាប់ ភាគីត្រូវតែធ្វើការបំពេញទម្រង់បែបបទដែលច្បាប់បានកំណត់ ទើបតុលាការ ធ្វើការវិនិច្ឆ័យដោយផ្អែកលើភស្តុតាងរបស់ភាគីដែលជាអង្គហេតុចម្បងក្នុងការទាមទារដើម្បីអោយតុលាការធ្វើការសម្រេចចិត្ត។

## ១.១.១. ចំណុចដែលត្រូវសរសេរនៅក្នុងពាក្យសុំ

### ១.១.១.១. ឈ្មោះ ឬនាមករណ៍ និងអាសយដ្ឋានរបស់ភាគី និង របស់អ្នកតំណាងដែលច្បាប់ បានកំណត់

ឈ្មោះ ឬនាមករណ៍ គឺជាអត្តសញ្ញាណរបស់ភាគី ឬភាគីបានធ្វើការជ្រើសរើសអ្នកតំណាងដែលច្បាប់បានកំណត់(មេធាវី ដើម្បីមកការពារផលប្រយោជន៍របស់ខ្លួន) នៅក្នុងប្រភេទសំណុំរឿងរក្សាការពារភាគីត្រូវបានផ្លាស់ប្តូរសមាសភាពក្លាយជា ម្ចាស់បំណុល និងកូនបំណុល។

**ឧទាហរណ៍៖** ម្ចាស់បំណុល ៖ ឈ្មោះ A អាសយដ្ឋាន ..... កូនបំណុល ៖ ឈ្មោះ B អាសយដ្ឋាន .....

### ១.១.១.២. ខ្លឹមសារនៃដីកាសម្រេចការពារ

នៅក្នុងខ្លឹមសារនៃដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្នចំពោះអចលនវត្ថុ ការទាមទាររបស់ភាគីត្រូវសរសេរជាពីរទម្រង់ផ្សេងៗពីគ្នា៖

**ប្រសិនបើសិទ្ធិដែលត្រូវបានការពារជាសិទ្ធិទាមទារឱ្យចុះបញ្ជី**

«កូនបំណុល មិនអាចធ្វើអនុប្បទាន ដាក់ប្រាតិភោគ(បញ្ចាំ ឬហ៊ីប៉ូតែកជាអាទិ៍) និងការចាត់ចែងផ្សេងៗទៀត ទៅលើអចលនវត្ថុ ដូចមានកំណត់នៅក្នុងឧបសម្ព័ន្ធនៃបញ្ជីអចលនវត្ថុជាបណ្តោះអាសន្ន» ។

**ប្រសិនបើសិទ្ធិដែលត្រូវបានការពារជាសិទ្ធិទាមទារឱ្យប្រគល់វត្ថុ ដូចជា អចលនវត្ថុជាអាទិ៍**

- ហាមឃាត់កូនបំណុលមិនឱ្យផ្ទេរការកាន់កាប់អចលនវត្ថុ ដូចមានកត់ត្រានៅក្នុងឧបសម្ព័ន្ធនៃបញ្ជីអចលនវត្ថុជាបណ្តោះអាសន្ន
- បង្គាប់ឱ្យកូនបំណុលប្រគល់អចលនវត្ថុដូចមានកត់ត្រានៅក្នុងឧបសម្ព័ន្ធនៃបញ្ជីអចលនវត្ថុ ទៅឱ្យអាជ្ញាសាលា
- បង្គាប់ឱ្យអាជ្ញាសាលាថែរក្សាគ្រប់គ្រងអចលនវត្ថុ ដូចមានកត់ត្រានៅក្នុងឧបសម្ព័ន្ធនៃបញ្ជីអចលនវត្ថុ
- អាជ្ញាសាលាត្រូវប្រកាសជាសាធារណៈថា កូនបំណុលត្រូវបានហាមឃាត់ការផ្ទេរការកាន់កាប់ អចលនវត្ថុ ហើយអាជ្ញាសាលាគ្រប់គ្រងថែរក្សាអចលនវត្ថុ ដូចមានកត់ត្រានៅក្នុងឧបសម្ព័ន្ធនៃបញ្ជី អចលនវត្ថុ

- អាជ្ញាសាលាត្រូវបិទលិខិតប្រកាសជាសាធារណៈ តាមរបៀបដែលពុំងាយបករចេញ ឬ តាមរបៀបសមរម្យផ្សេងទៀត ចំពោះចំណុច ១និង៣

**កំណត់សម្គាល់៖** តុលាការអាចបង្គាប់ឱ្យអាជ្ញាសាលាប្រគល់អចលនវត្ថុដូចមានកត់ត្រានៅក្នុងឧបសម្ព័ន្ធនៃបញ្ជីអចលនវត្ថុ ទៅឱ្យម្ចាស់បំណុល ឬប្រគល់ការប្រើប្រាស់ឱ្យកូនបំណុល។

### ១.១.១.៣. សិទ្ធិ ឬទំនាក់ទំនងគតិយុត្ត ដែលត្រូវបានរក្សាការពារ

ផ្អែកតាមមាត្រា ៥៤១ កថាខណ្ឌទី ១ ចំណុច «គ» នៃក្រមនីតិវិធីរដ្ឋប្បវេណី ពាក្យសុំឱ្យចេញដីកាសម្រេចរក្សាការពារត្រូវសរសេរអំពីសិទ្ធិ ឬ ទំនាក់ទំនងគតិយុត្តដែលនឹងត្រូវបានរក្សាការពារ។ សិទ្ធិឬទំនាក់ទំនងគតិយុត្តដែលនឹងត្រូវបានរក្សាការពារ គឺជាសិទ្ធិទាមទារដែលមានកំណត់នៅក្នុងច្បាប់សារធាតុដែលដូចគ្នានឹងសិទ្ធិទាមទារនៅក្នុងបណ្ដឹងអង្គសេចក្តី។ ម្យ៉ាងវិញទៀត សិទ្ធិឬទំនាក់ទំនងគតិយុត្តដែលនឹងត្រូវបានរក្សាការពារ ត្រូវតែជាសិទ្ធិទាមទារដែលគ្មានគោលបំណងឱ្យសងជាប្រាក់។ ក្នុងករណី សិទ្ធិឬទំនាក់ទំនងគតិយុត្តដែលនឹងត្រូវបានរក្សាការពារ ជា**<u>សិទ្ធិទាមទារឱ្យចុះបញ្ជី (លុបការចុះបញ្ជីអំពីការផ្ទេរកម្មសិទ្ធិផ្អែកលើអានុភាពនៃបដិទាន) ដោយមូលហេតុរំលាយ កិច្ចសន្យា</u>** (ប្រការ ៣១ នៃប្រកាសអន្តរក្រសួងស្តីពីនីតិវិធីនៃការចុះបញ្ជីអំពីសិទ្ធិប្រត្យក្សទាក់ទងនឹងក្រម រដ្ឋប្បវេណី) ខ្លឹមសារនៃការចាត់ចែងជាបណ្ដោះអាសន្នចំពោះអចលនវត្ថុគឺការហាមឃាត់ការចាត់ចែង ។ ក្នុងករណី សិទ្ធិឬទំនាក់ទំនងគតិយុត្តដែលត្រូវរក្សាការពារ គឺ **<u>សិទ្ធិទាមទារឱ្យប្រគល់វត្ថុផ្អែកលើកម្មសិទ្ធិជាអាទិ៍</u>** ខ្លឹមសារនៃការចាត់ចែងជាបណ្ដោះអាសន្នចំពោះអចលនវត្ថុ គឺ "ហាមឃាត់ការផ្ទេរការកាន់កាប់"។

យោងតាមមាត្រា៥៤១កថាខណ្ឌទី៣នៃក្រមនីតិវិធីរដ្ឋប្បវេណីអ្នកដាក់ពាក្យសុំគប្បីសរសេរឱ្យច្បាស់លាស់ និងសរសេរនូវកស្តុតាងតាមអង្គហេតុនីមួយៗ ដែលត្រូវបញ្ជាក់ចំពោះចំណុចស្តីអំពីសិទ្ធិ ឬទំនាក់ទំនងគតិយុត្តដែលនឹងត្រូវបានរក្សាការពារ។ ហេតុនេះដើម្បីឱ្យមានភាពច្បាស់លាស់ អ្នកដាក់ពាក្យសុំគប្បីសរសេរនូវអង្គហេតុដែលជាមូលហេតុនៃការទាមទារ និងអង្គហេតុសំខាន់ៗក្នុងចំណោមអង្គហេតុដែលជាមូលហេតុនៃការទាមទារ ដូចមានបញ្ញត្តនៅក្នុងមាត្រា ៧៥ កថាខណ្ឌទី ៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី (សូមអានខ្លឹមសារនៅក្នុងឯកសារគំរូនៃពាក្យសុំ)។ ក្នុងពាក្យសុំ ក៏អាចសរសេរនូវអង្គហេតុដែលអាចគិតទុកថា កូនបំណុលនឹងតវ៉ានៅក្នុងបណ្ដឹងអង្គសេចក្ដី ហើយក៏ត្រូវសរសេរអំពីការតវ៉ាតបនឹងការតវ៉ានោះផងដែរ។

**ឧទាហរណ៍៖** នៅក្នុងពាក្យសុំឱ្យចេញដីកាសម្រេចរក្សាការពារ ម្ចាស់បំណុលអះអាងអំពីសិទ្ធិ ឬទំនាក់ទំនងគតិយុត្តដែលនឹងត្រូវបានរក្សាការពារ ជាសិទ្ធិទាមទារឱ្យចុះបញ្ជី(លុបការចុះបញ្ជីអំពីការផ្ទេរកម្មសិទ្ធិផ្អែកលើអានុភាពនៃបដិទានដោយមូលហេតុនៃកិច្ចសន្យាជាអាទិ៍)។ កូនបំណុលនឹងអះអាងអង្គហេតុតវ៉ាថាខ្លួននឹង

សហការលុបការចុះបញ្ជីរហូតដល់ម្ចាស់បំណុលប្រគល់ប្រាក់ដែលបានបង់រួចមកឱ្យកូនបំណុលគ្រប់ចំនួន (សិទ្ធិតវ៉ាឱ្យអនុវត្តព្រមគ្នា) ហេតុនេះ ម្ចាស់បំណុលអាចអះអាងអង្គហេតុតវ៉ាតបស្ដីពីការសេង ឬសំលើផ្ដល់ការសង (ខ្ញុំយកប្រាក់ដែលកូន បំណុលបានបង់រួចឱ្យកូនបំណុលវិញ ប៉ុន្តែកូនបំណុលមិនទទួល) ចំណុចទាំងនេះ អាចឱ្យតុលាការជឿជាក់ ចំពោះការអះអាងអំពីសិទ្ធិ ឬទំនាក់ទំនងគតិយុត្តរបស់ម្ចាស់បំណុលដែលចាំបាច់ត្រូវរក្សាការពារ។

### ១.១.១.៤. ភាពចាំបាច់នៃការចាត់ចែងរក្សាការពារ

ផ្អែកតាមមាត្រា ៥៤១ កថាខណ្ឌទី ១ ចំណុច «ឃ» នៃក្រមនីតិវិធីរដ្ឋប្បវេណី ពាក្យសុំឱ្យចេញដីកាសម្រេចរក្សាការពារ ត្រូវសរសេរនូវភាពចាំបាច់នៃការរក្សាការពារ។ ភាពចាំបាច់ នៃការរក្សាការពារ គឺជាអង្គហេតុទាំងឡាយណាដែលបញ្ជាក់អំពីការបារម្ភរបស់ម្ចាស់បំណុលថា មិនអាចធ្វើបានឬមានការលំបាកខ្លាំងក្នុងការអនុវត្តដោយបង្ខំ។ករណីកម្មសិទ្ធិនៃដី L១ និង L២ ស្ថិតនៅក្រោមឈ្មោះកូនបំណុល ហេតុនេះ កូនបំណុលអាចធ្វើការចាត់ចែងដោយសេរី។ករណី ដីជាក់ស្ដែងកំពុងកាន់កាប់ដោយកូនបំណុល ហើយនៅក្នុងកិច្ចសន្យាជួលបានអនុញ្ញាតឱ្យកូនបំណុលជួលបន្តជាអាទិ៍ អាចមានស្ថានភាពដែលកូនបំណុល ផ្ទេរការកាន់កាប់ជាក់ស្ដែងទៅតតិយជន បានដោយងាយស្រួល ជាអាទិ៍។

### ១.១.២. សោហ៊ុយនៃការចាត់ចែងរក្សាការពារ

នៅក្នុងករណីដែលដាក់ពាក្យសុំឱ្យចេញដីកាសម្រេចរក្សាការពារ អ្នកដាក់ពាក្យសុំត្រូវបង់ពន្ធចំនួន ៥.០០០(ប្រាំពាន់)រៀលទៅកាន់តុលាការ។

## ១.២. យុត្តាធិការដែលមានសមត្ថកិច្ច

ផ្អែកតាមមាត្រា ៥៤០ មាត្រា ៥៣៣ មាត្រា ១៧ និងមាត្រា ១១ នៃក្រមនីតិវិធីរដ្ឋប្បវេណី សំណុំរឿងរក្សាការពារ ត្រូវស្ថិតក្រោមសមត្ថកិច្ចផ្ដាច់មុខរបស់តុលាការដែលមានសមត្ថកិច្ចលើអង្គសេចក្ដី ឬសាលាដំបូងដែលមានសមត្ថកិច្ចលើទីកន្លែងដែលនឹងត្រូវបានរឹបអូសជាបណ្ដោះអាសន្នឬវត្ថុដែលជាកម្មវត្ថុវិវាទស្ថិតនៅ។

**ឧទាហរណ៍៖** ក្នុងអង្គហេតុនេះកូនបំណុលមានអាសយដ្ឋានស្ថិតនៅខេត្តព្រះសីហនុបណ្ដឹងអង្គសេចក្ដីអាចយកតុលាការដែលមានសមត្ថកិច្ចតាមអាសយដ្ឋានរបស់ចុងចម្លើយគឺសាលាដំបូងខេត្តព្រះសីហនុមកធ្វើជាតុលាការដែលមានសមត្ថកិច្ចចំពោះសំណុំរឿងរក្សាការពារបានផងដែរ។

មួយវិញទៀត កម្មវត្ថុដែលត្រូវចាត់ចែងជាបណ្ដោះអាសន្ន ផ្អែកតាមអង្គហេតុខាងលើនេះគឺ ដី L1 ស្ថិតនៅភ្នំពេញ និងដីL2 ស្ថិតនៅខេត្តកណ្ដាលនាំឱ្យសាលាដំបូងរាជធានីភ្នំពេញ ឬសាលាដំបូងខេត្តកណ្ដាលសុទ្ធតែជាតុលាការមានសមត្ថកិច្ច។ ករណីមានសមត្ថកិច្ចច្រើនចំពោះកម្មវត្ថុដែលអាចរួមបញ្ចូលក្នុងពាក្យសុំតែ

មួយបែបនេះ គឺការកំណត់សមត្ថកិច្ចអាស្រ័យនៅពេលដាក់ពាក្យសុំ មានន័យថា បើម្ចាស់បំណុលដាក់ទៅសាលាដំបូងរាជធានីភ្នំពេញក៏បាន ឬសាលាដំបូងខេត្តកណ្ដាល ក៏បាន (មាត្រា ៥៣៩ មាត្រា ១៧ និងមាត្រា ១១ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។ ផ្អែកតាមអង្គហេតុខាងលើនេះ អាចដាក់ពាក្យសុំដីកាសម្រេចរក្សាការពារទៅសាលាដំបូងខេត្តព្រះសីហនុ (តុលាការតាមបណ្ដឹងអង្គសេចក្ដី) ឬដាក់ទៅសាលាដំបូងរាជធានីភ្នំពេញ (តុលាការតាមវត្ថុដែលជាកម្មវត្ថុនៃវិវាទស្ថិតនៅ)ឬដាក់ទៅសាលាដំបូងខេត្តកណ្ដាល(តុលាការតាមវត្ថុដែលជាកម្មវត្ថុនៃវិវាទស្ថិតនៅ)។

## ១.៣. ការត្រួតពិនិត្យពាក្យសុំ

នៅពេលដែលធ្វើការដាក់ពាក្យសុំចេញដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្ន (អំពីកម្មវត្ថុដែលបានទាមទារ) តុលាការនឹងធ្វើការត្រួតពិនិត្យអំពីពាក្យសុំ[1]។

តើខ្លឹមសារដែលម្ចាស់បំណុលបានធ្វើការដាក់ពាក្យសុំចេញដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្នចំពោះអចលនវត្ថុ តើវាមានលក្ខណៈគ្រប់គ្រាន់តាមផ្លូវច្បាប់ដែរឬទេ? ក្នុងករណីនេះតុលាការនឹងធ្វើការពិនិត្យពាក្យសុំ។

នៅក្នុងដំណាក់កាលនៃការត្រួតពិនិត្យ បើតុលាការពិនិត្យឃើញថា ចំណុចដែលសរសេរនៅក្នុងពាក្យសុំមានចំណុចខុសតុលាការនឹងធ្វើការបង្គាប់ឱ្យកែតម្រូវ។ [2] ប៉ុន្តែក្នុងករណីដែលអ្នកពាក្យសុំមិនបានធ្វើការកែប្រែតាមការបង្គាប់របស់តុលាការ និងធ្វើការលើកចោលពាក្យសុំឱ្យចេញដីកាសម្រេចរក្សាការពារ (ម្ចាស់បំណុលអាចធ្វើការប្ដឹងជំទាស់បានក្នុងអំឡុងពេល២សប្ដាហ៍ចាប់ពីថ្ងៃដែលខ្លួនបានទទួលការជូនដំណឹង។[3]

[1] ក្រមនីតិវិធីរដ្ឋប្បវេណី,លេខ នស/រកម/0៧0៦/0២១, 0៦ កក្កដា ២00៦, មាត្រា ៥៤១។

[2] ក្រមនីតិវិធីរដ្ឋប្បវេណី,លេខ នស/រកម/0៧0៦/0២១, 0៦ កក្កដា ២00៦, មាត្រា៧៨។

[3] ក្រមនីតិវិធីរដ្ឋប្បវេណី,លេខ នស/រកម/0៧0៦/0២១, 0៦ កក្កដា ២00៦, មាត្រា៥៤៤។

# ផ្នែកទី២៖ ការដាក់ប្រាតិភោគ

ការដាក់ប្រាតិភោគ ជាប្រាក់ដែលត្រូវបានដាក់ដោយបុគ្គលដែលមានកាតព្វកិច្ច (អ្នកដាក់ប្រាតិភោគ) មកតុលាការ ដើម្បីធានាសំណង សម្រាប់អ្នកមានសិទ្ធិលើប្រាតិភោគ។

## ២.១ មូលហេតុដែលនាំឱ្យដាក់ប្រាតិភោគ

ការដាក់ប្រាតិភោគផ្តល់ផលប្រយោជន៍ដល់ភាគីម្ខាងទៀតនៃបណ្តឹង ឬពាក្យសុំដើម្បីបញ្ចៀសការប្តឹងដោយគ្មានមូលដ្ឋាន ឬតាមទំនើងចិត្តរបស់ភាគីម្ខាងទៀត។ មិនតែប៉ុណ្ណោះ ការដាក់ប្រាតិភោគអាចឱ្យបុគ្គលដែលរងបណ្តឹង ឬភាគីម្ខាងទៀតនៃពាក្យសុំទទួលបានការធានាតាមរយៈការតម្កល់ជា ប្រាតិភោគដើម្បីទទួលបានសិទ្ធិជាអទិភាពនៅពេលសាមីខ្លួនឈ្នះបណ្តឹង។ នៅក្នុងដីកាសម្រេចរក្សាការពារ អាចធ្វើដោយឱ្យដាក់ប្រាតិភោគ ឬមិនឱ្យដាក់ប្រាតិភោគបានទៅតាមឆន្ទានុសិទ្ធិរបស់តុលាការ។

### ២.១.១. ប្រាតិភោគសម្រាប់ដីកាសម្រេចរក្សាការពារ

ការដាក់ប្រាតិភោគសម្រាប់ដីកាសម្រេចរក្សាការពារ គឺជាយន្តការសម្រាប់ការពារផលប្រយោជន៍របស់អ្នកមានសិទ្ធិលើប្រាតិភោគ។

ឧទាហរណ៍៖ ក ដាក់ពាក្យសុំឱ្យចេញដីកាសម្រេចរក្សាការពារលើដី(ភ្នំពេញ) របស់ ខ ដែលដី (ភ្នំពេញ) មានតម្លៃ100,000$ ហើយសិទ្ធិលើបំណុលគិតត្រឹមកាលបរិច្ឆេទនៃការដាក់ពាក្យសុំគឺ120,000$ ។ ក្នុងករណីនេះ តុលាការយល់ឃើញថា មានភាពចាំបាច់ ដាក់ប្រាតិភោគដើម្បីជាលក្ខខណ្ឌនៃការចេញដីកាសម្រេចរក្សាការពារ គឺតុលាការបង្គាប់ឱ្យ ក ដាក់ប្រាតិភោគចំនួន100,000$ ដើម្បីទទួលបានដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្ន។[4]

ប្រសិនបើ ក ចាញ់ក្តី ខ អាចទាមទារសំណងផ្អែកលើអំពើអនីត្យានុកូល ហើយអាចអនុវត្តដោយបង្ខំចំពោះប្រាក់ដែលជាប្រាតិភោគ ដោយមានអត្ថិភាពជាងម្ចាស់បំណុលផ្សេងទៀតរបស់ ក។

### ២.១.២. ប្រាតិភោគសម្រាប់ផ្អាកការអនុវត្តរក្សាការពារ

ពេលដែលចេញដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្ន ក្នុងការអនុវត្តដីកាសម្រេចរក្សាការពារ។

ឧទាហរណ៍៖ A ដាក់ពាក្យសុំឱ្យចេញ ដីកាសម្រេចរក្សាការពារហាមឃាត់ កូនបំណុល B មិនឱ្យធ្វើអាជីវកម្មនៅក្នុង តំបន់ X និងបានអនុវត្តរក្សាការពាររួច ហើយ។ បានដាក់ពាក្យតវ៉ាចំពោះដីកា សម្រេចរក្សា

[4] ក្រមនីតិវិធីរដ្ឋប្បវេណី,លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៥៤២។

ការពារ ដោយបានបញ្ជាក់ពី មូលហេតុ និងសេចក្ដីបញ្ជាក់ដំបូងអំពីការ តវ៉ា គោលបំណងលុបចោល។ ប៉ុន្តែការសុំ តវ៉ាមិនបង្អាក់ ឬលុបការអនុវត្តបានឡើយ ត្រូវមានពាក្យសុំលុប ឬផ្អាកការអនុវត្តរក្សា ការពារ ដោយភ្ជាប់នឹងការដាក់ប្រាតិភោគរបស់កូនបំណុល ទើបអាចផ្អាកបាន។[5]

ពាក្យសុំតវ៉ាចំពោះដីកាសម្រេចរក្សាការពារ មិនមានអានុភាពផ្អាក ឬលុបចោលការអនុវត្តទេ។ តុលាការអាចបង្គាប់ឱ្យផ្អាក ឬលុបចោលការអនុវត្តរក្សាការពារបាន នៅពេលដែលកូនបំណុលដាក់ពាក្យសុំផ្អាក ឬលុបចោលការអនុវត្តរក្សាការពារ។

### ២.១.៣. ប្រាតិភោគសម្រាប់លុបចោលដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្នដោយសារស្ថានភាពពិសេស

**ឧទាហរណ៍៖** A ប្ដឹង B ទាមទារប្រាក់។ B បានដឹងថាបើ B ចាញ់ក្ដី ប្រាកដជា Aអនុវត្តលក់ដី L ហេតុនេះ B បានលក់ដីនេះ ឱ្យប្អូនខ្លួនឯង ប៉ុន្តែមិនមែនជាការលកពិតប្រាកដនោះទេ។ បច្ចុប្បន្នដី L ស្ថិតក្រោមឈ្មោះ C។ បើទោះបីជា A ឈ្នះក្ដីក៏មិនអាចអនុវត្តនៅលើដី L បានឡើយ។ A បាន ដឹងថាការលក់ទិញរវាង B និង C មិនមែនជាការលក់ទិញពិតប្រាកដនោះទេ គឺជាការបង្វែរទ្រព្យ ហេតុនេះក៏ដាក់ពាក្យបណ្ដឹងថ្មីមួយទៀត (បណ្ដឹងទាមទារឱ្យលុបចោលនូវអំពើនាំឱ្យខូចប្រយោជន៍- CC#428) ដោយយក B និង C ធ្វើជាសហចុងចម្លើយ ដែលមានខ្លឹមសារទី1លុបចោលកិច្ចសន្យា លក់ទិញដីរវាងនិងC និងទី2 បង្គាប់ឱ្យចុងចម្លើយ  ធ្វើនីតិវិធីចុះបញ្ជីដីទៅឱ្យចុងចម្លើយ។ នៅពេលបណ្ដឹងទាមទារឱ្យលុបចោលនូវអំពើឱ្យខូចប្រយោជន៍នេះកំពុងដំណើរការ ឱកាសដែល ផ្ទេរ ដី ទៅតតិយជនគឺមាកម្រិតខ្ពស់ ហេតុនេះ A អាចដាក់ពាក្យសុំរក្សាការពារ ហាមឃាត់ C មិនឱ្យ ធ្វើអនុប្បទានដី & ផ្អែកលើសិទ្ធិទាមទារឱ្យលុបចោលនូវអំពើនាំឱ្យខូចប្រយោជន៍។ នៅពេលដែលតុលាការចេញដីកាសម្រេចហាមឃាត់ C មិនឱ្យធ្វើអនុប្បទានដីតាមការស្នើសុំរបស់ A ហើយ A បានដាក់ពាក្យសុំអនុវត្តរក្សាការពារនេះរួចហើយ បើ C មានបំណងលុបចោលបន្ទុកនៅលើដី L នោះ C ត្រូវដាក់ប្រាតិភោគទៅតុលាការ។[6]

## ២.២. ដំណើរការនៃការដាក់ប្រាតិភោគ

ក្នុងករណីមានការស្នើសុំឱ្យដាក់ប្រាតិភោគ ជាលក្ខខណ្ឌដើម្បីទទួលបានអានុភាពតាមច្បាប់នូវកិច្ចនីតិវិធីណាមួយ បុគ្គលដែលមានកាតព្វកិច្ចដាក់ប្រាតិភោគ ត្រូវដាក់តាមវិធី ទីកន្លែង ចំនួនប្រាតិភោគ និងពេលវេលាដែលតុលាការកំណត់។

[5] ក្រមនីតិវិធីរដ្ឋប្បវេណី,លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៥៥១។

[6] ក្រមនីតិវិធីរដ្ឋប្បវេណី,លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៥៥៩។

បុគ្គលដែលមានកាតព្វកិច្ចដាក់ប្រាតិភោគ ហៅថាអ្នកដែលបានដាក់ប្រាតិភោគ។ ចំណែកបុគ្គលដែលទទួលផលប្រយោជន៍ពីការតម្កល់ប្រាតិភោគ ហៅថា អ្នកមានសិទ្ធិលើប្រាតិភោគ។

### ២.២.១. វិធីដាក់ប្រាតិភោគ

វិធីដាក់ប្រាតិភោគដែលតុលាការកំណត់ គឺតម្កល់ប្រាក់ ឬឧបករណ៍ដែលអាចជួញដូរបាន ដែលតុលាការទទួលស្គាល់ថាសមរម្យ ដូចជា មូលប្បទានបត្រ ជាអាទិ៍។

**ឧទាហរណ៍៖** តុលាការបង្គាប់ឱ្យចុងចម្លើយ «ខ» ដាក់ប្រាតិភោគចំនួន5,000$ ដើម្បីរួចផុតពីការអនុវត្តសាលក្រមជាបណ្ដោះអាសន្ន។ ក្នុងករណីដែល «ខ» អាចដាក់ប្រាតិភោគក្នុងទម្រង់ជាសាច់ប្រាក់ឬឧបករណ៍ដែលអាចជួញដូរបានដូចជា មូលប្បទានបត្រ ដែលមានចំនួន5,000$ទៅតុលាការ

### ២.២.២. ទីកន្លែងដាក់ប្រាតិភោគ

ទីកន្លែងដាក់ប្រាតិភោគដែលតុលាការកំណត់ គឺទីតាំងតុលាការ ឬធនាគាររបស់តុលាការ។

**ឧទាហរណ៍៖** តុលាការបង្គាប់ឱ្យដើមចោទ«ក»ដាក់ប្រាតិភោគចំនួន «X» តម្កល់នៅសាលាដំបូងរាជធានីភ្នំពេញ ឬគណនីលេខ 00 របស់សាលាដំបូងរាជធានីភ្នំពេញ ដើម្បីទទួលបានការប្រកាសអនុវត្តជាបណ្ដោះអាសន្នលើសាលក្រម។

ក្នុងករណីនេះ «ខ» អាចដាក់ប្រាតិភោគ «X» ទៅកាន់ទីតាំងនៃសាលាដំបូងរាជធានីភ្នំពេញ ឬអាចផ្ញើនៅធនាគារលេខ 00 របស់សាលាដំបូងរាជធានីភ្នំពេញ ដើម្បីទទួលបានការប្រកាសអនុវត្តជាបណ្ដោះអាសន្ន។

### ២.២.៣. ពេលវេលាដាក់ប្រាតិភោគ

ពេលវេលាដាក់ប្រាតិភោគ តុលាការតែងតែកំណត់ដាក់លាក់នៅក្នុងដីកាសម្រេចបង្គាប់ឱ្យដាក់ប្រាតិភោគ។

**ឧទាហរណ៍៖** តុលាការបង្គាប់ឱ្យម្ចាស់បំណុល«ក»ដាក់ប្រាតិភោគ«X»មកតុលាការដើម្បីទទួលបានដីកាសម្រេចរក្សាការពារ ត្រឹមថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០២០។

ក្នុងករណីនេះ «ក» ត្រូវដាក់ប្រាតិភោគទៅតុលាការ យ៉ាងយូរត្រឹមថ្ងៃទី០៤.០៧.២០២០ ពុំនោះទេ តុលាការនឹងចេញដីកាសម្រេចលើកចោលពាក្យសុំឱ្យចេញដីកាសម្រេចរក្សាការពារ ដោយមូលហេតុ «ក» មិនបានដាក់ប្រាតិភោគតាមការកំណត់។

### ២.២.៤. ចំនួនទឹកប្រាក់នៃប្រាតិភោគ

ចំនួនទឹកប្រាក់នៃប្រាតិភោគ តុលាការថ្លឹងថ្លែងទៅតាមករណីជាក់ស្ដែង។

**ឧទាហរណ៍៖** «ក» ដាក់ពាក្យសុំឱ្យចេញដីកាសម្រេចរក្សាការពារលើដី(ភ្នំពេញ)របស់«ខ»ដែលដី(ភ្នំពេញ)មានតម្លៃ 100,000$។

ក្នុងករណីនេះ តុលាការបានចេញដីការសម្រេចបង្គាប់ឱ្យ«ក»ដាក់ប្រាតិភោគចំនួន 100,000$ មកតុលាការ ដើម្បីទទួលបានដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្ន ព្រោះថាដី(ភ្នំពេញ)មានតម្លៃ 100,000$ ហេតុនេះមានភាពសមរម្យដែល «ក» ត្រូវបង់ប្រាក់ 100,000$ ដើម្បីទទួលបានការចាត់ចែងលើដី (ភ្នំពេញ) របស់កូនបំណុល។

## ២.២.៥. ករណីដែលដាក់ ប៉ុន្តែតុលាការអាចបង្គាប់ឱ្យប្តូរប្រាតិភោគ

ប្រសិនបើប្រាតិភោគត្រូវបានដាក់ តុលាការអាចបង្គាប់ឱ្យប្តូរប្រាតិភោគ តាមពាក្យសុំរបស់អ្នកដែលបានដាក់ប្រាតិភោគដោយដីកាសម្រេចបាន។

**ឧទាហរណ៍៖** «ក»បានដាក់បណ្ណសងតាមបញ្ជាតម្លៃ[7]10,000$ជាប្រាតិភោគដើម្បីរួចផុតពីការអនុវត្តសាលក្រមជាបណ្តោះអាសន្ន។ ក្រោយមកបណ្ណនោះបានកើនតម្លៃឡើងដល់15,000$ ហេតុនេះ«ខ» បានដាក់ពាក្យសុំប្តូរប្រាតិភោគ ដែលមានខ្លឹមសារថា«ស្នើសុំប្តូរប្រាតិភោគពីបណ្ណសងតាមបញ្ជាចំនួន10,000$ ទៅជាប្រាក់ចំនួន10,000$ វិញ»។[8]

ក្នុងករណីដែលនេះ តុលាការអាចបង្គាប់ឱ្យ«ខ»ប្តូរប្រាតិភោគដោយខ្លឹមសារថា «បង្គាប់ឱ្យ ខ ដាក់ប្រាតិ-ភោគជាប្រាក់ចំនួន10,000$ ប្តូរជាមួយបណ្ណសងតាមបញ្ជាចំនួន10,000$ដែលបានដាក់កាលពីថ្ងៃទី០៤ កក្កដា ឆ្នាំ២០២០ មកតុលាការឱ្យបានមុនថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០២១»។

## ២.៣. សិទ្ធិអាទិភាពចំពោះប្រាតិភោគ

អ្នកមានសិទ្ធិលើប្រាតិភោគគឺជាបុគ្គលដែលមានប្រយោជន៍អំពីប្រាតិភោគ។

**ឧទាហរណ៍៖** A បានដាក់ពាក្យសុំឱ្យចេញដីកាសម្រេចរក្សាការពារលើ ដី L របស់B។ក្រោយពីពិនិត្យពាក្យសុំរបស់តុលាការយល់ថា មានមូលហេតុ តាមច្បាប់ក្នុងការរឹបអូសដី L ហេតុនេះបានបង្គាប់ឱ្យ A ដាក់ប្រាតិភោគមក តុលាការដើម្បីទទួលបានដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នលើដី L។

[7] ប័ណ្ណសងតាមបញ្ជា គឺជាប្រភេទមួយនៃឧបករណ៍ដែលអាចជួញដូរបាន ដែលអ្នកចេញសន្យាថាបង់ប្រាក់ទៅតាមចំនួនដែលមានកំណត់នៅក្នុងប័ណ្ណនោះទៅឱ្យបុគ្គលដែលមានឈ្មោះនៅក្នុងប័ណ្ណនោះ។

[8] ក្រមនីតិវិធីរដ្ឋប្បវេណី,លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៧១។

ផ្អែកតាមឧទាហរណ៍ខាងលើ អ្នកដែលមានសិទ្ធិលើប្រាតិភោគ គឺ កូនបំណុល B ព្រោះថា ការដាក់ប្រាតិភោគរបស់ម្ចាស់បំណុល A គឺដើម្បីទទួលបានដីកាសម្រេចរក្សាការពារលើដី L របស់កូនបំណុល ឬ អាចពិចារណាថា A យកប្រាតិភោគមកដាក់តម្កល់ដើម្បីដោះដូរនឹងការ ទទួលបានសិទ្ធិក្នុងការរឹបអូសដី L របស់កូនបំណុល ហេតុនេះនាំឱ្យ កូនបំណុល B មានសិទ្ធិលើប្រាតិភោគជំនួសឱ្យការកម្រិតសិទ្ធិលើដី L ដោយសារការរឹបអូសរបស់ម្ចាស់បំណុល A ។

អ្នកមានសិទ្ធិលើប្រាតិភោគមានសិទ្ធិអាទិភាពទៅលើម្ចាស់បំណុលផ្សេងទៀត ទៅលើការសងចំពោះប្រាក់ ឬឧបករណ៍ដែល អាចជួញដូរបាន ដែលត្រូវបានតម្កល់ជាប្រាតិភោគ ដើម្បីសងសិទ្ធិលើ បំណុលដែលត្រូវបានធានា។

ផ្អែកតាមឧទាហរណ៍ខាងលើ ប្រសិនបើក្រោយមកតុលាការ សម្រេចលុបចោលដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នលើដី L វិញ កូនបំណុល B អាចទាមទារសំណងការខូចខាតពីម្ចាស់បំណុល A បាន។ ក្នុងករណីនេះ ប្រាតិភោគដែល A បានដាក់ ដើម្បីទទួលបានដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន ត្រូវចាត់ទុកថាជាទ្រព្យសម្បត្តិ ទទួលខុសត្រូវរបស់ម្ចាស់បំណុល A ហើយកូនបំណុល B អាចអនុវត្ត ដោយបង្ខំលើប្រាតិភោគនោះនឹងទទួលបានការសងជាអាទិភាព។

ការទទួលបានការសងជាអាទិភាពរបស់ អ្នកមានសិទ្ធិលើប្រាតិភោគ មានន័យថា ក្នុងករណីដែលម្ចាស់បំណុល A មាន ម្ចាស់បំណុលច្រើននាក់ហើយចង់អនុវត្ត សិទ្ធិលើទ្រព្យសម្បត្តិរបស់ A នាំឱ្យ B ដែលជាអ្នកមានសិទ្ធិលើប្រាតិភោគ អាចទទួលបានការសងមុនគេចំពោះទឹកប្រាក់ដែល A បានដាក់ប្រាតិភោគសម្រាប់សំណុំរឿងរក្សាការពាររវាង A និង B ។

## ២.៤. ហេតុដែលនាំអោយរំលត់ប្រាតិភោគ

ប្រាតិភោគដែលបានដាក់អាចត្រូវបានរលត់ក្នុងករណីណាមួយ ដូចខាងក្រោម៖

### ២.៤.១. ហេតុដែលបានកំណត់ឱ្យមានការដាក់ប្រាតិភោគបានរលត់

ប្រសិនបើហេតុដែលបានកំណត់ឱ្យមានការដាក់ប្រាតិភោគ បានរលត់ហេតុដែលនាំឱ្យមានការដាក់ប្រាតិភោគ ត្រូវរលត់អាចជា៖ ករណីប្រាតិភោគលើប្រាក់ប្រដាប់ក្តី ប្រសិនបើដើមចោទ ក្លាយជាមានលំនៅឋាន ឬទីតាំងអាជីវកម្ម ឬបានឈ្នះក្តីទាំងស្រុង។ ករណីការដាក់ប្រាតិភោគដើម្បីទទួលបានការប្រកាសអនុវត្តជាបណ្តោះអាសន្ន ឬរួចផុតពីការអនុវត្តជាបណ្តោះអាសន្ន ប្រសិនបើសាលក្រម ឬសាលដីកានោះបានចូលជា

ស្ថាពរ ឬមាន ការលុបចោលសាលក្រមដោយតុលាការជាន់ខ្ពស់ ហើយសេចក្តីសម្រេចនោះបានចូលជាស្ថាពរជាអាទិ៍។

### ២.៤.២. អ្នកមានសិទ្ធិប្រាតិភោគយល់ព្រមឱ្យលុបចោល

**ឧទាហរណ៍៖** A បានដាក់ប្រាតិភោគ ដើម្បីទទួលបានសាលក្រមដែលភ្ជាប់ នឹងការអនុវត្តជាបណ្តោះ-អាសន្ន ប៉ុន្តែ ក្រោយមក A និង B បាន ព្រមព្រៀងគ្នាអំពីចំនួនទឹកប្រាក់ដែល ត្រូវបង់ក្រៅផ្លូវតុលាការ។ A មានបំណងដកប្រាតិភោគ ហើយ B បានយល់ព្រមលើពាក្យសុំនេះ។

### ២.៤.៣. ការចាត់ទុកថាអ្នកមានសិទ្ធិលើប្រាតិភោគយល់ព្រមលុបចោល

**ឧទាហរណ៍៖** A បានដាក់ប្រាតិភោគ ដើម្បីទទួលបានសាលក្រមដែលភ្ជាប់ នឹងការអនុវត្តជាបណ្តោះអាសន្ន ប៉ុន្តែ ក្រោយមក A និង B បាន ព្រមព្រៀងគ្នាអំពីចំនួនទឹកប្រាក់ដែល ត្រូវបង់ក្រៅផ្លូវតុលាការ។ A មាន ចំណងដកប្រាតិភោគ និងបានដាក់ ពាក្យសុំទៅតុលាការ ប៉ុន្តែមិនមាន ការបញ្ជាក់ពី B ទេ។

ក្នុងករណីនេះ តុលាការនឹងជូនដំណឹង ទៅ B ថា សូមឆ្លើយតបចំពោះការស្នើ សុំរបស់ A អំពីការស្នើសុំលុបចោលនូវ ប្រាតិភោគ ក្នុងអំឡុងពេល 2 សប្តាហ៍ គិតចាប់ពីថ្ងៃទទួលបានការជូនដំណឹង នេះ បើមិនឆ្លើយតប ចាត់ទុកថា B យល់ព្រមចំពោះការស្នើសុំរបស់ A ក្នុង ការស្នើសុំលុបចោលនូវប្រាតិភោគ។

ប្រសិនបើអ្នកដាក់ប្រាតិភោគ អាចបញ្ជាក់ហេតុណាមួយ ខាងលើនេះបាន គឺអាចដាក់ពាក្យសុំទៅតុលាការ ដើម្បីចេញដីកាសម្រេចលុបចោលនូវប្រាតិភោគ។ក្នុងករណីមានពាក្យសុំបែបនេះ តុលាការត្រូវជូនដំណឹងទៅអ្នកមានសិទ្ធិលើប្រាតិភោគអំពីការណ៍នេះ ដើម្បីឆ្លើយតប ឬអនុវត្តសិទ្ធិរបស់ខ្លួន ក្នុងអំឡុងពេលដែលច្បាប់កំណត់។

ដីកាសម្រេចលុបចោលនូវប្រាតិភោគក្នុងចំណុច ក និង ខ អាចប្តឹងជំទាស់បាន។

**ឧទាហរណ៍៖** A បានដាក់ពាក្យស្នើសុំ លុបចោលប្រាតិភោគលើប្រាក់ប្រដាប់ក្តី ដោយមូលហេតុ A មានលំនៅឋាននៅ កម្ពុជា ហើយតុលាការបានចេញដីកា សម្រេចលុបចោលប្រាតិភោគ។ ប៉ុន្តែ B ដែលជាអ្នកមានសិទ្ធិលើប្រាតិភោគ មិន សុខចិត្តនឹងដីកាសម្រេចនេះ ព្រោះយល់ ថា A មិនទាន់មានលំនៅឋាននៅកម្ពុជា ហេតុនេះ B អាចប្តឹងជំទាស់នឹង ដីកាសម្រេចលុបចោលប្រាតិភោគ។

អំឡុងពេលប្តឹងជំទាស់គឺ ០១(មួយ)សប្តាហ៍ គិតចាប់ពីថ្ងៃបានទទួលដំណឹងអំពីដីកាសម្រេចនេះ។

## ២.៥ ដីកាសម្រេចបង្គាប់ឱ្យដាក់ប្រាតិភោគ

នៅក្នុងដីកាសម្រេចបង្គាប់ឱ្យដាក់ប្រាតិភោគ គឺជាវិធានមួយរបស់តុលាការក្នុងការសម្រេច ឱ្យដាក់ឬមិនឱ្យដាក់ប្រាតិភោគបាន។[9]

នៅក្នុងទម្រង់ក្នុងការបង្គាប់ឱ្យដាក់ប្រាតិភោគៈ[10]
អំពីឈ្មោះ និងអាសយដ្ឋានរបស់ភាគី (ម្ចាស់បំណុល និងកូនបំណុល)។ ករណីដែល ម្ចាស់បំណុល មានអ្នកតំណាងដែលច្បាប់បានកំណត់ ។

សំអាងហេតុ ជាហេតុដែលនាំអោយតុលាការក្នុងសម្រេចបង្គាប់អោយដាក់ប្រាតិភោគ។

សេចក្ដីសម្រេចបញ្ចប់ ជាខ្លឹមសារដែលតុលាការចេញក្នុងការបង្គាប់ឱ្យម្ចាស់បំណុល ផ្ញើប្រាក់មកកាន់តុលាការ ហើយប្រាតិភោគនោះសម្រាប់កូនបំណុល ហើយតុលាការនឹងធ្វើការកំណត់អំពីថ្ងៃដែលត្រូវដាក់ប្រាតិភោគជាក់លាក់។ ក្នុងករណីដែលម្ចាស់បំណុលមិនអនុវត្តករណីយកិច្ច តាមការសម្រេចរបស់តុលាការ និងលើកចោលពាក្យសុំ។

[9] ក្រមនីតិវិធីរដ្ឋប្បវេណី,លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៥៤២។

[10] ឧបសម្ព័ន្ធទី២, ទម្រង់គំរូស្ដីពីដីកាសម្រេចបង្គាប់ឱ្យដាក់ប្រាតិភោគ។

# ផ្នែកទី៣៖ ដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្ន

## ៣.១. ទម្រង់នៃដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្ន

ក្នុងការសម្រេចសេចក្ដីរបស់តុលាការ គឺផ្អែកលើឆន្ទានុសិទ្ធិរបស់តុលាការដែលមានសមត្ថកិច្ច ដែលកម្មវត្ថុនៃវិវាទស្ថិតនៅ ហើយការសម្រេច អោយភាគីណាមួយក្នុងការឈ្នះក្ដី ដោយផ្អែកលើអង្គហេតុ និង អង្គច្បាប់ ហើយភ្ជាប់ជាមួយភស្តុតាងក្នុងការបញ្ជាក់ អំពីគោលបំណងដែលបានធ្វើការស្នើសុំអោយតុលាការចេញដីកាសម្រេចនៅក្នុង នោះតុលាការនឹងធ្វើការត្រួតពិនិត្យថា៖

- តើបានរៀបចំលក្ខខណ្ឌបណ្ដឹងហើយឬនៅ?
- តើបានសរសេរអំពីចំណុចដែលត្រូវសរសេរនៅក្នុងពាក្យសុំទេ?
- តើមានសេចក្ដីបញ្ជាក់ដំបូងអំពីសិទ្ធិ ឬទំនាក់ទំនងគតិយុត្តដែលនឹងត្រូវបានរក្សាការពារឬទេ?
- តើមានសេចក្ដីបញ្ជាក់ដំបូងអំពីភាពចាំបាច់នៃរក្សាការពារឬទេ?

ដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្ន គឺខុសគ្នាជាមួយការរឹបអូសជាបណ្ដោះអាសន្ន ហើយនៅក្នុងការចាត់ចែងជាបណ្ដោះអាសន្ន មិនមានបញ្ញត្តិដែលធ្វើការបញ្ជាក់អំពីការដាក់ប្រាក់រំដោះដូចការរឹបអូសជាបណ្ដោះអាសន្ននោះទេ។[11] ប្រភេទនៃដីកាសម្រេចទាំងពីរនេះមានគោលបំណងចុងក្រោយខុសគ្នា ប្រភេទដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន គឺគោលបំណងសងជាប្រាក់ រីឯប្រភេទដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្ន គឺគ្មានគោលបំណងអោយសងជាប្រាក់នោះទេ ជាគោលការណ៍ទូទៅប្រភេទនេះគឺមានគោលបំណងក្នុងការថែរក្សាវត្ថុដែលជាកម្មវត្ថុនៃវិវាទនោះអោយស្ថិតនៅក្នុងស្ថានភាពដើម ដើម្បីងាយស្រួលក្នុងការអនុវត្តនៅពេលដីកាសម្រេចនេះចូលជាស្ថាពរ ដើម្បីធ្វើការរក្សាសិទ្ធិដែលនឹងត្រូវបានរក្សាការពារ ហើយជាសិទ្ធិលើវត្ថុដែលកំពុងមានវិវាទ និងមានគោលបំណងឱ្យធ្វើសកម្មភាពជាកំណត់មួយចំពោះវត្ថុនៃវិវាទ។

បញ្ញត្តិដែលទាក់ទងទៅនឹង តុលាការមានសមត្ថកិច្ច[12] ការដាក់ពាក្យសុំ[13] វិធីក្នុងការវិនិច្ឆ័យ និង ការចេញដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្ន វាមានលក្ខណៈដូចគ្នាទៅនឹងការរឹបអូសជាបណ្ដោះអាសន្នដែរ លើកលែងតែមានបញ្ញត្តិពិសេស។

---

[11] ក្រមនីតិវិធីរដ្ឋប្បវេណី,លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៥៤៧។

[12] ក្រមនីតិវិធីរដ្ឋប្បវេណី,លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៥៣២។

[13] ក្រមនីតិវិធីរដ្ឋប្បវេណី,លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៥៣៤។

ក្នុងការចាត់ចែងជាបណ្ដោះអាសន្នចំពោះវត្ថុដែលជាកម្មវត្ថុនៃវិវាទ ក្រៅពីតុលាការដែលមានសមត្ថកិច្ចលើអង្គសេចក្ដីសាលាដំបូងដែលមានសមត្ថកិច្ចលើទីកន្លែងដែលវត្ថុដែលជាកម្មវត្ថុនោះស្ថិតនៅ។[14] ចំពោះទីកន្លែងនៃសិទ្ធិលើបំណុល និងសិទ្ធិលើទ្រព្យសម្បត្តិផ្សេងទៀត ប្រភេទនៃសំណុំរឿងរក្សាការពារ ត្រូវស្ថិតក្រោមសមត្ថកិច្ចផ្ដាច់មុខរបស់តុលាការដែលមានសមត្ថកិច្ចលើអង្គសេចក្ដី ឬសាលាដំបូងដែលមានសមត្ថកិច្ច លើទីកន្លែងដែលនឹងត្រូវរឹបអូសជាបណ្ដោះអាសន្ន ឬវត្ថុដែលជាកម្មវត្ថុស្ថិតនៅ។[15]

**ឧទាហរណ៍៖** ក្នុងករណីដែលកូនបំណុលមានអាសយដ្ឋានស្ថិតនៅភ្នំពេញ បណ្ដឹងអង្គសេចក្ដីអាចយកតុលាការដែលមានសមត្ថកិច្ចតាមអាសយដ្ឋានរបស់ចុងចម្លើយ គឺសាលាដំបូងភ្នំពេញ មកធ្វើជាតុលាការដែលមានសមត្ថកិច្ចចំពោះសំណុំរឿងរក្សាការពារបានផងដែរ។

តុលាការ គឺមិនអាចចេញដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្នបានឡើយបើមិនឆ្លងកាត់តាមកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ ឬតាមកាលបរិច្ឆេទនៃការសួរដែលកូនបំណុលអាចចូលរួមបាន។[16] ទោះជាមានមូលដ្ឋាន ការចាត់ចែងជាបណ្ដោះអាសន្ន ត្រូវធ្វើជាសម្ងាត់ដូចករណីនៃការរឹបអូសជាបណ្ដោះអាសន្នក៏ដោយ នៅក្នុងការចាត់ចែងជាបណ្ដោះអាសន្ន ផលប្រយោជន៍របស់ម្ចាស់បំណុលនៅតែត្រូវបានការពារទោះជាគ្មានការវិនិច្ឆ័យជាសម្ងាត់ដូចករណីរឹបអូសជាបណ្ដោះអាសន្នក៏ដោយ ក្នុងការចាត់ចែងជាបណ្ដោះអាសន្នចំពោះវត្ថុដែលជាកម្មវត្ថុនៃវិវាទ ផលប្រយោជន៍របស់ម្ចាស់បំណុល នៅតែត្រូវបានការពារទោះជាគ្មានការវិនិច្ឆ័យដោយសម្ងាត់ក៏ដោយ ហើយម្យ៉ាងទៀត បើនីតិវិធីធ្វើឡើងដោយសម្ងាត់ នោះនឹងនាំមានការប៉ះពាល់ធ្ងន់ធ្ងរដល់កូនបំណុល។ ហេតុនេះបានជាច្បាប់ធ្វើការផ្ដល់ឱកាសឱ្យកូនបំណុល ក្នុងការការពារខ្លួន នៅក្នុងការចាត់ចែងជាបណ្ដោះអាសន្នប្រភេទនេះ ក៏ប៉ុន្តែ ប្រសិនបើមានស្ថានភាពពិសេសដែលនាំឱ្យពុំអាចសម្រេចគោលបំណងនៃពាក្យសុំឱ្យចេញដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្ន ដោយសារឆ្លងតាមកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់។ ក្នុងទម្រង់នៃដីកាសម្រេចចាត់ចែងគឺជាការបង្ហាញអំពីគោលបំណងនៃការដាក់ពាក្យសុំរក្សាការពារឱ្យសមស្របតាមការកំណត់របស់ច្បាប់។

## ៣.២. ខ្លឹមសារនៃនៃដីកាសម្រេចដែលអ្នកដាក់ពាក្យសុំធ្វើការទាមទារ

នៅក្នុងខ្លឹមសារនៃអ្នកដាក់ពាក្យសុំធ្វើការទាមទារ តើអ្នកដាក់ពាក្យសុំនោះមានគោលបំណងបែបណាត្រូវធ្វើការបញ្ជាក់អោយបានច្បាស់លាស់អំពីគោលបំណងដែលជាខ្លឹមសារក្នុងការទាមទារ ហើយនៅក្នុងការដាក់

[14] ក្រមនីតិវិធីរដ្ឋប្បវេណី,លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៥៤០។

[15] ក្រមនីតិវិធីរដ្ឋប្បវេណី,លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៥៤០។

[16] ក្រមនីតិវិធីរដ្ឋប្បវេណី,លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៥៤៨។

ពាក្យសុំរក្សាការពារគួរតម្បីធ្វើការបញ្ជាក់អោយបានច្បាស់លាស់អំពីអំពីខ្លឹមសារនៃការទាមទារ។តើអ្នកដាក់ពាក្យសុំនោះចង់បានអ្វី? គួរតម្បីធ្វើការបញ្ជាក់អោយបានច្បាស់លាស់ ដោយសាររក្សាការពារប្រភេទទី២នេះ គឺមានគ្មានគោលបំណងអោយសងជាប្រាក់នោះទេ គឺគោលបំណងអោយធ្វើការប្រគល់វត្ថុនោះដោយស្ថិតនៅក្នុងស្ថានភាពដើម ដើម្បីងាយស្រួលក្នុងការអនុវត្តបង្ខំនាពេលអនាគតហើយខ្លឹមសារនៃប្រភេទរក្សាការពារនេះមាន ២ គឺ ការហាមឃាត់ការចាត់ចែង និង ការហាមឃាត់ការផ្ទេរការកាន់កាប់។

ជាគោលការណ៍ទូទៅសម្រាប់អ្នកដែលជាអ្នកដាក់ពាក្យសុំធ្វើការទាមទារ គឺធ្វើការ«ហាមឃាត់ក្នុងការចាត់ចែង» គឺកូនបំណុលត្រូវបានកម្រិតសិទ្ធិក្នុងការចាត់ចែងដូចជា ការលក់ ដូរធ្វើប្រទានកម្ម ជាអាទិ៍ ឬដាក់ប្រាតិភោគដូចជា ហ៊ីប៉ូតែក ជាអាទិ៍ និងការចាត់ចែងផ្សេងទៀត ហេតុនេះការចាត់ចែងរបស់កូនបំណុលដែលផ្ទុយនឹងការហាមឃាត់នេះ មិនអាចតតាំងនឹងម្ចាស់បំណុលនៃការចាត់ចែងជាបណ្តោះអាសន្នបានឡើយ ពោលគឺ តតិយជនដែលបានទទួលសិទ្ធិពីការចាត់ចែងនេះ មិនអាចយកលទ្ធកម្មនេះទៅតតាំងជាមួយនឹងម្ចាស់បំណុលបានឡើយ ហើយលទ្ធកម្មនេះនឹងត្រូវចាត់ទុកជាមោឃៈ នៅពេលម្ចាស់បំណុលឈ្នះបណ្តឹងអង្គសេចក្តីជាស្ថាពរ និងធ្វើការដាក់ពាក្យសុំលុបការចុះបញ្ជីអំពីការផ្ទេរកម្មសិទ្ធិ ផ្អែកលើសេចក្តីសម្រេចអង្គសេចក្តីដែលចូលជាស្ថាពរ[17]។

**ឧទាហរណ៍៖** លោក«ក»បានជួលផ្ទះ (ភតិសន្យា )មួយខ្នងទៅអោយ កញ្ញា «ខ» ដោយនៅក្នុងខ្លឹមសារនៅក្នុងកិច្ចសន្យាបានធ្វើការកំណត់ អំពីការបង់ថ្លៃឈ្នួលផ្ទះ និងបានធ្វើការកំណត់ថាក្នុងករណីដែលភាគីម្ខាងមិនអនុវត្តកាតព្វកិច្ចតាមខ្លឹមសារនៃកិច្ចសន្យា «គឺអាចធ្វើការរំលាយភតិសន្យា» ដោយធ្វើការប្រគល់វត្ថុត្រឡប់មកស្ថានភាពដើមវិញ។ ប៉ុន្តែក្នុងអំឡុងពេលក្នុងការអនុវត្ត កញ្ញា«ខ»មិនធ្វើការអនុវត្តតាមខ្លឹមសារនៃកិច្ចសន្យា គឺមិនបានបង់ថ្លៃឈ្នួល តាមខ្លឹមសារនៃកិច្ចសន្យា។ មួយសប្តាហ៍ក្រោយមក លោក«ក»បានធ្វើការដាស់តឿនឱ្យកញ្ញា«ខ» បង់ប្រាក់ឈ្នួលដែលជាតម្លៃនៃថ្លៃជួល និងជាមួយនឹងការបង្ហាញឆន្ទៈរំលាយកិច្ចសន្យា ប្រសិនបើកញ្ញា«ខ»នៅតែមិនធ្វើការបង់ប្រាក់ ក្នុងអំឡុងពេលដែលបានធ្វើការដាស់តឿន។ ពីរសប្តាហ៍ក្រោយមក លោក«ក»បានធ្វើការជូនដំណឹងទៅអោយកញ្ញា«ខ» ប៉ុន្តែកញ្ញា «ខ» មិនធ្វើការអនុវត្ត ដោយមិនប្រគល់ផ្ទះមកវិញ។ លោក«ក»បានប្តឹងទៅកាន់តុលាការ ដោយទាមទារឱ្យរើចេញ ដោយប្រគល់អាគារដែលជាកម្មវត្ថុនៃវិវាទត្រឡប់មកវិញ។ ក្នុងករណីនេះ លោក «ក»បានឈ្នះក្តី ក៏ប៉ុន្តែ មុនពេលដែល លោក «ក» ដាក់ពាក្យបណ្តឹង លោក«គ» បានមកចូលរស់នៅក្នុងផ្ទះនោះដោយគ្មានការអនុញ្ញាត ដោយបានធ្វើការអះអាងថាគាត់បានជួលពី កញ្ញា«ខ»។ ហើយកញ្ញា «ខ»មិនដឹងទៅណាបាត់ទេ ដោយបានខ្លួនបាត់ហើយ។

[17] ក្រមនីតិវិធីរដ្ឋប្បវេណី,លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៤៣១។

នៅក្នុងការនេះ លោក«ក» ត្រូវដាក់ពាក្យសុំរក្សាការពារ ហើយគួរធ្វើការបញ្ជាក់អំពីគោលបំណងអោយបានច្បាស់លាស់ ថាតើលោក «ក» ចង់បានអ្វី? ចង់បានប្រាក់ ឬក៏ចង់អោយធ្វើការប្រគល់វត្ថុដែលជាកម្មវត្ថុនៃវិវាទនោះអោយស្ថិតនៅក្នុងស្ថានភាពដើម? បើ លោក«ក» ចង់បានប្រាក់ គួរគប្បីធ្វើការដាក់រក្សាការពារប្រភេទការរឹបអូសជាបណ្ដោះអាសន្ន ប៉ុន្តែក្នុងករណីដែល លោក«ក» ចង់អោយប្រគល់វត្ថុដោយស្ថិតនៅក្នុងស្ថានភាពដើមវិញ គួរគប្បីដាក់រក្សាការពារប្រភេទទី២ ការចាត់ចែងជាបណ្ដោះអាសន្នចំពោះវត្ថុដែលជាកម្មវត្ថុនៃវិវាទ។

លោក «ក» ត្រូវដាក់ពាក្យសុំដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្នចំពោះវត្ថុដែលជាកម្មវត្ថុនៃវិវាទ ហើយខ្លឹមសារនៃដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្ន«ហាមឃាត់ការចាត់ចែង» ។

ករណីខ្លឹមសារនៃដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្ន«ហាមឃាត់ការផ្ទេរការកាន់កាប់» ក្នុងករណីអាជ្ញាសាលាបានចុះមកអនុវត្ត និងប្រកាសជាសាធារណៈអំពីការហាមឃាត់ការផ្ទេរការកាន់កាប់ បន្ទាប់មកមានការផ្ទេរការកាន់កាប់ផ្ទុយពីការហាមឃាត់នេះ ការផ្ទេរការកាន់កាប់នេះមិនអាចតតាំងនឹងម្ចាស់បំណុលនៃការចាត់ចែងជាបណ្ដោះអាសន្នបានឡើយ ហេតុនេះប្រសិនបើម្ចាស់បំណុលទទួលបានលិខិតអនុវត្តដែលមានអនុភាពអនុវត្ត(សាលក្រមស្ថាពរ) គឺអាចអនុវត្តដោយបង្ខំឱ្យប្រគល់អចលនវត្ថុទាំងនេះបាន ទោះបីអ្នកកាន់កាប់ជាក់ស្តែងនោះជាតតិយជនក៏ដោយ[18]។

**ឧទាហរណ៍៖** លោក «ក» បានឱ្យ លោក«ខ» ជួលដីដែលខ្លួនមានកម្មសិទ្ធិ ប៉ុន្តែ លោក «ក»បានរំលាយភតិសន្យា ដោយសារតែ លោក «ខ»មិនបានបង់ថ្លៃឈ្នួលដែលជួលដី។ ទោះបីជាភតិសន្យាត្រូវបានរំលាយហើយក៏ដោយក្តី ក៏លោក«ខ»មិនប្រគល់ដីទៅឱ្យលោក «ក» ដោយស្ម័គ្រចិត្តនោះទេ។ ក្នុងករណីនេះ ដើម្បីទទួលបានដីត្រឡប់មកវិញ លោក«ក» ត្រូវដាក់ពាក្យបណ្ដឹងទាមទារឱ្យប្រគល់ដី ដោយយក លោក«ខ»ជាចុងចម្លើយ ហើយនៅពេលទទួលបានសាលក្រមឈ្នះក្តី លោក«ក»ត្រូវអនុវត្តដោយបង្ខំឱ្យប្រគល់អចលនវត្ថុ។

ប្រសិនបើ លោក«ក»ដាក់ពាក្យបណ្ដឹងយក លោក«ខ»ជាចុងចម្លើយ ដូចដែលបានរៀបរាប់នៅលើនេះ ទោះបីជា លោក«ខ»បានផ្ទេរការកាន់កាប់ដីទៅឱ្យ លោក«គ»ដែលជាតតិយជនក្រោយពេលដែលបានដាក់ពាក្យបណ្ដឹងក៏ដោយ ក៏មិនមានឥទ្ធិពលទៅលើបណ្ដឹងដែរ[19]។ប្រសិនបើ លោក«ក»បន្តបណ្ដឹងដោយយក លោក «ខ» ជាចុងចម្លើយ ហើយទទួលបានសាលក្រមឈ្នះក្តីចំពោះ លោក«ខ» នោះលោក«ក»នឹងទទួលបាននូវការផ្តល់ជារូបមន្តអនុវត្តពិសេស(រូបមន្តអនុវត្តបន្ត)ហើយអាចដាក់ពាក្យសុំអនុវត្តដោយបង្ខំ ឱ្យប្រគល់អចលនវត្ថុចំពោះលោក «គ»បាន[20]។ប៉ុន្តែ ករណីដែលលោក«ខ»ចេញដីមួយរយៈដោយបានបន្សល់ទុកនូវចលនវត្ថុដូចជាគ្រឿង-

[18] ក្រមនីតិវិធីរដ្ឋប្បវេណី,លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៥៧១។

[19] ក្រមនីតិវិធីរដ្ឋប្បវេណី,លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៨៨។

[20] ក្រមនីតិវិធីរដ្ឋប្បវេណី,លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា១៩៨, និង មាត្រា៣៥១។

សង្ហារឹមជាអាទិ៍ ហើយក្នុងអំឡុងពេលនោះ លោក«គ»បានកាន់កាប់ដោយខុសច្បាប់លើដីនោះ នាំឱ្យលោក«ក» ទោះបីជាទទួលបានសាលក្រមឈ្នះក្តីចំពោះ លោក«ខ»ក៏ដោយ ក៏មិនអាចអនុវត្តដោយបង្ខំឱ្យប្រគល់អចលនវត្ថុចំពោះ លោក«គ»បានឡើយ។ ព្រោះលោក«គ»មិនមែនបន្តកាន់កាប់ពីលោក«ខ»នោះទេ ដូច្នេះករណីនេះមិនត្រូវនឹងបុគ្គលដែលទទួលបានបន្តសិទ្ធិ ឬកាតព្វកិច្ច[21] នោះទេ ហើយមិនអាចបញ្ចូលនៅក្នុងទំហំនៃបុគ្គលដែលអាចអនុវត្តដោយបង្ខំបានឡើយ។

វិធីដែលជៀសផុតនូវស្ថានភាពខាងលើ លោក«ក»ត្រូវដាក់ពាក្យសមចាត់ចែងជាបណ្តោះអាសន្នដែលហាមឃាត់ការផ្ទេរការកាន់កាប់ ដើម្បីរក្សាការពារសិទ្ធិទាមទារឱ្យប្រគល់ដីចំពោះលោក«ខ»នៅពេលដែលការចាត់ចែងជាបណ្តោះអាសន្នដែលហាមឃាត់ការផ្ទេរការកាន់កាប់ត្រូវបានអនុវត្ត ហើយករណីដែល លោក«គ» បានកាន់កាប់ដីទាំងដឹងថាមានការអនុវត្តនោះ នាំឱ្យលោក«ក»អាចដាក់ពាក្យសុំអនុវត្តដោយបង្ខំឱ្យប្រគល់អចលនវត្ថុចំពោះលោក«គ» ក្រោយពេលទទួលបាននូវការផ្តល់រូបមន្តអនុវត្តពិសេស(រូបមន្តអនុវត្តបន្ត)ដោយផ្អែកតាមសាលក្រមឈ្នះក្តីលោក«ខ»បាន។

ម្យ៉ាងទៀត ចំពោះវិធីអនុវត្តការចាត់ចែងជាបណ្តោះអាសន្នដែលហាមឃាត់ការផ្ទេរការកាន់កាប់ មានវិធីដែលអនុញ្ញាតឱ្យកូនបំណុលប្រើប្រាស់វត្ថុដែលជាកម្មវត្ថុនៃវិវាទ និងវិធីអជ្ញាសាលាថែរក្សាគ្រប់គ្រងវត្ថុដែលជាកម្មវត្ថុនៃវិវាទដោយខ្លួនឯង។

ដោយផ្អែកតាមមាត្រា១៣១ នៃក្រមនីតិវិធីរដ្ឋប្បវេណី ពាក្យ«សេចក្តីបញ្ជាក់ដំបូង»សំដៅ ភស្តុតាងដែលអាចពិនិត្យភ្លាមៗបាន។សេចក្តីបញ្ជាក់ដំបូងជារបៀបទទួលស្គាល់អង្គហេតុ ដោយប្រើភស្តុតាងដែលអាចពិនិត្យបានភ្លាមៗ ហេតុនេះភស្តុតាងដែលប្រើពេលច្រើន ដូចជាលទ្ធផលកោសលវិច័យឬការសាកសួរសាក្សីមិនត្រូវបានទទួលស្គាល់ទេ។ភស្តុតាងដែលអាចពិនិត្យបានភ្លាមៗ សំដៅ«ភស្តុតាងជាឯកសារ»។

ដោយផ្អែកតាមកថាខណ្ឌទី៣ មាត្រា៥៤១ នៃក្រមនីតិវិធីរដ្ឋប្បវេណី នៅក្នុងពាក្យសុំឱ្យចេញដីកាសម្រេចរក្សាការពារ ចាំបាច់ត្រូវធ្វើសេចក្តីបញ្ជាក់ដំបូងអំពីសិទ្ធិ ឬទំនាក់ទំនងគតិយុត្តដែលនឹងត្រូវបានរក្សាការពារ និងភាពចាំបាច់នៃរក្សាការពារ។ សេចក្តីបញ្ជាក់ដំបូង គឺជាភស្តុតាងដែលអាចពិនិត្យបានភ្លាមៗ ដូចជាលិខិតកិច្ចសន្យា វិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុជាអាទិ៍ ហេតុនេះ ចំពោះភស្តុតាងដែលត្រូវការពេលវេលាដើម្បីធ្វើនីតិវិធីដូចជាការស្រាវជ្រាវ ការបង្គាប់ឱ្យដាក់ឯកសារ ការសាកសួរសាក្សី ជាអាទិ៍ មិនមែនជាសេចក្តី-បញ្ជាក់ដំបូងនោះទេ។នៅក្នុងនីតិវិធីធម្មតា ដើម្បីឱ្យតុលាការជឿជាក់ចំពោះការអះអាងអង្គហេតុណាមួយ ភាគីត្រូវធ្វើការបញ្ជាក់អង្គហេតុនោះ ប៉ុន្តែនៅក្នុងនីតិវិធីចាត់ចែងរក្សាការពារ ជាករណីលើកលែង តុលាការអាចចេញដីកា

[21] ក្រមនីតិវិធីរដ្ឋប្បវេណី,លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា១៩៨ និង មាត្រា៣៥១។

សម្រេចរក្សាការពារ ត្រឹមតែមើលទៅលើការធ្វើសេចក្តីបញ្ជាក់ដំបូងរបស់អ្នកដាក់ពាក្យសុំ ចំពោះអង្គហេតុស្តីពីសិទ្ធិ ឬទំនាក់ទំនងគតិយុត្តដែលត្រូវនឹងរក្សាការពារ និងភាពចាំបាច់នៃរក្សាការពារតែប៉ុណ្ណោះ។ ការបញ្ជាក់ និងសេចក្តីបញ្ជាក់ដំបូង មានភាពខុសគ្នាចំពោះកម្រិតនៃការជឿជាក់របស់ចៅក្រម ការបញ្ជាក់ដោយភស្តុតាង គឺជាស្ថានភាពដែលចៅក្រមមានជំនឿជឿជាក់ច្បាស់ក្នុងការទទួលស្គាល់ឬមិនទទួលស្គាល់អង្គហេតុ។ ចំណែកឯសេចក្តីបញ្ជាក់ដំបូងជាស្ថានភាពដែលចៅក្រមទទួលបាននូវជំនឿជឿជាក់ថា ប្រហែលជាការពិត ក៏ចៅក្រមអាចចេញដីកាសម្រេចរក្សាការពារតាមពាក្យសុំផងដែរ។

ចំពោះសេចក្តីសម្រេចបញ្ជាប់នៅក្នុងដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្ន ទៅតាមភាគីដែលបានធ្វើការស្នើសុំឱ្យតុលាការចេញឱ្យស្របតាមវិធីអនុវត្ត ដែលរួមមាន ការហាមឃាត់ការផ្ទេរកាប់ និងការហាមឃាត់ការចាត់ចែង។

ចំពោះសេចក្តីសម្រេចបញ្ជាប់នៅក្នុង ដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្នដែលហាមឃាត់ការចាត់ចែង ត្រូវធ្វើការក្នុងការបញ្ជាក់៖

ហាមឃាត់មិនឱ្យកូនបំណុលធ្វើអនុប្បទាននូវកម្មសិទ្ធិ ឬបង្កើតសិទ្ធិប្រាតិភោគ(សិទ្ធិបញ្ចាំ ឬហ៊ីប៉ូតែកជាអាទិ៍) ឬសិទ្ធិជួល ឬការចាត់ចែងផ្សេងទៀត ចំពោះអចលនវត្ថុ ដូចមានសរសេរនៅក្នុងបញ្ជីឧបសម្ព័ន្ធអំពីវត្ថុជាបណ្តោះអាសន្ន។

ចំពោះសេចក្តីសម្រេចបញ្ជាប់នៅក្នុងដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្នដែលហាមឃាត់ផ្ទេរការកាន់កាប់ ត្រូវធ្វើការសរសេរ ដោយស្របតាមវិធីក្នុងការអនុវត្តនោះ៖

វិធីដែលអនុញ្ញាតឱ្យកូនបំណុលប្រើប្រាស់វត្ថុដែលជាកម្មវត្ថុនៃវិវាទ

ហាមឃាត់មិនឱ្យកូនបំណុលផ្ទេរការកាន់កាប់ចំពោះអចលនវត្ថុដែលបានសរសេរនៅក្នុងបញ្ជីឧបសម្ព័ន្ធអំពីវត្ថុជាបណ្តោះអាសន្ន ។

បង្គាប់ឱ្យកូនបំណុលត្រូវប្រគល់អចលនវត្ថុដែលបានសរសេរនៅក្នុងបញ្ជី ឧបសម្ព័ន្ធអំពីវត្ថុទៅឱ្យអាជ្ញា-សាលា។ អាជ្ញាសាលា ត្រូវប្រកាសជាសារធារណៈថា កូនបំណុលត្រូវបានហាមឃាត់ការផ្ទេរការកាន់កាប់ចំពោះអចលនវត្ថុដូចមានសរសេរក្នុងបញ្ជីឧបសម្ព័ន្ធអំពីវត្ថុ ដោយលិខិតបិទប្រកាសជាសាធារណៈតាមរបៀបពុំងាយបកចេញ ឬតាមរបៀបសមរម្យផ្សេងទៀត។

បង្គាប់ឱ្យអាជ្ញាសាលាត្រូវអនុញ្ញាតឱ្យកូនបំណុលប្រើប្រាស់អចលវត្ថុដូចមានសរសេរក្នុងបញ្ជីឧបសម្ព័ន្ធអំពីវត្ថុ។ វិធីដែលអាជ្ញាសាលាថែរក្សាគ្រប់គ្រងវត្ថុដែលជាកម្មវត្ថុនៃវិវាទ ដោយខ្លួនឯងហាមឃាត់មិនឱ្យកូនបំណុលផ្ទេរការកាន់កាប់ចំពោះអចលនវត្ថុដែលបានសរសេរនៅក្នុងបញ្ជីឧបសម្ព័ន្ធអំពីវត្ថុ។

បង្គាប់ឱ្យកូនបំណុលត្រូវប្រគល់អចលនវត្ថុដែលបានសរសេរនៅក្នុងបញ្ជីឧបសម្ព័ន្ធអំពីវត្ថុទៅឱ្យអាជ្ញាសាលា។

បង្គាប់ឱ្យអាជ្ញាសាលាថែរក្សាគ្រប់គ្រងអចលវត្ថុដែលបានសរសេរនៅក្នុងបញ្ជីឧបសម្ព័ន្ធអំពីវត្ថុ។ អាជ្ញាសាលា ត្រូវប្រកាសជាសាធារណៈថា កូនបំណុលត្រូវបានហាមឃាត់ការផ្ទេរការកាន់កាប់ ចំពោះអចលនវត្ថុដូចមានសរសេរនៅក្នុងបញ្ជីឧបសម្ព័ន្ធអំពីវត្ថុ ហើយអាជ្ញាសាលាថែរក្សាគ្រប់គ្រង ចំពោះអចលនវត្ថុដូចមានសរសេរក្នុងបញ្ជីឧបសម្ព័ន្ធអំពីវត្ថុ ដោយលិខិតបិទប្រកាសជាសាធារណៈ តាមរបៀបដែលពុំងាយបកចេញ ឬតាមរបៀបសមរម្យផ្សេងទៀត។

នៅក្នុងខ្លឹមសារនៃសេចក្តីសម្រេចបញ្ចប់អំពីការចាត់ចែងជាបណ្តោះអាសន្នដែលហាមឃាត់ការផ្ទេរការកាន់កាប់ នៅសាលាដំបូងរាជធានីភ្នំពេញ៖

- **ខ្លឹមសារនៃប្រយោគ**

អត្តសញ្ញាណរបស់ភាគី ដូចគ្នាទៅនឹងការសរសេរនៅក្នុងបញ្ជីសារពើភណ្ឌស្តីពីភាគី«សង្ខេប»

ស្តីអំពី«លេខសំណុំរឿង និងឈ្មោះសំណុំរឿង» រវាងគូភាគីខាងលើ តុលាការ ទទួលស្គាល់ ពាក្យសុំរបស់ម្ចាស់បំណុលមានភាពត្រឹមត្រូវ ដោយបង្គាប់ឱ្យម្ចាស់បំណុលដាក់ប្រាតិភោគនូវទឹកប្រាក់ចំនួន......ដុល្លារ និងធ្វើការសម្រេចដូចតទៅ៖

- **ទម្រង់ដែលស្តីអំពីការប្រើប្រាស់របស់កូនបំណុល**

កូនបំណុលមិនត្រូវផ្ទេរការកាន់កាប់លើវត្ថុដែលបានសរសេរក្នុងបញ្ជីសារពើភណ្ឌស្តីពីវត្ថុសង្ខេបឱ្យទៅតតិយជន ឬផ្លាស់ប្តូរឈ្មោះក្នុងការកាន់កាប់ទេ។

កូនបំណុលត្រូវតែលះបង់ការកាន់កាប់នៃវត្ថុខាងលើ ហើយប្រគល់វត្ថុនេះឱ្យទៅអាជ្ញាសាលា។

អាជ្ញាសាលាត្រូវតែថែរក្សាគ្រប់គ្រង់វត្ថុខាងលើ។

អាជ្ញាសាលាត្រូវតែអនុញ្ញាតឱ្យកូនបំណុលប្រើប្រាស់វត្ថុខាងលើទេ។

អាជ្ញាសាលាត្រូវតែប្រកាសជាសាធារណៈអំពី ការហាមឃាត់កូនបំណុលមិនឱ្យផ្ទេរការកាន់កាប់ ឬផ្លាស់ប្តូរឈ្មោះក្នុងការកាន់កាប់លើវត្ថុខាងលើ និង អំពីការដែលអាជ្ញាសាលាកំពុងគ្រប់គ្រងលើវត្ថុខាងលើ។

- **ទម្រង់ស្តីពីការគ្រប់គ្រងរបស់អាជ្ញាសាលា**

កូនបំណុលមិនត្រូវផ្ទេរការកាន់កាប់លើវត្ថុដែលបានសរសេរក្នុងបញ្ជីសារពើភណ្ឌស្តីពីវត្ថុសង្ខេបឱ្យតតិយជន ឬផ្លាស់ប្តូរឈ្មោះក្នុងការកាន់កាប់ទេ។

កូនបំណុលត្រូវតែលះបង់ការកាន់កាប់នៃវត្ថុខាងលើ ហើយប្រគល់វត្ថុនេះ ឱ្យទៅអាជ្ញាសាលា។

អាជ្ញាសាលាត្រូវតែថែរក្សាគ្រប់គ្រងវត្ថុខាងលើ ។

អាជ្ញាសាលាត្រូវតែប្រកាសជាសាធារណៈអំពី ការហាមឃាត់កូនបំណុលមិនឱ្យផ្ទេរការកាន់កាប់ ឬផ្លាស់ប្តូរឈ្មោះក្នុងការកាន់កាប់លើវត្ថុខាងលើ និងអំពីការដែលអាជ្ញាសាលាកំពុងគ្រប់គ្រងលើវត្ថុខាងលើ។

- **ទម្រង់ដែលស្តីពីការប្រើប្រាស់របស់ម្ចាស់បំណុល**

កូនបំណុលមិនត្រូវផ្ទេរការកាន់កាប់លើវត្ថុដែលបានសរសេរក្នុងបញ្ជីសារពើភណ្ឌស្តីពីវត្ថុសង្វេបឱ្យតតិយជន ឬផ្លាស់ប្តូរឈ្មោះក្នុងការកាន់កាប់ទេ។

កូនបំណុលត្រូវតែលះបង់ការកាន់កាប់នៃវត្ថុខាងលើ ហើយប្រគល់វត្ថុនេះឱ្យទៅអាជ្ញាសាលា។

អាជ្ញាសាលាត្រូវតែថែរក្សាគ្រប់គ្រងវត្ថុខាងលើ។

អាជ្ញាសាលាត្រូវតែអនុញ្ញាតឱ្យម្ចាស់បំណុលប្រើប្រាស់វត្ថុខាងលើ។

អាជ្ញាសាលាត្រូវតែប្រកាសជាសាធារណៈអំពី ការហាមឃាត់កូនបំណុលមិនឱ្យផ្ទេរការកាន់កាប់ ឬផ្លាស់ប្តូរឈ្មោះ ក្នុងការកាន់កាប់លើវត្ថុខាងលើ និង អំពីការដែលអាជ្ញាសាលាកំពុងគ្រប់គ្រងលើវត្ថុខាងលើ។

# ផ្នែកទី៤៖ ការធ្វើឧបាស្រ័យចំពោះដីកាសម្រេចរក្សាការពារ

## ៤.១. ពាក្យសុំតវ៉ាចំពោះដីកាសម្រេចរក្សាការពារ

ការតវ៉ាចំពោះការរក្សាការពារ គឺជាវិធីនៃការធ្វើឧបាស្រ័យចំពោះដីកាសម្រេចរក្សាការពារ។ ទោះជាយ៉ាងណាមិញ ការធ្វើឧបាស្រ័យចំពោះដីកាសម្រេចលើកចោលពាក្យសុំឱ្យចេញដីកាសម្រេចរក្សាការពារ ត្រូវធ្វើឡើងដោយបណ្តឹងជំទាស់[22]។

ហើយនីតិវិធីដែលទាមទារឱ្យលុបចោលនូវការបង្គាប់ឱ្យរក្សាការពារ ដោយផ្អែកលើមូលហេតុនៃនត្ថិភាពនូវលក្ខខណ្ឌក្នុងការចេញការបង្គាប់ឱ្យរក្សាការពារជាមូលហេតុ។

### ៤.១.១. ពាក្យសុំតវ៉ាចំពោះការរក្សាការពារ

ការដាក់ពាក្យសុំតវ៉ា គឺជាឱកាសដែលផ្តល់ឱ្យកូនបំណុលដែលពុំមានឱកាសចូលរួមក្នុងនិតិវិធីជាមុនក្នុងការសុំឱ្យមានការវិនិច្ឆ័យអំពីភាពត្រឹមត្រូវ ឬមិនត្រឹមត្រូវ នៃដីកាសម្រេច។[23]

នៅក្នុងពាក្យសុំតវ៉ា ត្រូវធ្វើជាលាយល័ក្ខណ៍អក្សរ[24]។

#### ៤.១.១.១. អ្នកដែលមានសិទ្ធិដាក់ពាក្យសុំ

នៅដែលមានសិទ្ធិក្នុងការដាក់ពាក្យសុំ គឺជាកូនបំណុល។ ហើយកូនបំណុលនេះ គឺទទួលបាននូវការបង្គាប់រក្សាការពារ[25]។

#### ៤.១.១.២. សមត្ថកិច្ច

នៅក្នុងការដាក់ពាក្យសុំតវ៉ាចំពោះរក្សាការពារ គឺជាតុលាការដែលបានចេញដីកាសម្រេចរក្សាការពារ[26]។

ឧទាហរណ៍៖ ការតវ៉ាចំពោះដីកាសម្រេចរក្សាការពារដែលសាលាដំបូងរាជធានីភ្នំពេញបានចេញ គឺត្រូវដាក់ពាក្យសុំទៅសាលាដំបូងរាជធានីភ្នំពេញ(មិនមែនតុលាការនៃបណ្តឹងឧទ្ធរណ៍ទេ)។

---

[22] ក្រមនីតិវិធីរដ្ឋប្បវេណី,លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៥៤៤។

[23] ក្រមនីតិវិធីរដ្ឋប្បវេណី,លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា ៥៥០។

[24] ក្រមនីតិវិធីរដ្ឋប្បវេណី,លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៥៣៤។

[25] ក្រមនីតិវិធីរដ្ឋប្បវេណី,លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា ៥៥០។

[26] ក្រមនីតិវិធីរដ្ឋប្បវេណី,លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា ៥៥០។

### ៤.១.១.៣. ការវិនិច្ឆ័យ

ចាំបាច់ត្រូវឆ្លងកាត់តាមកាលបរិច្ឆេទនៃការទាញហេតុផលផ្ទាល់មាត់ ឬតាមកាលបរិច្ឆេទនៃការសួរដែលភាគីទាំងសងខាងអាចចូលរួមបាន[27]។

ដើម្បីអាចបញ្ចប់ការវិនិច្ឆ័យបាន ចាំបាច់ត្រូវសម្រេចថ្ងៃបញ្ចប់ការវិនិច្ឆ័យដោយកំណត់អំឡុងពេលអនុគ្រោះដ៏សមរម្យ ឬត្រូវប្រកាសអំពីការបញ្ចប់ការវិនិច្ឆ័យនៅក្នុងកាលបរិច្ឆេទនៃការទាញហេតុផលដោយផ្ទាល់មាត់ ឬកាលបរិច្ឆេទនៃការសួរភាគីទាំងសងខាងអាចចូលរួមបាន[28]។

នៅក្នុងពាក្យសុំតវ៉ាចំពោះដីកាសម្រេចរក្សាការពារ គឺមិនមានអនុភាពផ្អាកនូវការអនុវត្តរក្សាការពារនោះទេ។ ដើម្បីធ្វើការផ្អាកនូវការអនុវត្តរក្សាការពារបាន ចាំបាច់ត្រូវដាក់ពាក្យសុំផ្អាកការអនុវត្ត។[29]

### ៤.១.១.៤. ដីកាសម្រេច

ដីកាសម្រេចចំពោះពាក្យសុំតវ៉ាដីកាសម្រេចរក្សាការពារ គឺមានបីប្រភេទ ១.ការទទួលស្គាល់ (ករណីដែលរក្សានូវដីកាសម្រេចរក្សាការពារ) ២.ការផ្លាស់ប្តូរ ៣.ការលុបចោល[30]។

តុលាការអាចដាក់លក្ខខណ្ឌឱ្យកូនបំណុលដាក់ប្រាតិភោគបាន ក្នុងករណីដែលសម្រេចថា លុបចោលនូវដីកាសម្រេចរក្សាការពារ។[31]

នៅពេលដែលសម្រេចលុបចោលនូវដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្ន តុលាការអាចបង្គាប់ឱ្យធ្វើបដិទានបានតាមពាក្យសុំរបស់កូនបំណុល។[32]

ដីកាសម្រេចដែលលុបចោលនូវដីកាសម្រេចរក្សាការពារ ពុំមានអនុភាពទេ បើមិនទាន់បានចូលជាស្ថាពរ ប៉ុន្តែបើយល់ឃើញថា ចាំបាច់ពិសេសតុលាការអាចប្រកាសថា ដីកាសម្រេចនោះមានអនុភាពភ្លាមៗ[33]។

ដីកាសម្រេចចំពោះពាក្យសុំតវ៉ាចំពោះដីកាសម្រេចរក្សាការពារ ត្រូវតែបញ្ជូនទៅភាគី[34]។

---

[27] ក្រមនីតិវិធីរដ្ឋប្បវេណី,លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា ៥៥២។

[28] ក្រមនីតិវិធីរដ្ឋប្បវេណី,លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា ៥៥៣។

[29] ក្រមនីតិវិធីរដ្ឋប្បវេណី,លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា ៥៥១។

[30] ក្រមនីតិវិធីរដ្ឋប្បវេណី,លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា ៥៥៤។

[31] ក្រមនីតិវិធីរដ្ឋប្បវេណី,លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា ៥៥៤។

[32] ក្រមនីតិវិធីរដ្ឋប្បវេណី,លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា ៥៥៥។

[33] ក្រមនីតិវិធីរដ្ឋប្បវេណី,លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា ៥៥៦។

[34] ក្រមនីតិវិធីរដ្ឋប្បវេណី,លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា ៥៥៤។

នៅក្នុងតុលាការបើកសិទ្ធិអាចធ្វើការប្ដឹងជំទាស់បាន ប្រសិនបើមានឧបាស្រ័យលើដីកាសម្រេចចំពោះពាក្យសុំតវ៉ាចំពោះដីកាសម្រេចរក្សាការពារ។[35]

### ៤.១.២. ការលុបចោលនូវរក្សាការពារ

នីតិវិធីនៃការលុបចោលនូវការរក្សាការពារអាចមាន ៣ ក្នុងនោះរួមមាន ការលុបចោលរក្សាការពារដោយសារមិនដាក់ពាក្យបណ្ដឹងអង្គសេចក្ដី[36] ការលុបចោលការរក្សាការពារដោយសារការផ្លាស់ប្ដូរស្ថានភាព[37] និង ការលុបចោលការរក្សាការពារដោយសារស្ថានភាពពិសេស[38] ។

#### ៤.១.២.១. ការលុបចោលរក្សាការពារដោយសារមិនដាក់ពាក្យបណ្ដឹងអង្គសេចក្ដី

តុលាការដែលបានចេញដីកាសម្រេចរក្សាការពារ ត្រូវបង្គាប់ឱ្យម្ចាស់បំណុលដាក់ពាក្យបណ្ដឹងអង្គសេចក្ដីហើយឱ្យដាក់ឯកសារបញ្ជាក់អំពីការដាក់ពាក្យបណ្ដឹងអង្គសេចក្ដីនោះ ដោយកំណត់អំឡុងពេលមិនតិចជាង ២ សប្ដាហ៍ តាមពាក្យសុំរបស់កូនបំណុល[39]។

បើម្ចាស់បំណុលមិនដាក់ឯកសារដែលបានកំណត់ខាងលើនេះ ក្នុងពេលដែលបានកំណត់ទេ តុលាការត្រូវ លុបចោលដីកាសម្រេចរក្សាការពារ តាមពាក្យសុំរបស់កូនបំណុល[40]។ យ៉ាងណាមិញ ក្នុងករណីដែលពាក្យបណ្ដឹងអង្គសេចក្ដីត្រូវបានដកវិញ ឬត្រូវបានលើកចោល នៅក្រោយពេលដែលឯកសារដែលបានកំណត់ខាងលើត្រូវបានដាក់ ត្រូវចាត់ទុកថា ឯកសារនោះមិនបានដាក់ឡើយ[41]។

#### ៤.១.២.២. ការលុបចោលការរក្សាការពារដោយសារការផ្លាស់ប្ដូរស្ថានភាព

នៅក្នុងការលុបចោលការរក្សាការពារដោយសារផ្លាស់ប្ដូរស្ថានភាព ត្រូវធ្វើការកំណត់ អំពីតុលាការ និងលក្ខខណ្ឌ ដែលបានធ្វើការកំណត់។

- តើសមត្ថកិច្ចណាទទួលបន្ទុក?
- តើលក្ខខណ្ឌអ្វីដែលលុបចោលរក្សាការពារដោយសារផ្លាស់ប្ដូរស្ថានភាព?

---

35 ក្រមនីតិវិធីរដ្ឋប្បវេណី,លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា ៥៦១។

36 ក្រមនីតិវិធីរដ្ឋប្បវេណី,លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៥៥៧។

37 ក្រមនីតិវិធីរដ្ឋប្បវេណី,លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា ៥៥៨។

38 ក្រមនីតិវិធីរដ្ឋប្បវេណី,លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា ៥៥៩។

39 ក្រមនីតិវិធីរដ្ឋប្បវេណី,លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា ៥៥៧។

40 ក្រមនីតិវិធីរដ្ឋប្បវេណី,លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា ៥៥៧។

41 ក្រមនីតិវិធីរដ្ឋប្បវេណី,លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា ៥៥៧។

  - តុលាការ៖ សមត្ថកិច្ចនៅត្រង់ចំណុចនេះ គឺចង់សំដៅទៅលើតុលាការដែលបានចេញដីកាសម្រេចរក្សាការពារ ឬតុលាការនៃបណ្តឹងអង្គសេចក្តី
  - លក្ខខណ្ឌ៖ ការរំលត់នូវសិទ្ធិ ឬទំនាក់ទំនងគតិយុត្តដែលនឹងត្រូវបានរក្សាការពារ ឬភាពចាំបាច់នៃរក្សាការពារ និងស្ថានភាពផ្សេងទៀត
    - នាពេលបច្ចុប្បន្នទាក់ទងនឹងសិទ្ធិដែលនឹងត្រូវបានរក្សាការពារ ឬភាពចាំបាច់នៃរក្សាការពារ តុលាការបានចេញដីកាសម្រេចរក្សាការពារ
    ករណីដែលគួរតែធ្វើការសម្រេចខុសពីនេះនៅពេលដែលចេញដីកាសម្រេចនោះ។
    ឧទាហរណ៍៖ សាលក្រមដែលម្ចាស់បំណុលបានឈ្នះក្តីនៅក្នុងបណ្តឹងអង្គសេចក្តីបានចូលជាស្ថាពរ សិទ្ធិដែលនឹងត្រូវបានរក្សាការពារត្រូវបានរលត់ដោយសារការសងជាអាទិ៍។

### ៤.១.២.៣. ការលុបចោលការរក្សាការពារដោយសារស្ថានភាពពិសេស

នៅក្នុងការលុបចោលការរក្សាការពារដោយសារស្ថានភាពពិសេស ត្រូវធ្វើការកំណត់ អំពីតុលាការ និងលក្ខខណ្ឌ ដែលបានធ្វើការកំណត់។

- តើតុលាការណាទទួលបន្ទុក?
- តើលក្ខខណ្ឌអ្វីដែលលុបចោលរក្សាការពារដោយសារផ្លាស់ប្តូរស្ថានភាព?
  - តុលាការ៖ តុលាការដែលបានចេញដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្ន ឬតុលាការនៃបណ្តឹងអង្គសេចក្តី
  - លក្ខខណ្ឌ៖ មានការបារម្ភថា ការខូចខាតដែលមិនអាចសងបាន នឹងកើតឡើងដោយសារដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្ន ឬមានស្ថានភាពពិសេសផ្សេងទៀត
  - នៅពេលដែលចេញដីកាសម្រេច តុលាការត្រូវតែមានលក្ខខណ្ឌដែលតម្រូវឱ្យដាក់ប្រាតិភោគ។

នៅក្នុងការវិនិច្ឆ័យ និងការចេញដីកាសម្រេចអំពីការលុបចោលនូវរក្សាការពារវិធានស្តីអំពីការតវ៉ាចំពោះរក្សាការពារ(លើកលែងតែ មាត្រា៥៥៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី) ត្រូវបានយកមកអនុវត្តក្នុងមាត្រា ៥៦០ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

ប៉ុន្តែលើកលែង(ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា ៥៦០ កថាខណ្ឌទី១ ករណីលើកលែង) នូវដីកាសម្រេចដែលបង្គាប់ឱ្យម្ចាស់បំណុលដាក់ពាក្យបណ្តឹងអង្គសេចក្តី ហើយឱ្យដាក់ឯកសារដែលបានបញ្ជាក់អំពីការដាក់ពាក្យបណ្តឹងនោះ(ក្រមនីតិវិធីរដ្ឋប្បវេណី មាត្រា៥៥៧ កថាខណ្ឌទី១)។

មានភាពចាំបាច់ក្នុងការបញ្ជូន( មាត្រា៥៥៧ កថាខណ្ឌទី៨ មាត្រា៥៥៨ កថាខណ្ឌទី៣ មាត្រា៥៥៩ កថាខណ្ឌទី៣ និង មាត្រា៥៤៣ នៃក្រមនីតិវិធីរដ្ឋប្បវេណី) លើកលែងតែដីកាសម្រេចខាងលើ។ អាចធ្វើបណ្តឹងជំទាស់បាន ប្រសិនបើមានការធ្វើឧបាស្រ័យលើដីកាសម្រេចនោះ (មាត្រា ៥៦១ កថាខណ្ឌទី១ ចំណុច«ក»)។

### ៤.១.៣. បណ្តឹងជំទាស់

សេចក្តីសម្រេចដែលអាចឱ្យធ្វើបណ្តឹងជំទាស់បាន មានដូចជាដីកាសម្រេចអំពីពាក្យសុំតវ៉ាចំពោះដីកាសម្រេចរក្សាការពារ (លើកលែងពាក្យសុំតវ៉ាចំពោះដីកាសម្រេចរក្សា ការពារដែលតុលាការនៃបណ្តឹងជំទាស់បានចេញ)ឬដីកាសម្រេចអំពីពាក្យសុំទាមទារឱ្យលុបចោលដីកា សម្រេចរក្សាការពារ។[42] ដីកាសម្រេចដែលបង្គាប់ឱ្យធ្វើបដិទានក្នុងករណីដែលលុបចោលនូវដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្ន។[43]

នៅក្នុងនោះផងដែរគួរពិចារណាដោយប្រុងប្រយ័ត្នទៅលើ អំឡុងពេលដែលអាចប្តឹងជំទាស់បានគឺ ពីរសប្តាហ៍[44] មានភាពចាំបាច់នូវការទាញហេតុផលដោយផ្ទាល់មាត់ ឬ ការសួរដែលភាគី ទាំងសងខាងអាចចូលរួមបាន។[45]

សេចក្តីសម្រេចដែលអាចឱ្យធ្វើបណ្តឹងជំទាស់បាន រួមមានសេចក្តីសម្រេចដែលលើកចោលពាក្យសុំឱ្យចេញដីកាសម្រេចរក្សាការពារ។[46] ដោយនៅក្នុងនោះត្រូវប្រុងប្រយ័ត្ននូវ អំឡុងពេលដែលអាចប្តឹងជំទាស់បានគឺ ២សប្តាហ៍។[47] ចំពោះនីតិវិធីនេះវិញ គឺដូចគ្នានឹងករណីនៃបណ្តឹងជំទាស់ធម្មតា ដែរហើយមិនមានភាពចាំបាច់នៅក្នុងការទាញហេតុផលដោយផ្ទាល់មាត់ឬ ការសួរទេ។[48] វិធីនៅក្នុងការវិនិច្ឆ័យមានលក្ខណៈខុសគ្នាពី បណ្តឹងជំទាស់ចំពោះដីកាសម្រេចអំពីពាក្យ សុំតវ៉ាចំពោះដីកាសម្រេចរក្សាការពារ។ [49]

[42] ក្រមនីតិវិធីរដ្ឋប្បវេណី,លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៥៦១។

[43] ក្រមនីតិវិធីរដ្ឋប្បវេណី,លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៥៦១។

[44] ក្រមនីតិវិធីរដ្ឋប្បវេណី,លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៥៦១។

[45] ក្រមនីតិវិធីរដ្ឋប្បវេណី,លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៥៦១។

[46] ក្រមនីតិវិធីរដ្ឋប្បវេណី,លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៥៤៤។

[47] ក្រមនីតិវិធីរដ្ឋប្បវេណី,លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៥៤៤។

[48] ក្រមនីតិវិធីរដ្ឋប្បវេណី,លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៥៣៩ និង មាត្រា ៣០៦។

[49] ក្រមនីតិវិធីរដ្ឋប្បវេណី,លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៥៦១។

# ផ្នែកទី៥៖ ការអនុវត្តចាត់ចែងជាបណ្ដោះអាសន្នចំពោះអចលនវត្ថុ

## ៥.១. លក្ខខណ្ឌអនុវត្ត

នៅក្នុងការអនុវត្តដីកាសម្រេចរក្សាការពារ ត្រូវអនុវត្តដោយផ្អែកលើឯកសារចម្លងយថាភូតនៃដីកាសម្រេចរក្សាការពារ ដូច្នេះ ជាគោលការណ៍ មិនត្រូវការរូបមន្តអនុវត្តទេ ។[50] ប៉ុន្តែ នៅពេលមានការអនុវត្ត សម្រាប់បុគ្គលក្រៅពីម្ចាស់បំណុល ឬ ចំពោះបុគ្គលក្រៅពីកូនបំណុល ដែលត្រូវបានកំណត់នៅក្នុងដីកា សម្រេចរក្សាការពារ គឺចាំបាច់ត្រូវការការផ្ដល់នូវរូបមន្តអនុវត្ត (រូបមន្តអនុវត្តពិសេស)[51] ដើម្បីបង្ហាញភាគីអនុវត្ត [52]។

ការអនុវត្តដីកាសម្រេចរក្សាការពារ មិនត្រូវធ្វើឡើយ បើអំឡុងពេល ២ សប្ដាហ៍ បានកន្លងហួស ចាប់ពីថ្ងៃដែលដីកាសម្រេចរក្សាការពារ ត្រូវបានបញ្ជូនទៅម្ចាស់បំណុល។[53] ការអនុវត្ត ដីកាសម្រេចរក្សាការពារ អាចធ្វើបាន ទោះបីជាមុនពេលដីកាសម្រេចរក្សាការពារត្រូវបានបញ្ជូនទៅកូន បំណុលក៏ដោយ។ [54]

## ៥.២. វិធី និង សមត្ថកិច្ចអនុវត្ត

តាមក្រមនីតិវិធីរដ្ឋប្បវេណី ចំពោះការអនុវត្តការចាត់ចែងជាបណ្ដោះអាសន្ន មានកំណត់ថា ត្រូវអនុវត្តតាមវិធីដូចគ្នានឹងការអនុវត្តរឹបអូសជាបណ្ដោះអាសន្ន ឬ ការអនុវត្តដោយបង្ខំតែប៉ុណ្ណោះ។[55] ហេតុដូច្នេះ ចំពោះវិធីអនុវត្តចាត់ចែងជាបណ្ដោះអាសន្ន និងសមត្ថកិច្ចនោះលុះត្រាតែមិនមានបញ្ញត្តិពិសេស ទើបត្រូវចាំបាច់ វិនិច្ឆ័យដោយអនុវត្តតាមវិធីដូចគ្នានឹងការអនុវត្តរឹបអូសជាបណ្ដោះអាសន្ន ឬ ការអនុវត្តដោយបង្ខំ ឱ្យបានត្រឹមត្រូវ ដោយស្របតាមលក្ខណៈនៃការចាត់ចែងជាបណ្ដោះអាសន្ន។

ការចាត់ចែងជាបណ្ដោះអាសន្នដែលហាមឃាត់ផ្ទេរការកាន់កាប់ ត្រូវបង្គាប់ហាមឃាត់មិនឱ្យកូនបំណុលផ្ទេរការកាន់កាប់វត្ថុ និង បង្គាប់ឱ្យកូនបំណុលប្រគល់វត្ថុទៅអាជ្ញាសាលា ដោយដកហូតការកាន់កាប់នោះ ហើយបង្គាប់ឱ្យអាជ្ញាសាលាថែរក្សាគ្រប់គ្រងវត្ថុនោះ ដើម្បីរក្សាការពារសិទ្ធិទាមទារឱ្យប្រគល់វត្ថុនោះ ត្រូវ បានចេញអាជ្ញាសាលាត្រូវប្រកាសជាសាធារណៈថា កូនបំណុលត្រូវបានហាមឃាត់ការផ្ទេរការកាន់កាប់ វត្ថុនោះ ហើយអាជ្ញាសាលាថែរក្សាគ្រង់គ្រងវត្ថុនោះ ដោយបិទប្រកាសជាសាធារណៈ តាមរបៀបដែល ពុំងាយបចេញ ឬ តាម

[50] ក្រមនីតិវិធីរដ្ឋប្បវេណី,លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៥៦២។

[51] ក្រមនីតិវិធីរដ្ឋប្បវេណី,លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៥៦២។

[52] ក្រមនីតិវិធីរដ្ឋប្បវេណី,លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៣៥១។

[53] ក្រមនីតិវិធីរដ្ឋប្បវេណី,លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា ៥៦២។

[54] ក្រមនីតិវិធីរដ្ឋប្បវេណី,លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៥៦២។

[55] ក្រមនីតិវិធីរដ្ឋប្បវេណី,លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា ៥៧០។

របៀបសមរម្យផ្សេងទៀត។[56] ម្យ៉ាងទៀត ទោះបីជា អាជ្ញាសាលាយកវត្ថុដែលជាកម្មវត្ថុនៃវិវាទចេញពីកូនបំណុល មួយខណៈក៏ដោយ ក៏វិធីថែរក្សាគ្រប់គ្រង ជាលម្អិតនៅពេលបន្ទាប់នោះ មានវិធីដូចខាងក្រោម៖

វិធីទី១ គឺជាវិធីដែលអនុញ្ញាតឱ្យកូនបំណុលបន្តប្រើប្រាស់វត្ថុដែលជាកម្មវត្ថុនៃវិវាទនោះ។ វិធីនេះ មិនសូវជាជះឥទ្ធិពលដល់កូនបំណុលទេ និងជាទម្រង់ប្រើប្រាស់ជាមូលដ្ឋានទោះបីនៅក្នុងប្រទេសជប៉ុន។ វិធីទី២ គឺជាវិធីដែលអាជ្ញាសាលាថែរក្សាគ្រប់គ្រងវត្ថុដែលជាកម្មវត្ថុនៃវិវាទដោយខ្លួនឯង។ ករណី វត្ថុដែលជាកម្មវត្ថុនៃវិវាទគឺជាចលនវត្ថុដូចជា វត្ថុសិល្បៈ និង វត្ថុជាគ្រឿងមាសប្រាក់ ជាអាទិ៍ ប្រសិនបើ ទុកនៅក្នុងដៃរបស់កូនបំណុល នោះនឹងលទ្ធភាពដែលតតិយជនធ្វើលទ្ធកម្មដោយសុចរិតនូវវត្ថុដែលជា កម្មវត្ថុនៃវិវាទនោះ។ ក្នុងករណីនេះអាជ្ញា-សាលា មិនត្រូវឱ្យកូន បំណុលប្រើប្រាស់វត្ថុដែលជាកម្មវត្ថុនៃវិវាទទេ គឺត្រូវថែរក្សាគ្រប់គ្រងវត្ថុដែលជាកម្មវត្ថុនៃវិវាទដោយខ្លួនឯង។

ចំពោះវិធីទី២នឹងជះឥទ្ធិពលយ៉ាងខ្លាំងទៅកូនបំណុល ដូច្នេះដើម្បីចេញដីកាសម្រេចចាត់ចែងជាបណ្ដោះ-អាសន្ន ក្រៅពីទាមទារឱ្យមានភាពចាំបាច់ខ្លាំងក្នុងការរក្សាការពារ ក៏នៅពេលជំនុំជម្រះ ចំពោះពាក្យសុំឱ្យចេញដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្ន គួរតែផ្ដល់ឱកាសទៅកូនបំណុលធ្វើការអះអាង ដោយសាកសួរមិនត្រឹមតែម្ចាស់បំណុលទេ ក៏សាកសួរផងដែរទៅកូនបំណុលផងដែរ។

ការអនុវត្តចាត់ចែងជាបណ្ដោះអាសន្នដែលហាមឃាត់ផ្ទេរការកាន់កាប់ គឺម្ចាស់បំណុលត្រូវដាក់ ពាក្យសុំជាលាយល័ក្ខណ៍អក្សរ[57] ចំពោះអាជ្ញាសាលានៃសាលាដំបូងដែលមានសមត្ថកិច្ចលើកន្លែងដែលវត្ថុដែលជាកម្មវត្ថុនៃវិវាទស្ថិតនៅ។ [58]

ការអនុវត្តចាត់ចែងជាបណ្ដោះអាសន្នដែលហាមឃាត់ចាត់ចែង ត្រូវធ្វើតាមវិធីដូចគ្នានឹងការអនុវត្តរឹបអូសជាបណ្ដោះអាសន្ន។ ការអនុវត្តចាត់ចែងជាបណ្ដោះអាសន្នចំពោះអចលនវត្ថុ ត្រូវអនុវត្តតាមវិធីចុះបញ្ជីហាមឃាត់ការចាត់ចែង។[59][60]

ការអនុវត្តចាត់ចែងជាបណ្ដោះអាសន្នដែលហាមឃាត់ការចាត់ចែង គឺកំណត់ឱ្យតុលាការដែល បានចេញដីកាសម្រេចហាមឃាត់ការចាត់ចែង ជាតុលាការអនុវត្តរក្សាការពារ ហើយក្រឡាបញ្ជីនៃតុលាការនេះត្រូវផ្ទុកផ្ទាកការចុះបញ្ជី។

[56] ក្រមនីតិវិធីរដ្ឋប្បវេណី,លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា ៥៧១។

[57] ក្រមនីតិវិធីរដ្ឋប្បវេណី,លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៥៣៤។

[58] ក្រមនីតិវិធីរដ្ឋប្បវេណី,លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា ៥៧០, មាត្រា ៥២៤ , និងមាត្រា ៥២៥។

[59] ក្រមនីតិវិធីរដ្ឋប្បវេណី,លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា ៥៧០ និង មាត្រា ៥៦៧។

[60] ប្រកាសអន្តរក្រសួងស្តីពីការចុះបញ្ជីអចលនវត្ថុទាក់ទងនឹងក្រមនីតិវិធីរដ្ឋប្បវេណីជាអាទិ៍, ប្រការ ២០។

## ៥.៣.អានុភាពនៃការអនុវត្តចាត់ចែងជាបណ្តោះអាសន្នចំពោះវត្ថុដែលជាកម្មវត្ថុនៃវិវាទ

នៅពេលដែលបានធ្វើការចាត់ចែងជាបណ្តោះអាសន្នដែលហាមឃាត់ផ្ទេរការកាន់កាប់ ម្ចាស់បំណុលអាចអនុវត្តដោយបង្ខំឱ្យប្រគល់វត្ថុដែលជាកម្មវត្ថុនៃវិវាទ ដោយផ្អែកលើលិខិតអនុវត្តនៅក្នុងអង្គសេចក្តី។ ប៉ុន្តែ អាចអនុវត្តបានតែចំពោះជនដែលកាន់កាប់វត្ថុនោះ ដោយដឹងថាការអនុវត្តការចាត់ចែងជាបណ្តោះអាសន្ន នោះត្រូវបានធ្វើហើយ។[61] មានន័យថា នេះមិនមែនជាការបន្តពីកូនបំណុលទេ គឺទោះបីជាមានការលេចឡើងតតិយជនដែលបានលទ្ធកម្មការកាន់កាប់វត្ថុដែលជាកម្មវត្ថុនៃវិវាទ ប្រសិនបើ តតិយជននោះទុច្ចរិត ពោលគឺបានដឹងថាការចាត់ចែងជាបណ្តោះអាសន្នដែលហាមឃាត់ផ្ទេរការកាន់កាប់ ត្រូវបានអនុវត្ត នាំឱ្យម្ចាស់បំណុល អាចអនុវត្តដោយបង្ខំឱ្យប្រគល់វត្ថុដែលជាកម្មវត្ថុនៃវិវាទ ដោយផ្អែកលើ លិខិតអនុវត្តនៅក្នុងអង្គសេចក្តីចំពោះកូនបំណុលបាន។ ម្យ៉ាងទៀត នេះជាករណីអនុវត្តដោយបង្ខំចំពោះ កូនបំណុលអនុវត្តដែលជាបុគ្គលក្រៅពីភាគីដែលត្រូវបានកំណត់នៅក្នុងលិខិតអនុវត្ត ដូច្នេះចាំបាច់ត្រូវផ្តល់ រូបមន្តអនុវត្តពិសេស ឬ រូបមន្តអនុវត្តបន្ត។[62]

ករណីដែលមិនមែនបន្តពីកូនបំណុល ហើយតតិយដែលបានលទ្ធកម្មការកាន់កាប់នូវវត្ថុដែលជា កម្មវត្ថុនៃវិវាទ បានសុចរិត ពោលគឺជាករណីដែលមិនបានដឹងថាការចាត់ចែងជាបណ្តោះអាសន្នដែល ហាមឃាត់ផ្ទេរការកាន់កាប់ត្រូវបានអនុវត្ត នាំឱ្យម្ចាស់បំណុល មិនអាចអនុវត្តដោយបង្ខំឱ្យប្រគល់វត្ថុដែល ជាកម្មវត្ថុនៃវិវាទ ដោយផ្អែកលើលិខិតអនុវត្តនៅក្នុងអង្គសេចក្តីចំពោះកូនបំណុល[63] ។ ម្យ៉ាងទៀត បុគ្គលដែលបានកាន់កាបវត្ថុដែលជាកម្មវត្ថុនៃវិវាទនៅក្រោយពេលអនុវត្តចាត់ចែងជា បណ្តោះអាសន្នដែលហាមឃាត់ផ្ទេរការកាន់កាប់ ត្រូវសន្មតថាបានកាន់កាប់ដោយដឹងថាការអនុវត្ត ចាត់ចែងជាបណ្តោះអាសន្ននោះត្រូវបានអនុវត្ត[64] ដូច្នេះ ករណីដែលអាចទទួលស្គាល់ថាតតិយជនជាជនសុចរិត គឺមិនមានច្រើននោះទេ។

## ៥.៤. ពាក្យសុំឱ្យអនុវត្តរក្សាការពារ[65]

នៅក្នុងការអនុវត្តជាក់ស្តែង នៅពេលដែលទទួលបានដីកាសម្រេច ត្រូវធ្វើការដាក់ពាក្យសុំឱ្យធ្វើការអនុវត្តនៅក្នុងពាក្យសុំឱ្យអនុវត្តរក្សាការពារ ត្រូវមានចំណុចសំខាន់ៗក្នុងការសុំឱ្យតុលាការក្នុងការអនុវត្ត

[61] ក្រមនីតិវិធីរដ្ឋប្បវេណី,លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៥៧១។

[62] ក្រមនីតិវិធីរដ្ឋប្បវេណី,លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៣៥៦។

[63] ក្រមនីតិវិធីរដ្ឋប្បវេណី,លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា ៥៧១។

[64] ក្រមនីតិវិធីរដ្ឋប្បវេណី,លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា ៥៧១។

[65] ឧបសម្ព័ន្ធទី៣, ទម្រង់គំរូ នៃពាក្យសុំឱ្យអនុវត្តរក្សាការពារ។

ក. សញ្ញាណនៃដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន[66]

ខ.សេចក្តីសុំឱ្យអនុវត្ត[67]

គ. សញ្ញាណនៃទ្រព្យសម្បត្តិដែលជាកម្មវត្ថុនៃការអនុវត្ត។[68]

[66] ក្រមនីតិវិធីរដ្ឋប្បវេណី,លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៥៦៤ និង មាត្រា៣៤៩។

[67] ក្រមនីតិវិធីរដ្ឋប្បវេណី,លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៥៦៤ និង មាត្រា៣៤៩។

[68] ក្រមនីតិវិធីរដ្ឋប្បវេណី,លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦, មាត្រា៥៦៤ និង មាត្រា៣៤៩។

## ៥.៥. លំហូរនីតិវិធីនៃការចុះបញ្ជីដែលទាក់ទងនឹងការអនុវត្តចាត់ចែងជាបណ្តោះអាសន្ន





រដ្ឋបាលសុរិយោដី
ការថតចម្លងសៀវភៅចុះបញ្ជី
ប្រការ៣៨
ក្រឡាបញ្ជី
ការពិនិត្យការថតចម្លងសៀវភៅចុះបញ្ជី
ត្រឹមត្រូវ(បញ្ចប់)
មិនត្រឹមត្រូវ
ក្រឡាបញ្ជី
ចេញលិខិតផ្ដុកផ្ដាក់ឱ្យកែតម្រូវ
ប្រការ៣៩
រដ្ឋបាលសុរិយោដី
ការកែតម្រូវ
ប្រការ៣៩
រដ្ឋបាលសុរិយោដី
ការថតចម្លងសៀវភៅចុះបញ្ជី
ប្រការ៣៨
រដ្ឋបាលសុរិយោដី
ការបញ្ជូនទៅឱ្យក្រឡាបញ្ជី
ធ្វើលិខិតផ្ដុកផ្ដាក់លុបការចុះបញ្ជីអំពីការចាត់ចែងជាបណ្ដោះអាសន្ន
ក្រឡាបញ្ជី
ប្រការ២០ ក្នុងឧបសម្ព័ន្ធទី១៧
មាត្រា៤២៨
ការលុបការចុះបញ្ជីអចលនវត្ថុអំពីការចាត់ចែងជាបណ្ដោះអាសន្នចំពោះអចលនវត្ថុនៅរដ្ឋបាលសុរិយោដី
ដោយរដ្ឋបាលសុរិយោដី
ប្រការ២១
ការថតចម្លងសៀវភៅចុះបញ្ជី
ដោយរដ្ឋបាលសុរិយោដី
ប្រការ៣៨
ការបញ្ជូនទៅឱ្យក្រឡាបញ្ជី
ដោយរដ្ឋបាលសុរិយោដី
ប្រការ៣៨
ការពិនិត្យការថតចម្លងសៀវភៅចុះបញ្ជី
ក្រឡាបញ្ជី
ប្រការ៣៨
ត្រឹមត្រូវ(បញ្ចប់)
មិនត្រឹមត្រូវ
ចេញលិខិតផ្ដុកផ្ដាក់ឱ្យកែតម្រូវ
ក្រឡាបញ្ជី




## ៥.៦ ការបញ្ជូន

នៅពេលដែលតុលាការបានចេញដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្ន (ចំពោះអចលនវត្ថុ) តាមពាក្យសុំរបស់ម្ចាស់បំណុល តុលាការនឹងធ្វើការបញ្ជូនទៅកាន់ភាគី (កូនបំណុល)។[69]

តើការបញ្ជូនដីកាសម្រេចនឹងតុលាការណាទទួលបន្ទុកក្នុងការបញ្ជូន.?តើការបញ្ជូនដីកាសម្រេចត្រូវប្រតិបត្តិរបៀបណា?

តុលាការដែលទទួលការទទួលបន្ទុកក្នុងការបញ្ជូន គឺតុលាការដែលទទួលពាក្យសុំចេញដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្ន (ចំពោះអចលនវត្ថុ) ដែលកម្មវត្ថុនៃវិវាទស្ថិតនៅ។ ក្នុងនោះកិច្ចការបញ្ជូនត្រូវធ្វើឡើងដោយក្រឡាបញ្ជី។[70] ហើយការបញ្ជូននេះត្រូវបានប្រតិបត្តិដោយបុគ្គលិកប្រៃសណីយ៍ អាជ្ញាសាលា ឬក្រឡា-បញ្ជី។[71] ការបញ្ជូនត្រូវធ្វើទៅលំនៅឋាន ទីសំណាក់ ទីកន្លែងអាជីវកម្ម ឬ ទីស្នាក់ការរបស់ជនដែលត្រូវទទួលការបញ្ជូន។[72]

នៅពេលដែលការបញ្ជូនរួចរាល់ត្រូវធ្វើរបាយការណ៍អំពីការបញ្ជូន នៅក្នុងនោះបានធ្វើការកំណត់៖

- សញ្ញាណនៃរឿងក្ដី និងឯកសារដែលបានបញ្ជូន
- ជនដែលត្រូវទទួលការបញ្ជូន

---

[69] ក្រមនីតិវិធីរដ្ឋប្បវេណី,លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦,មាត្រា៥៤៣ ។

[70] ក្រមនីតិវិធីរដ្ឋប្បវេណី,លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦,មាត្រា២៤៦ កថាខណ្ឌទី២ ។

[71] ក្រមនីតិវិធីរដ្ឋប្បវេណី,លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦,មាត្រា២៤៦ កថាខណ្ឌទី៣ ។

[72] ក្រមនីតិវិធីរដ្ឋប្បវេណី,លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦,មាត្រា២៤៩។

- ថ្ងៃ ខែ ឆ្នាំ និងទីកន្លែងដែលបានធ្វើការបញ្ជូន
- វិធីបញ្ជូន
- ហត្ថលេខា ឬស្នាមមេដៃរបស់អ្នកដែលបានទទួលឯកសារ
- ហត្ថលេខារបស់អ្នកដែលប្រតិបត្តិការបញ្ជូន។[73]

[73] ក្រមនីតិវិធីរដ្ឋប្បវេណី,លេខ នស/រកម/០៧០៦/០២១, ០៦ កក្កដា ២០០៦,មាត្រា២៥៤។

# ជំពូកទី៣
# បញ្ហាប្រឈម
# និងដំណោះស្រាយ

# ជំពូកទី៣
# បញ្ហាប្រឈម និងដំណោះស្រាយ

នៅក្នុងវិស័យយុត្តិធម៌ ពាក់ព័ន្ធនឹងនីតិវិធីរដ្ឋប្បវេណី គោលបំណងនៃបណ្តឹងរដ្ឋប្បវេណី គឺធ្វើការពឹងពាក់ទៅកាន់តុលាការដើម្បីអោយតុលាការដោះស្រាយវិវាទរដ្ឋប្បវេណី ដោយផ្អែកលើច្បាប់ ដើម្បីការពារសិទ្ធិរបស់បុគ្គលឯកជន។

បើក្រឡេកទៅមើលនៅក្នុងការអនុវត្តជាក់ស្តែង តែងតែមានបញ្ហា ទោះមានបញ្ញត្តិនៃច្បាប់បានធ្វើការកំណត់យ៉ាងច្បាស់ក៏ដោយសារបរិបទនៃសង្គមមានការប្រែប្រួល បែបនេះក្នុងការអនុវត្តតែងតែមានការប្រែប្រួលទៅតាមការរីកចម្រើននៅក្នុងសង្គមនេះ ជាក់ស្តែងដូចជាច្បាប់ជាដើម ប្រជាពលរដ្ឋទូទាំងប្រទេសនៅតែមានយល់ដឹងមានកម្រិត ទោះបច្ចុប្បន្នមានការរីកចម្រើនក៏ដោយ យ៉ាងណាមិញក៏មានការចូលរួមក្រសួងពាក់ព័ន្ធក្នុងការធ្វើយន្តការក្នុងការផ្សព្វផ្សាយអំពីច្បាប់ អោយប្រជាពលរដ្ឋបានធ្វើការយល់ដឹងអំពីច្បាប់។ ទោះជាយ៉ាងណាក្តីនៅតែមិនទាន់ទូលំទូលាយក្នុងការយល់ដឹង ដូចជា វ៉ាក្យស័ព្ទភាសាច្បាប់មានការប្រើប្រាស់មិនដូចជាភាសាទូទៅដែលប្រជាពលរដ្ឋប្រើប្រាស់ប្រាស្រ័យទាក់ទងគ្នា ហើយបើយើងក្រឡេកពាក់ព័ន្ធច្បាប់ក្រមនីតិវិធីរដ្ឋប្បវេណីទៀត។

## ផ្នែកទី១៖ បញ្ហាប្រឈម

### ១.១ ភាពខ្វះចន្លោះនៃច្បាប់

ទោះបីរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជាបានធ្វើការបង្កើតច្បាប់ជាច្រើនប៉ុន្តែច្បាប់ទាំងអស់នឹងតែមិនទាន់គ្រប់គ្រាន់នៅឡើយទេជាពិសេសក្រមនីតិវិធីរដ្ឋប្បវេណីបទបញ្ញត្តិមួយចំនួននៅក្នុងរក្សាការពារនៅតែមានភាពខ្វះចន្លោះ។នៅក្នុងបទបញ្ញត្តិនៃការចាត់ចែងជាបណ្តោះអាសន្នចំពោះអចលនវត្ថុ មានបទបញ្ញត្តិមួយចំនួនបានធ្វើការចែងមិនគ្រប់គ្រាន់ មានបទបញ្ញត្តិខ្លះចែងនៅក្នុងលំហូរនីតិវិធីបណ្តឹង (ការអនុវត្តសាលក្រមនៅក្នុងរក្សាការពារគឺចៅក្រមបានធ្វើការកំណត់ចំណុចវិវាទ)។ ប៉ុន្តែនៅក្នុងការអនុវត្តជាក់ស្តែងចៅក្រមមិនបានធ្វើការកំណត់ចំនុចវិវាទនោះទេ គឺចេញដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្នចំពោះអចលនវត្ថុទៅឱ្យម្ចាស់បំណុលតែម្តង នៅពេលដែលម្ចាស់បំណុលដាក់ពាក្យសុំ ដោយភ្ជាប់ជាមួយសេចក្តីបញ្ជាក់ដំបូង ។តុលាការចេញដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្នចំពោះអចលនវត្ថុតែម្តង ដោយចៅក្រមមិនបានធ្វើការកោះហៅភាគីកូនបំណុលម្ចាស់បំណុលធ្វើការកំណត់ចំនុចវិវាទនោះទេ ប៉ុន្តែតាមផ្លូវច្បាប់ការចាត់ចែងជាបណ្តោះអាសន្នចំពោះអចលនវត្ថុក៏តម្រូវឱ្យមានចំណុចវិវាទផងដែរដូចចែងនៅក្នុងមាត្រា។ដូចជាបទបញ្ញត្តិខ្លះអត់បានធ្វើការចែងនៅក្នុងរក្សាការពារប៉ុន្តែចែងនៅក្នុងការអនុវត្តដោយបង្ខំអំពីតួនាទីរបស់អាជ្ញាសាលា ហើយយកមកអនុវត្តនៅក្នុង

រក្សាការពារ ជាពិសេសនៅក្នុងព្រះរាជាណាចក្រកម្ពុជាមិនទាន់មានច្បាប់ស្តីពីលក្ខន្តិកៈអាជ្ញាសាលានៅឡើយ នៅក្នុងរឿងក្តីចាត់ចែងជាបណ្តោះអាសន្នចំពោះអចលនវត្ថុនៅក្នុងរឿងនឹង

បច្ចុប្បន្នយើងមានប្រកាសស្តីពីការចុះបញ្ជីដែលទាក់ទងនឹងការអនុវត្តចាត់ចែងរក្សាការពារ មានប្រកាសរបស់ក្រសួងយុត្តធម៌ស្តីពីតួនាទី និងភារកិច្ចរបស់ព្រះរាជអាជ្ញា ព្រះរាជអាជ្ញារងទទួលបន្ទុក ជំនួសអាជ្ញាសាលានៅក្នុងការអនុវត្ត។

នៅក្នុងក្រមនីតិវិធីធ្វើការចែងអត់គ្រប់ជ្រុងជ្រោយ ដូចជានៅក្នុងរក្សាការពារអត់បានធ្វើការកំណត់អំពីថេរវេលាអំពីបណ្តឹងតវ៉ា។

## ១.២. ភាពយឺតយ៉ាវនៃដំណើរការនីតិវិធីសំណុំរឿងចាត់ចែងជាបណ្តោះអាសន្នចំពោះអចលនវត្ថុ

នៅក្នុងដំណើរការនីតិវិធីនៃសំណុំរឿងរក្សាការពារ(ចាត់ចែងជាបណ្តោះអាសន្នចំពោះអចលនវត្ថុ)មានភាពយឺតយ៉ាវដោយសារនីតិវិធីនេះមានលក្ខណៈបទបែនតាមកាលៈទេសៈ នៃនីតិវិធីនេះដែលនាំស្មុគស្មាញក្នុងការដំណើរការនីតិវិធី តាំងពីដាក់ពាក្យសុំរហូតដល់ចេញដីកាសម្រេចដែលកំណត់អំពីសិទ្ធិក្នុងការអនុវត្ត ដែលនាំឲ្យនីតិវិធីមានភាពយឺតយ៉ាវ ក្នុងករណីខ្លះមានការប្រែប្រួលកម្មវត្ថុ ដោយសារអ្នកដាក់ពាក្យសុំធ្វើការផ្លាស់ប្តូរកម្មវត្ថុដោយសារអត់បានធ្វើការកំណត់អំពីគោលបំណងអោយបានច្បាស់លាស់អំពីគោលបំណងអំពីកម្មវត្ថុដែលបានដាក់មកកាន់តុលាការ ដែលនាំឲ្យតុលាការធ្វើការច្រានចោល ឬបង្គាប់អោយធ្វើការកែប្រែ បែបនេះហើយទើបធ្វើអោយមានភាពយឺតយ៉ាវនៃដំណើរនីតិវិធីដែលធ្វើអោយរាំងស្ទះក្នុងការអនុវត្តរបស់តុលាការ ។

ជាទូទៅនីតិវិធីនៃការចាត់ចែងជាបណ្តោះអាសន្នចំពោះអចលនវត្ថុវាមានភាពយឺតយ៉ាវ នៅពេលដែលម្ចាស់បំណុលដាក់ពាក្យស្នើសុំដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្នចូលទៅតុលាការហើយ តុលាការទទួលពាក្យសុំចេញដីកាសម្រេចនឹង ហើយតុលាការអត់ទាន់ចេញដីកាសម្រេចឱ្យម្ចាស់បំណុលភ្លាមៗនោះទេ ទុកសំណុំរឿងនៅយូរ ម្ចាស់បំណុលគាត់ដាក់ពាក្យសុំទៅកាន់តុលាការអត់ត្រឹមត្រូវ ជាហេតុដែលនាំឱ្យចេញដីកាបង្គាប់ឱ្យកែតម្រូវពាក្យសុំធ្វើឱ្យមានការយឺតយ៉ាវដែរ។ តុលាការទទួលសំណុំរឿងច្រើន ការចាត់ចែងជាបណ្តោះអាសន្ននឹង អត់ទាន់ចាត់រឿងនឹងទៅកាន់ក្រឡាបញ្ជី កំហុសបច្ចេកទេសក្នុងដំណើរការនីតិវិធី ក៏ជាមូលហេតុដែលនាំឱ្យមានភាពយឺតយ៉ាវដែរ។

ដូចនៅក្នុងសំណុំរឿងការចាត់ចែងជាបណ្តោះអាសន្ន (ចំពោះអចលនវត្ថុ) មាននៅពេលដែលដាក់ពាក្យសុំចេញដីកាសម្រេចការចាត់ចែងជាបណ្តោះអាសន្នចំពោះអចលនវត្ថុ ម្ចាស់បំណុល(អ្នកដាក់ពាក្យសុំ)។

**ឧទាហរណ៍៖**លោក«ក»បានធ្វើការដាក់ពាក្យសុំឱ្យចេញដីកាសម្រេចរក្សាការពារ ការចាត់ចែងជាបណ្ដោះអាសន្នចំពោះអចលនវត្ថុ ហាមឃាត់ការផ្ទេរការកាន់កាប់ទៅលើអចលនវត្ថុ នៅពេលដែលអំឡុងពេលដំណើរការនីតិវិធី ដោយសារមានលក្ខណៈស្មុគស្មាញ ដែលធ្វើឱ្យការផ្ទេរអចលនវត្ថុ ដែលជាកម្មវត្ថុនៃវិវាទទៅឱ្យតតិយជន ។

ដូចក្នុងករណីដែលម្ចាស់បំណុល មិនមានភាពច្បាស់លាស់អំពីគោលបំណងថា ចង់បានអ្វីឱ្យពិតប្រាកដ គោលបំណងឱ្យសងជាប្រាក់? គ្មានគោលបំណងឱ្យសងជាប្រាក់?(ឱ្យធ្វើការប្រគល់អចលនវត្ថុដែលជាកម្មវត្ថុនៃវិវាទត្រឡប់មកវិញ។ ដោយសារតែបែបនេះហើយទើបធ្វើឱ្យដំណើរការនីតិវិធីមានលក្ខណៈស្មុគស្មាញត្រូវចំណាយពេលវេលាជាច្រើននៅក្នុងនីតិវិធី។

មួយវិញទៀតដូចក្នុងករណី នៅពេលដែលទទួលបានដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្ន(ចំពោះអចលនវត្ថុ) ប៉ុន្តែមិនអាចធ្វើការអនុវត្តបានដោយសារ នៅក្នុងដំណើរការនីតិវិធីមានលក្ខណៈស្មុគស្មាញ ដែលនាំឱ្យមានការផ្ទេរកម្មសិទ្ធិនៃអចលនវត្ថុដែលកម្មវត្ថុនៃវិវាទ(ដីមានច្រើនកន្លែង)ទៅឱ្យតតិយជនរួចរាល់។

**ឧទាហរណ៍៖** លោក«ក»ដាក់ពាក្យសុំចេញដីកាសម្រេចរក្សាការពារ(ចាត់ចែងជាបណ្ដោះអាសន្នចំពោះអចលនវត្ថុ «ហាមឃាត់ការផ្ទេរការកាន់កាប់») ដោយកម្មវត្ថុនៃវិវាទដែលជាអចលនវត្ថុមានច្រើនកន្លែង (ភ្នំពេញ, បាត់ដំបង,ព្រះសីហនុ,សៀមរាប,ស្វាយរៀង,តាកែវ) លោក«ក» បានឈ្នះក្ដី ហើយយកដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្ន(ហាមឃាត់ការផ្ទេរការកាន់កាប់)យកទៅអនុវត្ត។ ប៉ុន្តែនៅក្នុងនោះអចលនវត្ថុដែលស្ថិតនៅក្នុងខេត្តតាកែវបានធ្វើការផ្ទេររួចរាល់ មុននឹងដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្ន(ចំពោះអចលនវត្ថុ«ហាមឃាត់ការផ្ទេរការកាន់កាប់») កម្មវត្ថុនៃវិវាទ(អចលនវត្ថុ)បានធ្វើការផ្ទេរកម្មសិទ្ធិបានរួចរាល់ទៅឱ្យតតិយជន(ដែលត្រូវជាក្មួយរបស់កូនបំណុល) ។

### ១.៣. បន្ទុកសោហ៊ុយចំណាយលើសលុបរបស់ម្ចាស់បំណុល

នៅក្នុងដំណើរការនីតិវិធីចាត់ចែងជាបណ្ដោះអាសន្នចំពោះអចលនវត្ថុ គឺម្ចាស់បំណុលអ្នកចំណាយសោហ៊ុយដោយសារតែសំណុំចាត់ចែងជាបណ្ដោះអាសន្នចំពោះអចលនវត្ថុជាសំណុំរឿងជាប្រភេទនៃមួយនៃសំណុំរឿងរដ្ឋប្បវេណី នីតិវិធីចាត់ចែងជាបណ្ដោះអាសន្នចំពោះអចលនវត្ថុ បន្ទុកសោហ៊ុយចំណាយ គឺជាការចំណាយរបស់ភាគីដើម្បីអោយតុលាការក្នុងការអនុវត្ត ដោយសារប្រភេទសំណុំរដ្ឋប្បវេណីខុសពីសំណុំរឿងព្រហ្មទណ្ឌ។ សំណុំរឿងរដ្ឋប្បវេណីតម្រូវអោយភាគីធ្វើការដំណើរការនីតិវិធីដោយខ្លួន ដោយប្រភេទសំណុំរឿងរដ្ឋប្បវេណី គឺជានីតិវិធីស្វែងរកយុត្តិធម៌ ដោយផ្អែកលើភស្តុតាងដែលភាគីបានធ្វើការដាក់មកកាន់តុលាការ ឬងសំណុំរឿងព្រហ្មទណ្ឌ គឺស្វែងរកយុត្តិធម៌ដោយដំណើរការនីតិវិធីដោយតុលាការ។

បន្ទុកសោហ៊ុយចំណាយ លើការដាក់ពាក្យសុំរហូតដល់ចេញដីកាសម្រេច នៅក្នុងការចំណាយនេះគឺជាការចំណាយអំពីដំណើរការនីតិវិធីទាំងស្រុង ដើម្បីធ្វើការទាមទារសិទ្ធិដែលជាម្ចាស់បំណុល ក្នុងការពឹងពាក់មកកាន់តុលាការដើម្បីអោយតុលាការស្វែងរកយុត្តិធម៌ដោយផ្អែកលើភស្តុតាង។

បន្ទុកសោហ៊ុយចំណាយ អ្នកអំណាងដោយអាណត្តិ(មេធាវី) អោយមកធ្វើការការពារផលប្រយោជន៍ដោយសារក្នុងករណីនេះ ម្ចាស់បំណុលភាគច្រើនមិនសូវមានការយល់ដឹងអំពីនីតិវិធី នេះច្បាស់ដោយសារវាមានលក្ខណៈស្មុគស្មាញ ក្នុងការអនុវត្តនៃដំណើរការនីតិវិធី។

បន្ទុកសោហ៊ុយចំណាយ ដែលជាប្រាក់ប្រដាប់ក្តី ដែលជាតម្លៃនៃកម្មវត្ថុនៃបណ្តឹង ដោយផ្អែកលើមូលដ្ឋាននៃផលប្រយោជន៍ដែលបានទាមទារក្នុងបណ្តឹងនោះ ហើយប្រាក់ប្រដាប់ក្តីនេះ ការដាក់ពាក្យសុំចេញដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្នចំពោះអចលនវត្ថុត្រូវបង់ពន្ធតែ៥,០០០(ប្រាំពាន់)រៀលជាប្រាក់ប្រដាប់ក្តីតុលាការ។

ក្នុងករណីដែលម្ចាស់បំណុលមិនបានធ្វើការបង់ពន្ធ តុលាការនឹងធ្វើការច្រានចោលពាក្យសុំនោះ ក្នុងករណីខ្លះដោយសារការចំណាយលើសលុបពេកក្នុងដំណើរការនីតិវិធី មានការបោះបង់ចោលក្នុងការទាមទារសិទ្ធិដោយសារ ការចំណាយលើសលុបនេះ ។

បន្ទុកសោហ៊ុយចំណាយក្នុងការពឹងពាក់សេវាមេធាវី ដើម្បីការពារផលប្រយោជន៍របស់ខ្លួន។

បន្ទុកសោហ៊ុយចំណាយក្នុងការធ្វើដំណើរសម្រាប់រត់ដីកាសម្រេចរក្សាការពារ។

បន្ទុកសោហ៊ុយចំណាយកបង់ពន្ធរដ្ឋបាលច្រកចេញចូល តាមប្រភេទនៃអចលវត្ថុ (ប្លង់រឹង បង់ចំនួន ១សែនរៀល ប្លង់ទុន បង់ចំនួន៥សែនរៀល) ។

## ១.៤. ការបញ្ជូនដីការក្សាការពារខុសភូមិសាស្ត្រដែនដី

តាមមាត្រា២៤៦នៃក្រមនីតិវិធីរដ្ឋប្បវេណីពេលដែលម្ចាស់បំណុលដាក់ពាក្យសុំដីកាសម្រេច (ចាត់ចែងជាបណ្តោះអាសន្នចំពោះអចលនវត្ថុបានរួចរាល់ហើយ)ក្រឡាបញ្ជី មានអង្គាសាលា នឹងមន្រ្តីប្រៃសនី(អនុវត្តមន្រ្តីជាប់កិច្ចសន្យា)ទទួលបន្ទុកបញ្ជូនទៅឱ្យកូនបំណុលប៉ុន្តែការបញ្ជូនខ្លះនៅពេលនោះមិនបានទៅដល់កូនបំណុលដោយសារខុសអាសយដ្ឋានរបស់កូនបំណុលនៅខេត្តកណ្តាល(ស្រុកឈើខ្មៅទៅក្រុងសំពៅលូន) មានការប្រែប្រួលភូមិសាស្ត្រដែនដីជាហេតុនាំឱ្យដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្នចំពោះអចលនវត្ថុ។

ក្នុងដំណាក់កាលនៃការបញ្ជូនដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្នចំពោះអចលនវត្ថុ ទៅកាន់ភាគីបានធ្វើការកំណត់អំពីអាសយដ្ឋាន របស់កូនបំណុល តាមទម្រង់នៃពាក្យស្នើសុំចេញដីកាសម្រេចរបស់ម្ចាស់បំណុល ប៉ុន្តែការបញ្ជូននេះមានលក្ខណៈប្រែប្រួលដោយសារ ដែនដីដែលមានសមត្ថកិច្ចបានធ្វើការផ្លាស់ប្តូរកាលពីក្នុងអំឡុងពេលដំណើរការនីតិវិធី តុលាការដែលមានសមត្ថកិច្ចមានការផ្លាស់ប្តូរឈ្មោះ ពីឃុំទៅជាសង្កាត់

បែបនេះហើយធ្វើឱ្យមានការប្រែប្រួលសមត្ថកិច្ច ដែលនាំឱ្យមានការបង្វិលដីកាសម្រេចនោះមកវិញ ត្រូវការចំណាយពេលក្នុងកែតម្រូវនៃដីកាសម្រេចនោះ ។

**ឧទាហរណ៍៖** ករណីរកិល ឬពង្រីកដែនដីនៃរាជធានីភ្នំពេញ។ ស្រុកមួយចំនួនរបស់ខេត្តកណ្ដាលត្រូវប្រែមកជាខណ្ឌស្ថិតក្រោមការគ្រប់គ្រងរបស់រដ្ឋបាលរាជធានីភ្នំពេញ ដោយសារការប្រែប្រួលសមត្ថកិច្ចដែនដីនេះអាចនាំឱ្យមានការភ័ន្តច្រឡំក្នុងការកំណត់អំពីការចេញដីកាបញ្ជូន (អរិយក្សត្រ ទៅជាក្រុងអរិយក្សត្រ)។

ក្នុងករណី លោក«ក»បានធ្វើការដាក់ពាក្យសុំចេញដីកាសម្រេចរក្សាការពារ(ចាត់ចែងជាបណ្ដោះអាសន្នចំពោះអចលនវត្ថុ) ដែលកម្មវត្ថុនៃវិវាទស្ថិតនៅក្នុងខេត្តព្រះសីហនុ(ឃុំឧកញ៉ាហេង) ដំណើរការនៃការដាក់ពាក្យសុំចេញដីកាសម្រេចរក្សាការពារ(ចាត់ចែងជាបណ្ដោះអាសន្នចំពោះអចលនវត្ថុ)នៅថ្ងៃទី១៥ខែសីហាឆ្នាំ២០២៤ ក្នុងនោះនៅថ្ងៃទី២៨ ខែសីហា ឆ្នាំ២០២៤ បានចេញអនុក្រឹត្យ[74] ស្ដីពីការបង្កើតក្រុងកំពុងសោមនៃខេត្តព្រះសីហនុដោយបានធ្វើការកំណត់អំពីឃុំចំនួន៥ទៅជាសង្កាត់ ដូចក្នុងករណីនេះកម្មវត្ថុនៃវិវាទ(អចលនវត្ថុ)ដែលស្ថិតនៅក្នុងឃុំឧកញ៉ាហេង។ក្នុងករណីនេះ លោក«ក»ត្រូវធ្វើការកែប្រែអំពីចំណុចដែលកំណត់អំពីកម្មវត្ថុនៃវិវាទស្ថិតនៅពីឃុំមកជាសង្កាត់វិញ។

## ១.៥. កូនបំណុលមិនគោរពតាមសេចក្ដីសម្រេចរបស់តុលាការ

ជាគោលការណ៍នៅពេលដែលម្ចាស់បំណុលដាក់ពាក្យស្នើសុំ(ចាត់ចែងជាបណ្ដោះអាសន្នចំពោះអចលនវត្ថុ)នៅពេលដែលតុលាការបានចេញឱ្យម្ចាស់បំណុលរួចរាល់ហើយ (កូនបំណុលមិនគោរពតាមសេចក្ដីសម្រេច ចាត់ចែងជាបណ្ដោះអាសន្នចំពោះអចលនវត្ថុនឹងនោះទេ មិនគោរពតាមសេចក្ដីសម្រេចចាត់ចែងជាបណ្ដោះអាសន្នចំពោះអចលនវត្ថុរបស់តុលាការ ។

**ឧទាហរណ៍៖** លោក «ក» បានដាក់ពាក្យសុំចេញដីកាសម្រេចចាត់ចែង(ជាបណ្ដោះអាសន្នចំពោះអចលនវត្ថុ) ដោយសារខ្លាចលោក «ខ» ជាកូនបំណុលត្រូវបានកម្រិតសិទ្ធិក្នុងការចាត់ចែងដូចជា ការលក់ ដូរធ្វើប្រទានកម្ម ជាអាទិ៍ ឬដាក់ ប្រាតិភោគដូចជា ហ៊ីប៉ូតែក ជាអាទិ៍ និងការចាត់ចែងផ្សេងទៀត។នៅពេលដែលធ្វើការបញ្ជូនដីកាសម្រេច(ហាមឃាត់ការចាត់ចែងជាបណ្ដោះអាសន្នចំពោះអចលនវត្ថុ) ទៅកាន់កូនបំណុល លោក«ខ»មិនធ្វើការគោរពតាមខ្លឹមសារនៃដីកាសម្រេចដែលតុលាការបានចេញ។

ពេលដែលតុលាការបានចេញដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្នចំពោះអចលនវត្ថុភាគីត្រូវគោរពតាមសេចក្ដីសម្រេចរបស់តុលាការ កូនបំណុលមានកាតព្វកិច្ចត្រូវគោរពតាមខ្លឹមសារនៃដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្នចំពោះអចលនវត្ថុប៉ុន្តែក្នុងករណីខ្លះ ទោះតុលាការបានចេញដីកាសម្រេចក្នុងការហាមឃាត់មិន

[74] អនុក្រឹត្យ ស្ដីពីការបង្កើតក្រុងកំពុងសោមនៃព្រះរាជាណាចក្រកម្ពុជា

ឱ្យកូនបំណុលធ្វើសកម្មភាពកំណត់ជាក់លាក់ណាមួយ លើកម្មវត្ថុដែលកម្មវត្ថុនៃវិវាទ ប៉ុន្តែកូនបំណុលនៅតែមិនធ្វើការគោរពតាមដីកាសម្រេចនោះ។

**ឧទាហរណ៍៖** តុលាការបានចេញដីកាសម្រេចក្នុងការហាមឃាត់មិនឱ្យកូនបំណុលធ្វើការផ្ទេរការកាន់កាប់ទៅកាន់តតិយជន។

# ផ្នែកទី២៖ ដំណោះស្រាយ

## ២.១. ការបង្កើត និងផ្សព្វផ្សាយច្បាប់

នៅពេលដែលមានភាពខ្វះចន្លោះនៃច្បាប់បានកើតឡើងស្ថាប័នដែលពាក់ព័ន្ធនឹងធ្វើការរួមគ្នាក្នុងការបង្កើតច្បាប់ដើម្បីធ្វើការដោះស្រាយបញ្ហាចំពោះមុខដែលកំពុងជួបប្រទះ។ក្នុងនោះលិខិតបទដ្ឋានគតិយុត្តផ្សេងៗដូចជាសេចក្ដីពន្យល់ក្រមនីតិវិធីរដ្ឋប្បវេណីសេចក្ដីកំណត់ចំពោះមាត្រានីមួយៗនៃក្រមនីតិវិធីរដ្ឋប្បវេណីនឹងឯកសារផ្សេងទៀតដែលជាជំនួយស្មារតីក្នុងសិក្សាការចាត់ចែងរក្សាការពារអោយកាន់តែមានប្រសិទ្ធិភាពខ្លឹមសារនៅក្នុងបទដ្ឋានគតិយុត្តទាំងនោះមានការបកស្រាយលម្អិតអំពីគោលបំណងនីមួយៗនៅក្នុង គន្លី និងផ្នែកនីមួយៗអោយមានភាពស៊ីជម្រៅថែមទាំងភ្ជាប់ឧទាហរណ៍មកបញ្ជាក់ផងដែរ។

**ឧទាហរណ៍៖** បង្កើតមាត្រាដែលកំណត់អំពី សិទ្ធិ នឹងទំនាក់ទំនងគតិយុត្ត អោយមានភាពច្បាស់លាស់តាមប្រភេទរក្សាការពារនីមួយៗ និងថែមទាំងធ្វើការកំណត់ថេរវេលានៅក្នុងពាក្យសុំតវ៉ាចំពោះដីកាសម្រេចរក្សាការពារ

ការផ្សព្វផ្សាយមានលក្ខណៈជាច្រើនទម្រង់ ដោយសារបច្ចុប្បន្នបច្ចេកវិទ្យាមានការជឿនលឿនដែលនាំអោយការផ្សព្វផ្សាយកាន់តែមានភាពទូលំទូលាយ។ ហើយច្បាប់ដែលពាក់ព័ន្ធនឹងផ្នែករក្សាការពារប្រភេទនេះការផ្សព្វផ្សាយ ដោយធ្វើការផ្សព្វផ្សាយតាមកិច្ចពិភាក្សាដែលរៀបចំតាមស្ថាប័នផ្សេងៗ ដូចជាគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា [75] តែងតែធ្វើការផ្សព្វផ្សាយអំពីប្រភេទរក្សាការពារនេះទៅអោយប្រជាពលរដ្ឋមានការយល់ដឹងកាន់តែទូលំទូលាយអំពីរក្សាការពារនេះ ដោយអោយប្រជាពលរដ្ឋមានការយល់ដឹងអំពីផ្នែកនេះ នៅពេលដែលមានបញ្ហានេះបានកើតឡើងប្រជាពលរដ្ឋនឹងបានដឹងខ្លះៗ អំពីយន្តការនឹងការដោះស្រាយអំពីបញ្ហាកំពុងតែជួបប្រទះ។

បច្ចុប្បន្នមានត្រឹមតែប្រកាសស្ដីពីតួនាទីរបស់អជ្ញាសាលា គួរណាស់តែឆាប់បង្កើតជាច្បាប់ក្នុងការកំណត់អំពីតួនាទី ភារកិច្ច ហើយរួមទាំងក្នុងការកំណត់ចំណាយសោហ៊ុយក្នុងដំណើរការនីតិវិធីរបស់អាជ្ញាសាលាជាអាទិ៍ ក្នុងនោះក៏ត្រូវតែកំណត់ថេរវេលាក្នុងការអនុវត្តរបស់តួនាទីអាជ្ញាសាលានៅពេលដែលចុះអនុវត្ត។

**ឧទាហរណ៍៖** នៅពេលដែលទទួលដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្នចំពោះអចលនវត្ថុ (ហាមឃាត់ការផ្ទេរការកាន់កាប់)។

ក្នុងមាត្រាដែលស្ដីអំពីការចាត់ចែងរក្សាការពារ មិនមានមាត្រាក្នុងការកំណត់អំពី ភាពចាំបាច់ទៅតាមប្រភេទរក្សាការពារនីមួយៗ និងសិទ្ធិក្នុងការទាមទារ រួមទាំងកំណត់អំពីទំនាក់ទំនងគតិយុត្តផងដែរ។

[75] គេហទំព័រផ្លូវការរបស់គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ដែលបង្កើតកិច្ចពិភាក្សា កាលពីថ្ងៃទី ០១ខែសីហា ឆ្នាំ២០២៣ ស្ដីពី«ដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្នចំពោះចំពោះវត្ថុដែលជាកម្មវត្ថុនៃវិវាទ» ។

គួរណាស់បង្កើតជាច្បាប់ក្នុងការកំណត់ថេរវេលា ថាប្រភេទរក្សាការពារនីមួយៗត្រូវចំណាយពេលប៉ុន្មាន ហើយរួមទាំងថវិកាចំនួនប៉ុន្មាន។

មួយវិញទៀត ដោយសារតែឃើញមានប្រជាពលរដ្ឋតែងតែចូលចិត្តក្នុងការមើលជាខ្សែភាពយន្ត បែបនេះ ហើយគួរតែមន្ត្រីពាក់ព័ន្ធ ធ្វើការរួមគ្នាក្នុងបង្កើតជាខ្សែភាពយន្ត ឬក៏វីដេអូខ្លីៗដែលនិយាយអំពីប្រធានបទរក្សាការពារប្រភេទអោយបានកាន់តែច្រើននឹងទូលំទូលាយ ដើម្បីអោយប្រជាពលរដ្ឋមានការយល់ដឹងកាន់តែច្រើន។

ដើម្បីឱ្យមានភាពទូលំទូលាយនៃការស្វែងយល់ ឬអាចផ្តល់ភាពងាយស្រួលក្នុងការស្វ័យសិក្សាបាន ដោយខ្លួនឯងតាមរយៈរួមមានៈ

ការផ្សព្វផ្សាយផ្នែកច្បាប់តាមរយៈសិក្ខាសាលាអនឡាញ៖ ចំពោះប្រជាពលរដ្ឋមួយចំនួនដែលមានឆន្ទៈក្នុងការចូលរួមស្វែងយល់បន្ថែមអំពីផ្នែកច្បាប់ ប៉ុន្តែពុំមានពេលគ្រប់គ្រាន់ក្នុងការចូលរួមដោយផ្ទាល់ទេនោះយុគ្គ-សម័យកាលនេះ គឺមានបច្ចេកវិទ្យាកាន់តែទំនើបដោយអាចមានការទំនាក់ទំនងគ្នា តាមរយៈប្រព័ន្ធអេឡិចត្រូនិចដែលអាចបង្ហាត់បង្ហាញ និងសន្ទនាគ្នាបានប្រកបដោយភាពងាយស្រួល ហេតុនេះដើម្បីការផ្សព្វផ្សាយផ្នែកច្បាប់ឱ្យមានភាពរីកដុះដាល និងមានការអភិវឌ្ឍន៍បន្ថែមទៅលើវិស័យច្បាប់។

ការផ្សព្វផ្សាយផ្នែកច្បាប់ជាឯកសារតម្កល់៖ ការចងក្រងជាឯកសារច្បាប់ ក្នុងប្រទេសកម្ពុជាយើងស្ថិតនៅក្នុងភាពតូចចង្អៀតនៅឡើយទេ ដើម្បីឱ្យបើកចំហចំពោះន័យច្បាប់ឱ្យងាយយល់ដល់ ប្រជាពលរដ្ឋ ឬនិស្សិតឬអ្នកច្បាប់ជាដើម ដោយមានឆន្ទៈក្នុងការស្វែងយល់នូវចំណេះដឹងផ្នែកច្បាប់បន្ថែម។ ចំពោះឯកសារភាគច្រើនមានតម្កល់ នៅបណ្ណាល័យអាចហៅបានថា គឺជាឃ្លាំងសម្រាប់តម្កល់នូវរាល់ឯកសារដែលមានការតាក់តែងជាអត្ថបទ និងអាចឧបាយជាកណ្តាលក្នុងការផ្សព្វផ្សាយផ្នែកច្បាប់មួយឱ្យមានភាពទូលំទូលាយ។

ការផ្សព្វផ្សាយផ្នែកច្បាប់តាមរយៈបណ្តាញសង្គម៖ នាពេលសម័យនេះ គឺមានភាពជឿនលឿនក្នុងការធ្វើទីផ្សារនៃការផ្សព្វផ្សាយផ្នែកច្បាប់ជូនប្រជាពលរដ្ឋគ្រប់មជ្ឈដ្ឋាន ដោយមិនកំណត់ទៅលើ ឋានៈ ឬ វ័យនៃចូលរួមក្នុងការស្វែងយល់បន្ថែម។ ដើម្បីឱ្យមានការយល់ដឹងបន្ថែមអំពីនីតិវិធីច្បាប់ផ្នែករដ្ឋប្បវេណីនៃប្រព័ន្ធតុលាការតាមរយៈបណ្តាញសង្គមទៅតាមមធ្យោបាយដូចជាៈ ការផ្សព្វផ្សាយតាមវិទ្យុ ឬការផ្សព្វផ្សាយតាមរយៈកាសែត ឬការផ្សព្វផ្សាយតាមទស្សនាវដ្តី ឬការផ្សព្វផ្សាយតាមរយៈទូរទស្សន៍ ឬការផ្សព្វផ្សាយតាមបណ្តាញសង្គមមានដូចជាៈ ហ្វេសប៊ុក (Facebook) តិកតុក (Tiktok) ឡាញ(Line) ជាដើមដោយឱ្យមានទូលំទូលាយនៃការផ្សព្វផ្សាយផ្នែកច្បាប់។

បន្ថែមទៀតនោះ ក្រសួងយុត្តិធម៌ ឬ គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ឬ រាជបណ្ឌិត្យសភាជាអាទិ៍គួរគប្បីធ្វើការបើកវគ្គបណ្តុះបណ្តាលទៅតាម ស្រុក/ភូមិ ឃុំ/សង្កាត់ រាជធានី/ខេត្ត ដល់ប្រជាពលរដ្ឋ ដើម្បីលើកតម្កើនលើវិស័យផ្នែកច្បាប់ និងអាចជាតាមមធ្យោបាយដូចជាៈ

ការបើកវគ្គបណ្តុះបណ្តាលរយៈពេលខ្លី និងវែង៖ ការបង្កើនកម្មវិធីវគ្គបណ្តុះបណ្តាលផ្នែកច្បាប់ មានរយៈពេលខ្លីត្រឹមតែចំណាយរយៈពេលបួនសប្តាហ៍ ក៏អាចផ្តល់នូវចំណេះដឹងជាមូលដ្ឋានគ្រឹះជូនដល់ប្រជាពលរដ្ឋបានគ្រប់មជ្ឈដ្ឋានផងដែរ ហើយក៏ជាផ្នែកមួយនៃការផ្សព្វផ្សាយច្បាប់ឱ្យមានភាពទូលំទូលាយ។ ប៉ុន្តែចំពោះការបើកវគ្គបណ្តុះបណ្តាលផ្នែកច្បាប់នេះ គួរគប្បីមិនតម្រូវឱ្យបង់ថ្លៃកម្រៃ ឬអាចបង់ទៅតាមវិភាគទានរបស់សិក្ខាកាមដែលមានឆន្ទៈក្នុងការចូលរួមវគ្គបណ្តុះបណ្តាលនេះ។ ការបង្កើនកម្មវិធីវគ្គបណ្តុះបណ្តាលផ្នែកច្បាប់ មានរយៈពេលវែងគឺត្រូវចំណាយរយៈពេល(០៦)ប្រាំមួយខែ ដើម្បីធ្វើបង្ហាត់បង្ហាញអំពីលំហូរនៃនីតិវិធីច្បាប់មួយផ្នែកនៃប្រព័ន្ធតុលាការក្នុងការយល់ដឹងអំពីតួនាទី និងមុខងាររបស់មន្ត្រីក្រសួងយុត្តិធម៌ ឬមន្ត្រីតុលាការ ឬស្ថាប័នពាក់ព័ន្ធជាអាទិ៍។ ហើយការផ្សព្វផ្សាយប្រព័ន្ធតុលាការអាចរួមចំណែកនៃការអភិវឌ្ឍវិស័យច្បាប់ និងអាចបណ្តុះចំណេះដឹងបន្ថែមដល់ប្រជាពលរដ្ឋដែលមានការយល់ដឹងនៅមានកម្រិត លើសពីនេះទៅទៀត ប្រជាពលរដ្ឋនឹងមានទំនុកចិត្តកាន់ខ្លាំង ចំពោះការដោះស្រាយតាមប្រព័ន្ធតុលាការកម្ពុជា ព្រោះប្រជាពលរដ្ឋបានទទួលនូវការយល់អំពីនីតិវិធីមួយចំនួនក្នុងដំណើរការនៃតុលាការអនុវត្ត។

## ២.២. ការពន្លឿននីតិវិធីនៃការអនុវត្តចាត់ចែងជាបណ្តោះអាសន្នចំពោះអចលនវត្ថុ

ដូចនៅក្នុងប្រភេទនៃរក្សាការពារ (ចាត់ចែងជាបណ្តោះអាសន្នចំពោះអចលនវត្ថុ) ម្ចាស់បំណុលបានធ្វើការដាក់ពាក្យសុំចេញដីកាសម្រេចរក្សាការពារដើម្បីការពារផលប្រយោជន៍របស់ខ្លួន ប៉ុន្តែតុលាការដំណើរការនីតិវិធីនៃការចេញដីកាសម្រេចមានភាពយឺតយ៉ាវ ក្នុងករណីខ្លះអត់ចេញដីកាសម្រេច បែបនេះហើយតុលាការត្រូវធ្វើការពន្លឿនឱ្យមានភាពលឿនប្រសើរ ហើយថែមទាំងប្រកបដោយប្រសិទ្ធិភាពផងចំពោះដំណើរការនៃការដាក់ពាក្យសុំចេញដីកាសម្រេច។

ដូចនៅក្នុងសំណុំរឿងការចាត់ចែងជាបណ្តោះអាសន្ន(ចំពោះអចលនវត្ថុ) មាននៅពេលដែលដាក់ពាក្យសុំចេញដីកាសម្រេចការចាត់ចែងជាបណ្តោះអាសន្នចំពោះអចលនវត្ថុ ម្ចាស់បំណុល(អ្នកដាក់ពាក្យសុំ)។

**ឧទាហរណ៍៖** លោក«ក»បានធ្វើការដាក់ពាក្យសុំឱ្យចេញដីកាសម្រេចរក្សាការពារ(ការចាត់ចែងជាបណ្តោះអាសន្នចំពោះអចលនវត្ថុ «ហាមឃាត់ការផ្ទេរការកាន់កាប់ទៅលើអចលនវត្ថុ») នៅពេលដែលអំឡុងពេលដំណើរការនីតិវិធី ដោយសារវាមានលក្ខណៈស្មុគស្មាញ ដែលធ្វើឱ្យការផ្ទេរអចលនវត្ថុ ដែលជាកម្មវត្ថុនៃវិវាទទៅឱ្យតតិយជន ។

គួរណាស់តែត្រូវមានកំណែទម្រង់អំពីដំណើរការនីតិវិធី ឱ្យមានភាពលឿន រហ័ស នឹងប្រកបដោយប្រសិទ្ធិភាពដើម្បីការពារផលប្រយោជន៍របស់ភាគី។

ដូចក្នុងករណីដែលម្ចាស់បំណុល មិនមានភាពច្បាស់លាស់អំពីគោលបំណងថា ចង់បានអ្វីឱ្យពិតប្រាកដគោលបំណងឱ្យសងជាប្រាក់? គ្មានគោលបំណងឱ្យសងជាប្រាក់?(ឱ្យធ្វើការប្រគល់អចលនវត្ថុដែលជាកម្មវត្ថុនៃ

វិវាទត្រឡប់មកវិញ។ ដោយសារតែបែបនេះហើយទើបធ្វើឱ្យដំណើរការនីតិវិធីមានលក្ខណៈស្មុគស្មាញ ត្រូវចំណាយពេលវេលាជាច្រើននៅក្នុងនីតិវិធី។

ក្នុងនោះសមត្ថកិច្ចដែលពាក់ព័ន្ធគួរណាស់ធ្វើការផ្សព្វផ្សាយតាមរយៈដែលអាចងាយស្រួលបានដូចជា៖ (បង្កើតជាខ្សែភាពយន្ត ឬជាវីដេអូខ្លីដែលនិយាយអំពី ប្រភេទនៃរក្សាការពារ(ការចាត់ចែងជាបណ្ដោះចំពោះអចលនវត្ថុ ឬចលនវត្ថុ)ដើម្បីជាយន្តការក្នុងការផ្សព្វផ្សាយឱ្យមានទូលំទូលាយក្នុងការឱ្យប្រជាពលរដ្ឋមានការយល់ដឹងអំពីច្បាប់កាន់តែច្រើនដោយសារបច្ចុប្បន្នជាសម័យឌីជីថល។

មួយវិញទៀតដូចក្នុងករណី នៅពេលដែលទទួលបានដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្ន(ចំពោះអចលនវត្ថុ) ប៉ុន្តែមិនអាចធ្វើការអនុវត្តបានដោយសារ នៅក្នុងដំណើរការនីតិវិធីមានលក្ខណៈស្មុគស្មាញ ដែលនាំឱ្យមានការផ្ទេរកម្មសិទ្ធិនៃអចលនវត្ថុដែលកម្មវត្ថុនៃវិវាទ(ដីមានច្រើនកន្លែង)ទៅឱ្យតតិយជនរួចរាល់។

**ឧទាហរណ៍៖** លោក«ក»ដាក់ពាក្យសុំចេញដីកាសម្រេចរក្សាការពារ(ចាត់ចែងជាបណ្ដោះអាសន្នចំពោះអចលនវត្ថុ «ហាមឃាត់ការផ្ទេរការកាន់កាប់») ដោយកម្មវត្ថុនៃវិវាទដែលជាអចលនវត្ថុមានច្រើនកន្លែង(ភ្នំពេញ, បាត់ដំបង,ព្រះសីហនុ,សៀមរាប,ស្វាយរៀង,តាកែវ) លោក«ក» បានឈ្នះក្តី ហើយយកដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្ន(ហាមឃាត់ការផ្ទេរការកាន់កាប់)យកទៅអនុវត្ត។ ប៉ុន្តែនៅក្នុងនោះអចលនវត្ថុដែលស្ថិតនៅក្នុងខេត្តតាកែវបានធ្វើការផ្ទេររួចរាល់ មុននឹងដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្ន(ចំពោះអចលនវត្ថុ«ហាមឃាត់ការផ្ទេរការកាន់កាប់») កម្មវត្ថុនៃវិវាទ(អចលនវត្ថុ)បានធ្វើការផ្ទេរកម្មសិទ្ធិបានរួចរាល់ទៅឱ្យតតិយជន(ដែលត្រូវជាក្មួយរបស់កូនបំណុល) ។

ក្នុងដំណើរការនីតិវិធីដោយសារកម្មវត្ថុនៃវិវាទ(អចលនវត្ថុ) ស្ថិតនៅច្រើនកន្លែងបែបនេះនៅពេលដែលដំណើរការនីតិវិធីគួរណាស់តែមានវិធានការទុកមុនខ្លាចមានការប្រែប្រួលដូនស្ថានភាពនេះជាដើម។

ដោយសារមានភាពយឺតយ៉ាវក្នុងនីតិវិធី បែបនេះហើយតុលាការតែងតែធ្វើការពន្លឿននីតិវិធី ដើម្បីជៀសវាងអំពីការខូចប្រយោជន៍របស់កូនបំណុល នឹងសេចក្តីទុកចិត្តរបស់ប្រជាពលរដ្ឋ។ ដូចជាថ្មីៗនេះនាថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ២០២៣ នេះ, ឯកឧត្តម កើត រិទ្ធ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និង ជាសមាជិកទី១ នៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម បានអញ្ជើញជាអធិបតីភាពដ៏ខ្ពង់ខ្ពស់ ក្នុងពិធីប្រកាសផ្ទេរ និងចូលកាន់មុខតំណែងរបស់ឯកឧត្តម ងិន ពេជ ជាព្រះរាជអាជ្ញានៃអយ្យការអមសាលាដំបូងខេត្តត្បូងឃ្មុំ ជំនួស ឯកឧត្តម ឡុង ហុកម៉េង ដែលត្រូវបានផ្ទេរភារកិច្ចទៅជា ព្រះរាជអាជ្ញានៃអយ្យការអមសាលាដំបូងខេត្តរតនគិរី។

ឆ្លៀតនាឱកាសនោះ ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី បានគូសបញ្ជាក់ថា ផ្អែកតាមការប្រគល់ភារកិច្ចរបស់សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត ប្រមុខរាជរដ្ឋាភិបាល, ក្រសួងយុត្តិធម៌ បាននិងកំពុងរៀបចំផែនការសកម្មភាពសម្រាប់អនុវត្តវិធានការគន្លឹះទី៥ សំដៅពង្រឹង និងលើកកម្ពស់គុណភាព និងប្រសិទ្ធភាពនៃប្រព័ន្ធយុត្តិធម៌ ដើម្បី

សម្រេចឱ្យបានចេញជាលទ្ធផលនៅក្នុងនីតិកាលទី ៧ នៃរដ្ឋសភា នូវកិច្ចការអាទិភាពគឺ (ទី១)-ការបង្កើតយន្តការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ ដើម្បីជួយសម្រុះសម្រួលដោះស្រាយវិវាទឱ្យបានឆាប់រហ័ស ជាពិសេសវិវាទរបស់ប្រជាពលរដ្ឋនៅមូលដ្ឋាន, (ទី២)-ការជំរុញ និងពន្លឿនការដោះស្រាយសំណុំរឿងក្តីនៅតាមតុលាការឱ្យបានឆាប់រហ័ស និង (ទី៣)-ការត្រួតពិនិត្យ និងការដោះស្រាយភាពមិនប្រក្រតីនៅតាមតុលាការ សំដៅជួយដោះស្រាយរកយុត្តិធម៌ជូនប្រជាពលរដ្ឋ ក៏ដូចជា ការលើកកម្ពស់តម្លាភាព សុចរិតភាព និងភាពត្រឹមត្រូវ ក្នុងការអនុវត្តច្បាប់ និងចំណាត់ការរឿងក្តីដោយតុលាការ។

ឯកឧត្តម កើត រិទ្ធ បានបន្តថា ឆ្លើយតបនឹងការផ្តល់ទំនុកចិត្តដ៏ខ្ពង់ខ្ពស់របស់សម្តេចធិបតីនាយករដ្ឋមន្ត្រី ក្រសួងយុត្តិធម៌បានរៀបចំផែនការសកម្មភាពសម្រាប់យុទ្ធនាការសំខាន់ៗចំនួន ៣ ដែលត្រូវបានចាត់ទុកជាបទបញ្ញា និងទិសដៅការងារដ៏មុតស្រួចដែលត្រូវអនុវត្ត គឺ៖ (ទី១)-យុទ្ធនាការសម្រុះសម្រួលដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ, (ទី២)-យុទ្ធនាការជំរុញ និងពន្លឿនការដោះស្រាយរឿងក្តីនៅតាមតុលាការ និង (ទី៣)-យុទ្ធនាការត្រួតពិនិត្យ និងដោះស្រាយភាពមិនប្រក្រតីនៅតាមតុលាការ។ ជារួម យុទ្ធនាការដ៏មានសារៈសំខាន់ទាំង ៣ នេះ មានសសរស្តម្ភ ចំនួន ២ គឺ សសរស្តម្ភទី១-ការកែទម្រង់លើការដោះស្រាយវិវាទក្នុងប្រព័ន្ធតុលាការនិងសសរស្តម្ភទី២-ការកែទម្រង់លើការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ ដែលសសរស្តម្ភទាំងពីរនេះមាននៅក្នុងច្បាប់ ហើយស្របច្បាប់។

ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ក៏បានគូសបញ្ជាក់ជូនអង្គពិធីអំពីគោលបំណង និងភាពចាំបាច់នានាក្នុងការដាក់ចេញនូវយុទ្ធនាការទាំង ៣ នេះ ដែលមានខ្លឹមសារសង្ខេបដូចខាងក្រោម៖

ទី១-យុទ្ធនាការសម្រុះសម្រួលដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ គឺជាយុទ្ធនាការដែលមានលក្ខណៈស្របទៅនឹងស្ថានភាពជាក់ស្តែងនៅក្នុងសង្គម និងស្របតាមប្រពៃណីរបស់អ្នកស្រុកនៅកម្ពុជា និងមានមូលដ្ឋានគ្រឹះមួយដ៏ធំ គឺនយោបាយឈ្នះ-ឈ្នះ របស់សម្តេចតេជោ ហ៊ុន សែន ដែលបានពន្លត់ភ្លើងសង្គ្រាមដ៏រ៉ាំរ៉ៃ និងការបែកបាក់ជាតិ ដែលកម្ពុជាទទួលបាននូវសុខសន្តិភាពពេញបរិបូរណ៍ ឯកភាពជាតិ និងការបង្រួបបង្រួមអធិបតេយ្យភាព និងបូរណភាពទឹកដី។ យុទ្ធនាការនេះមានគោលបំណងសំខាន់ៗ ចំនួន ៤ គឺ៖ (ទី១)-ជួយកាត់បន្ថយចំនួនសំណុំរឿង និងការកកស្ទះសំណុំរឿងនៅតាមសាលាជម្រះ, (ទី២)-បង្វិតសេវាដោះស្រាយវិវាទឱ្យកាន់តែកៀកនឹងប្រជាពលរដ្ឋនៅមូលដ្ឋាន និង (ទី៣)-ធានាបាននូវភាពសុខដុមរមនាក្នុងសហគមន៍ និងសង្គមជាតិ តាមរយៈការព្យាយាមសម្រុះសម្រួលផ្សះផ្សាបញ្ចប់វិវាទនៅក្រៅប្រព័ន្ធតុលាការ។

ទន្ទឹមនេះ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ក៏បានគូសបញ្ជាក់ថា កាលពីថ្ងៃទី២៧ ខែតុលា ឆ្នាំ២០២៣ សេចក្តីព្រាងព្រះរាជក្រឹត្យស្តីពីការបង្កើត ការរៀបចំ និងកិច្ចដំណើរការរបស់អាជ្ញាធរជាតិដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ ត្រូវបានកិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រីសម្រេចអនុម័តរួចហើយ ហើយក្នុងពេលឆាប់ៗខាងមុខនេះ

អាជ្ញាធរជាតិដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ នេះ ត្រូវបង្កើតឡើង ក្រោយពេល ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុតនៃយើង ទ្រង់ឡាយព្រះហស្តលេខាលើព្រះរាជក្រឹត្យនេះ។ ការបង្កើតអាជ្ញាធរជាតិនេះ គឺដើម្បីបំពេញបន្ថែមលើយន្តការដែលមានស្រាប់ និងអាចឆ្លើយតបនឹងតម្រូវការរបស់ប្រជាជននៅមូលដ្ឋាន ដែលចង់បាននូវដំណោះស្រាយវិវាទមួយ និងជាដំណោះស្រាយវិវាទដែលគូភាគីវិវាទទាំងអស់អាចទទួលយកបាន ហើយអាជ្ញាធរជាតិនឹងរៀបចំឱ្យមានក្រុមចល័តចុះធ្វើការសម្រុះសម្រួលផ្សះផ្សាវិវាទរបស់ប្រជាពលរដ្ឋនៅតាមមូលដ្ឋានតែម្តង។ ទន្ទឹមនេះ, ដើម្បីធានាប្រសិទ្ធភាពខ្ពស់ក្នុងការសម្រុះសម្រួលផ្សះផ្សាវិវាទរបស់អាជ្ញាធរជាតិ ក្របខណ្ឌគតិយុត្តមួយច្បាស់លាស់ សម្រាប់កិច្ចដំណើរការនៃការសម្រុះសម្រួលផ្សះផ្សាវិវាទត្រូវបានកំណត់ ជាពិសេស កំណត់ហេតុព្រមព្រៀងបញ្ចប់វិវាទ នឹងទទួលបានតម្លៃគតិយុត្តជាភស្តុតាងរឹងមាំ និងមានអានុភាពជាលិខិតអនុវត្តដូចសាលក្រម ឬសាលដីកាស្ថាពររបស់តុលាការ។

ទី២-យុទ្ធនាការជំរុញ និងពន្លឿនការដោះស្រាយរឿងក្តីនៅតាមតុលាការ គឺជាយុទ្ធនាការដែលមានទិសដៅធ្វើឱ្យប្រសើរឡើងនូវការផ្តល់សេវាយុត្តិធម៌ជូនដល់ប្រជាពលរដ្ឋឱ្យបានលឿន និងឆាប់រហ័ស ដែលគ្របដណ្តប់ទាំងលើរឿងក្តីរដ្ឋប្បវេណី ទាំងលើរឿងក្តីព្រហ្មទណ្ឌ និង សម្រាប់តុលាការគ្រប់ជាន់ថ្នាក់ ដោយរួមទាំងអង្គការអយ្យការផងដែរ ។

ទី៣-យុទ្ធនាការត្រួតពិនិត្យ និង ដោះស្រាយភាពមិនប្រក្រតីនៅតាមតុលាការ មានគោលបំណងសំខាន់ៗចំនួន ៣ គឺ៖ (១)-ការបង្កើតច្រក និងយន្តការសម្រាប់ទទួលបណ្តឹងអំពីភាពមិនប្រក្រតីនៅតាមតុលាការ ដើម្បីជួយត្រួតពិនិត្យ និង ជួយដោះស្រាយរកយុត្តិធម៌ជូនប្រជាពលរដ្ឋ ពិសេស ប្រជាពលរដ្ឋក្រីក្រ និង ជនងាយរងគ្រោះក្នុងសង្គម, (២)-ការចូលរួមដោះស្រាយភាពអយុត្តិធម៌ និង ភាពមិនប្រក្រតីក្នុងប្រព័ន្ធតុលាការ សំដៅលើកកម្ពស់ភាពយុត្តិធម៌ នៅក្នុងចំណាត់ការរឿងក្តីដោយតុលាការ និង (៣)-ការលើកកម្ពស់តម្លាភាព សុចរិតភាព ភាពស្អាតស្អំ និងភាពត្រឹមត្រូវ នៅក្នុងប្រព័ន្ធតុលាការ ។ ជារួម, យុទ្ធនាការត្រួតពិនិត្យ និងដោះស្រាយភាពមិនប្រក្រតីនៅតាមតុលាការ ផ្តោតការយកចិត្តទុកដាក់លើការត្រួតពិនិត្យលើគុណភាពនៃសេចក្តីសម្រេចរបស់តុលាការ និងប្រសិទ្ធិភាពនៃចំណាត់ការរឿងក្តីរបស់តុលាការ។

ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ក៏បានណែនាំ និងផ្តាំផ្ញើដល់ ឯកឧត្តមប្រធានសាលាដំបូង ឯកឧត្តមព្រះរាជអាជ្ញាថ្មីនៃអយ្យការអមសាលាដំបូងខេត្តត្បូងឃ្មុំ ព្រមទាំងចៅក្រម ព្រះរាជអាជ្ញា ព្រះរាជអាជ្ញារង ក្រឡាបញ្ជី និងមន្ត្រីក្នុងវិស័យយុត្តិធម៌ទាំងអស់ ដូចខាងក្រោម៖

(១)-ត្រូវធ្វើខ្លួនជាបង្អែកមួយប្រកបដោយភាពកក់ក្តៅសម្រាប់ប្រជាពលរដ្ឋ ជាពិសេសប្រជាពលរដ្ឋដែលទទួលរងនូវការរំលោភបំពានដោយអយុត្តិធម៌ ដោយប្រកាន់យកនូវភាពត្រឹមត្រូវ និងយុត្តិធម៌ជាគោលការណ៍. អនុវត្តការងារ ដើម្បីជាកត្តិយសរបស់អង្គភាព និងជាកត្តិយសរបស់ខ្លួនឯងផ្ទាល់ក្នុងនាមជាមន្ត្រីអនុវត្តច្បាប់ ។

(២)-ត្រូវពង្រឹងប្រសិទ្ធភាពចំណាត់ការសំណុំរឿង ឱ្យបានម៉ឺងម៉ាត់ តឹងរ៉ឹង ត្រឹមត្រូវ និងតម្លាភាព ជាអាទិ៍ បទល្មើសគ្រឿងញៀន, ជួញដូរមនុស្សនិងអាជីវកម្មផ្លូវភេទ, បទល្មើសឆក់ប្លន់, និងករណីក្មេងទំនើង ដើម្បីរួមចំណែកអនុវត្ត "គោលនយោបាយភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព" ។ (៣)-ត្រូវរក្សាភាពមិនលំអៀង ដោយវៀរចាកអគតិទាំង ៤ ប្រការគឺ ឆន្ទាគតិ ទោសាគតិ ភយាគតិ និងមោហាគតិ និងត្រូវប្រកាន់យកសុគតិធម៌ទាំង ៥ គឺ វិរិយសម្បយុត្តិ សុចរិតយុត្តិធម៌ បញ្ញត្តិគារវោ សមទណ្ឌោ និង បញ្ញាវុធវិនិច្ឆ័យ នៅពេលជំនុំជម្រះក្តី ។

(៤)-ត្រូវបន្តពង្រឹងសមត្ថភាពមន្ត្រីក្រោមឱវាទ និងមន្ត្រីអនុវត្តច្បាប់ពាក់ព័ន្ធ តាមគ្រប់មធ្យោបាយ, រៀបចំសមាសភាពមន្ត្រីដើម្បីទទួលការបណ្តុះបណ្តាលបន្ត ហើយមន្ត្រីគ្រប់រូបក្នុងវិស័យយុត្តិធម៌ ក៏ត្រូវពង្រឹងសមត្ថ-ភាពរបស់ខ្លួនជាប់ជាប្រចាំ។

(៥)-ត្រូវពង្រឹងគុណភាពនៃការតាក់តែងសាលក្រម/សាលដីកាឱ្យបានត្រឹមត្រូវតាមក្បួនខ្នាត, ត្រូវមានសំអាងហេតុ និងសំអាងច្បាប់ជាមូលដ្ឋានរឹងមាំ ងាយយល់ ច្បាស់លាស់ គ្រប់គ្រាន់ ត្រឹមត្រូវ និងយុត្តិធម៌ ជាសាលក្រម/សាលដីកាគំរូ ស្របតាមច្បាប់ និងនីតិវិធីជាធរមាន ហើយ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ក៏ស្នើសុំឱ្យមន្ត្រីអនុវត្តច្បាប់ដែលមានការពាក់ព័ន្ធ និងអាជ្ញាធរមានសមត្ថកិច្ច សូមមេត្តាផ្តល់កិច្ចសហការពេញលេញ ធានាឱ្យសេចក្តីសម្រេចរបស់តុលាការត្រូវបានអនុវត្តពេញលេញ និងប្រកបដោយប្រសិទ្ធភាព ដើម្បីរួមចំណែកក្នុងការពង្រឹងគោលការណ៍នីតិរដ្ឋនៅកម្ពុជា។

(៦)-ត្រូវប្រកាន់ភ្ជាប់នូវអភិក្រមដ៏ថ្លៃថ្លាទាំង ៥ របស់ សម្តេចតេជោ ហ៊ុន សែន គឺ"ឆ្លុះកញ្ចក់ ងូតទឹក ដុសក្អែល ព្យាបាល និង វះកាត់" និងអភិក្រមទាក់ទងនឹងការកែទម្រង់ទាំង ៤ របស់ សម្តេចធិបតីនាយករដ្ឋមន្ត្រី គឺ "ត្រូវមានចក្ខុវិស័យច្បាស់លាស់ មានការប្តេជ្ញាចិត្តខ្ពស់ មានការចូលរួមដោយស្មោះត្រង់ និងការលះបង់" ក្នុងការអនុវត្តមុខងារ និងភារកិច្ចរបស់ខ្លួន ជាពិសេស ការត្រៀមលក្ខណៈគ្រប់បែបយ៉ាង និងការបង្ហាញនូវភាពជាអ្នកដឹកនាំ ដើម្បីចូលរួមអនុវត្តយុទ្ធនាការសំខាន់ៗទាំង ៣ ដែលនឹងដាក់ចេញដោយក្រសួងយុត្តិធម៌នាពេលខាងមុខ។

ឆ្លៀតក្នុងឱកាសនេះ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី បានក្រើនរំលឹកដល់ឯកឧត្តមព្រះរាជអាជ្ញា ក្នុងនាមជាម្ចាស់បណ្តឹងអាជ្ញា ត្រូវយកចិត្តទុកដាក់តាមដានជាប្រចាំ អំពីនយោបាយព្រហ្មទណ្ឌដែលបានដាក់ចេញដោយរាជរដ្ឋាភិបាលឱ្យបានច្បាស់លាស់ សំដៅចូលរួមអនុវត្តឱ្យមានប្រសិទ្ធភាពខ្ពស់ និងម៉ឺងម៉ាត់ ដើម្បីធានានូវសន្តិសុខ សណ្តាប់ធ្នាប់ និងរបៀបរៀបរយនៅក្នុងសង្គម។ ទន្ទឹមនេះ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី បានគូសបញ្ជាក់ជូនថ្នាក់ដឹកនាំ និងមន្ត្រីរាជការនៃសាលាជម្រះក្តី និងអង្គការអយ្យការអមសាលាជម្រះក្តីគ្រប់ជាន់ថ្នាក់ ក៏ដូចជាមន្ត្រីអនុវត្តច្បាប់ផ្សេងៗ អំពីទិសដៅការងារកែទម្រង់វិស័យយុត្តិធម៌ របស់រាជរដ្ឋាភិបាល ក្នុងនីតិកាលទី ៧ នៃរដ្ឋសភានេះ។ កិច្ចការនេះ នៅតែជាអាទិភាព ដែលជាមុំមួយដ៏សំខាន់ក្នុងចំណោមមុំទាំង ៥ ដែលបង្កើតបានជាស្នូលនៃយុទ្ធសាស្ត្របញ្ចកោណ - ដំណាក់កាលទី១។

## ២.៣. យន្តការក្នុងការកាត់បន្ថយសោហ៊ុយចំណាយ

នៅក្នុងដំណើរការនីតិវិធី ត្រូវចំណាយសោហ៊ុយ តាំងពីការដាក់ពាក្យសុំ រហូតដល់ចេញដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្នចំពោះអចលនវត្ថុ)មានការចំណាយច្រើន ដូចជាសេវាពឹងពាក់មេធាវី ឬអ្នកតំណាងដោយអាណត្តិ មិនបានធ្វើការកំណត់ឱ្យបានច្បាស់លាស់អំពីកម្រៃនៃសេវាពឹងពាក់មេធាវី គួរតែមានវិធានការនឹងច្បាប់ក្នុងការកំណត់ឱ្យបានច្បាស់លាស់ថាតើប្រភេទនៃសំណុំរឿងនីមួយៗត្រូវបង់ប្រាក់កម្រៃក្នុងការពឹងពាក់ចំនួនប៉ុន្មាន ដើម្បីឱ្យភាគីមានលទ្ធភាពក្នុងការជ្រើសរើសដើម្បីជាផលប្រយោជន៍របស់ភាគី។

ពេលចេញដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្នចំពោះអចលនវត្ថុ រួចរាល់ហើយ នៅពេលចុះអនុវត្តម្ចាស់បំណុលត្រូវធ្វើការចំណាយផ្សេងទាំងសេវាធ្វើដំណើរ ចំណាយលើការបរិភោគ ស្នាក់នៅ នឹងរួមទាំងការចំណាយសម្រាប់មន្ត្រីមូលដ្ឋានដែលបានធ្វើការចុះអនុវត្តជាមួយបែបនេះហើយ គួរតែមានវិធានការក្នុងការកំណត់ឱ្យបានច្បាស់លាស់ក្នុងការចំណាយនានាពេលដែលចុះអនុវត្ត គួរតែបង្កើតជាប្រកាសឬអនុក្រឹត្យ ឬការតាក់តែងផ្សេងដើម្បីជាមូលដ្ឋានគ្រឹះក្នុងការកំណត់ឱ្យបានច្បាស់លាស់អំពីការចំណាយនានា។

បន្ទុកក្នុងការចំណាយសោហ៊ុយ ការកូពីឯកសារនានានៅតាមស្ថាប័នតុលាការ គួរតែធ្វើការកំណត់ឱ្យបានច្បាស់លាស់ក្នុងការចំណាយ ។

មន្ត្រីដែលពាក់ព័ន្ធគួរតែមូលមតិជាឯកច្ឆ័នក្នុងការជួយសម្រួលអំពីការចំណាយនានានៅពេលដែលមានបណ្តឹងដែលទាមទារឱ្យតុលាការចូលរួមក្នុងការដោះស្រាយ នឹងឡើងជាវិធានការផ្សេងៗអោយសមស្របតាមបរិបទនៃសង្គមនីមួយៗ។

## ២.៤. ការពង្រឹងនូវការអនុវត្តដីកាបញ្ជូនឱ្យត្រឹមត្រូវតាមភូមិសាស្ត្រដែនដី

នៅពេលដែលទទួលបានម្ចាស់បំណុលទទួលបានដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្នចំពោះអចលនវត្ថុជាស្ថាពរ តុលាការនឹងធ្វើការបញ្ជូនដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្នចំពោះអចលនវត្ថុ ទៅកាន់ភាគី (កូនបំណុល) ប៉ុន្តែការបញ្ជូនខ្លះវាខុសនឹងអាសយដ្ឋានដែនដីរបស់កូនបំណុលដោយសារ ឬការប្រែប្រួលភូមិសាស្ត្រដែនដី។

អាសយដ្ឋាន របស់កូនបំណុល តាមទម្រង់នៃពាក្យស្នើសុំចេញដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្នចំពោះអចលនវត្ថុរបស់ម្ចាស់បំណុល ប៉ុន្តែការបញ្ជូននេះមានលក្ខណៈប្រែប្រួលដោយសារ ដែនដីដែលមានសមត្ថកិច្ចបានធ្វើការផ្លាស់ប្តូរ កាលពីក្នុងអំឡុងពេលដំណើរការនីតិវិធី តុលាការដែលមានសមត្ថកិច្ចមានការផ្លាស់ប្តូរឈ្មោះ ពីឃុំទៅជាសង្កាត់ បែបនេះហើយធ្វើឱ្យមានការប្រែប្រួលសមត្ថកិច្ច ដែលនាំឱ្យមានការបង្វិលដីកា

សម្រេចនោះមកវិញ ត្រូវការចំណាយពេលក្នុងកែតម្រូវនៃដីកាសម្រេចនោះ ។ ជាក់ស្ដែងរួមមានករណីរកិល ឬពង្រីកដែនដីនៃរាជធានីភ្នំពេញជាដើម។

ដើម្បីជាដំណោះស្រាយដល់ការបញ្ជូនដីកាសម្រេចទៅកាន់ភាគីខុសសមត្ថកិច្ចដែនដី អាជ្ញាធរមានសមត្ថកិច្ចគប្បីចូលរួមសហការនឹងអាជ្ញាធរមូលដ្ឋានដើម្បីកំណត់នូវអាសយដ្ឋាន ភូមិសាស្ត្រដែនដីឱ្យបានច្បាស់លាស់។ ម្យ៉ាងទៀតដើម្បីពន្លឿនដល់នីតិវិធីនៃការបង្វិលដីកាសម្រេចនោះមកវិញ កាត់បន្ថយដល់ការចំណាយពេលក្នុងកែតម្រូវនៃដីកាសម្រេចនោះ គួរមានការបង្កើតនូវអាជ្ញាធរមូលដ្ឋានដើម្បីសម្រួលដល់កិច្ចការនោះតែម្ដង។

## ២.៥. ការបង្កើតយន្តការពិន័យក្នុងករណីកូនបំណុលមិនសហការ

ពេលដែលតុលាការបានចេញដីកាសម្រេចអំពីការចាត់ចែងជាបណ្ដោះអាសន្នចំពោះអចលនវត្ថុភាគីត្រូវគោរពតាមសេចក្ដីសម្រេចរបស់តុលាការ កូនបំណុលមានកាតព្វកិច្ចត្រូវគោរពតាមខ្លឹមសារនៃដីកាសម្រេចអំពីការចាត់ចែងជាបណ្ដោះអាសន្នចំពោះអចលនវត្ថុ ។ ប៉ុន្តែក្នុងករណីខ្លះ ទោះតុលាការបានចេញដីកាសម្រេចក្នុងការហាមឃាត់មិនឱ្យកូនបំណុលធ្វើសកម្មភាពកំណត់ជាក់លាក់ណាមួយ លើកម្មវត្ថុដែលកម្មវត្ថុនៃវិវាទ ប៉ុន្តែកូនបំណុលនៅតែមិនធ្វើការគោរពតាមដីកាសម្រេចនោះ។

ក្នុងករណីដែលមិនគោរពតាមខ្លឹមសារនៃការសម្រេចការចាត់ចែងជាបណ្ដោះអាសន្នចំពោះអចលនវត្ថុនឹង គួរគប្បីបង្កើតជាយន្តការគតិយុត្តដើម្បីដាក់ពិន័យជាទឹកប្រាក់ឱ្យគាត់គោរពតាមសេចក្ដីសម្រេចនឹង។

**ឧទាហរណ៍៖** លោក «ក» បានដាក់ពាក្យសុំចេញដីកាសម្រេចចាត់ចែង(ជាបណ្ដោះអាសន្នចំពោះអចលនវត្ថុ) ដោយសារខ្លាចលោក «ខ» ជាកូនបំណុលត្រូវបានកម្រិតសិទ្ធិក្នុងការចាត់ចែងដូចជា ការលក់ ដូរធ្វើប្រទានកម្ម ជាអាទិ៍ ឬដាក់ ប្រាតិភោគដូចជា ហ៊ីប៉ូតែក ជាអាទិ៍ និងការចាត់ចែងផ្សេងទៀត។នៅពេលដែលធ្វើការបញ្ជូនដីកាសម្រេច(ហាមឃាត់ការចាត់ចែងជាបណ្ដោះអាសន្នចំពោះអចលនវត្ថុ) ទៅកាន់កូនបំណុល លោក«ខ»មិនធ្វើការគោរពតាមខ្លឹមសារនៃដីកាសម្រេចដែលតុលាការបានចេញ។

ចំពោះករណីនេះតុលាការអាចពិចារណាក្នុងការអនុវត្តនូវយន្តការពិន័យជាប្រាក់ ឬការបង្វែរបន្ទុកចំណាយទៅជាបន្ទុករបស់ភាគីជាកូនបំណុលជំនួសភាគីដែលជាម្ចាស់បំណុលវិញ។ យន្តការនេះអាចជំរុញឱ្យកូនបំណុលចូលរួមសហការប្រសើរជាងមុន។

# សេចក្តីសន្និដ្ឋាន

# សេចក្តីសន្និដ្ឋាន

ស្របតាមខ្លឹមសារដែលបានបកស្រាយខាងលើរួចមក គេអាចកំណត់សម្គាល់ថា នីតិវិធីនៃការចាត់ចែងរក្សាការពារ ជានីតិវិធីរដ្ឋប្បវេណីមួយដែលមានគោលបំណងនៅក្នុងការការពារ និងថែរក្សាស្ថានភាពបច្ចុប្បន្នដោយប្រើប្រាស់នូវអំណាចរបស់រដ្ឋ ដើម្បីការពារសិទ្ធិរបស់បុគ្គលណាម្នាក់ នៅពេលដែលមានការបារម្ភថា ការអនុវត្តដោយបង្ខំមិនអាចអនុវត្តទៅបាន ឬមានការលំបាកខ្លាំងក្នុងការអនុវត្តដោយបង្ខំ ដោយសារមានការប្រែប្រួលស្ថានភាពបច្ចុប្បន្ននៃទ្រព្យសម្បត្តិរបស់កូនបំណុលនៃការអនុវត្ត ឬនៅពេលដែលមានការបារម្ភថានឹងមានការខូចខាតធ្ងន់ធ្ងរ ឬគ្រោះថ្នាក់បន្ទាន់ដល់ឋានៈរបស់ភាគីណាមួយ ដោយសារតែមានវិវាទអំពីទំនាក់ទំនងនៃសិទ្ធិ។ លើសពីនេះទៅទៀត គេអាចនិយាយបានថា នីតិវិធីនេះមានចរិតលក្ខណៈជាការបំពេញបន្ថែមទៅលើនីតិវិធីអនុវត្តដោយបង្ខំ ព្រោះថាការរក្សាការពារក៏ជានីតិវិធីអនុវត្តដោយបង្ខំមួយដែរ។ ចរិតលក្ខណៈនៃនីតិវិធីចាត់ចែងអនុវត្តរក្សាការពារមាន ៤ សំខាន់ៗ ដែលរួមមានដូចជា ចរិតលក្ខណៈបណ្តោះអាសន្ន លក្ខណៈបន្ទាន់បង្ខំ លក្ខណៈបន្ទាប់បន្សំ និងលក្ខណៈសម្ងាត់។

ការចាត់ចែងរក្សាការពារ ត្រូវបានគេបែងចែកចេញជា ២ ប្រភេទរួមមាន ការរឹបអូសជាបណ្តោះអាសន្នដែលជាការចាត់ចែងមួយដែលមានកម្រិតនូវការចាត់ចែងទ្រព្យសម្បត្តិរបស់កូនបំណុល ក្នុងគោលដៅដើម្បីរក្សាការពារការអនុវត្តដោយបង្ខំចំពោះសិទ្ធិលើបំណុលដែលមានគោលបំណងឱ្យសងជាប្រាក់ និងការចាត់ចែងជាបណ្តោះអាសន្នចំពោះវត្ថុដែលជាកម្មវត្ថុនៃវិវាទ ជាការចាត់ចែងមួយប្រភេទដែលរក្សាទុកនូវស្ថានភាពបច្ចុប្បន្ន នៃវត្ថុដែលជាកម្មវត្ថុនៃវិវាទ ក្នុងករណីដែលមានការបារម្ភថា ម្ចាស់បំណុលនឹងមិនអាចអនុវត្តសិទ្ធិ ឬនឹងមានការលំបាកយ៉ាងខ្លាំងក្នុងការអនុវត្តសិទ្ធិដោយសារមានការប្រែប្រួលស្ថានភាពបច្ចុប្បន្ននៃវត្ថុនោះ។

ទន្ទឹមនឹងនេះ ដើម្បីអនុវត្តនីតិវិធីនៃការចាត់ចែងរក្សាការពារបាន លុះត្រាមានការដាក់ពាក្យសុំជាលាយលក្ខណ៍អក្សរទៅកាន់តុលាការជាមុនសិន ដែលពាក្យសុំនោះត្រូវបានគេហៅថា ពាក្យសុំឲ្យចេញសេចក្តីសម្រេចរក្សាការពារ។ ហើយការអនុវត្តនីតិវិធីនេះទៀតសោតត្រូវធ្វើឡើងដោយតុលាការ ឬអាជ្ញាសាលាតាមពាក្យស្នើសុំរបស់ភាគី។ តុលាការអនុវត្តរក្សាការពារជាតុលាការដែលមានសមត្ថកិច្ចផ្តាច់មុខ។ ចំណែកឯករណីដែលការអនុវត្តចាត់ចែងរក្សាការពារធ្វើឡើងដោយអាជ្ញាសាលាវិញ ការចាត់ចែងនោះត្រូវធ្វើឡើងដោយសាលាដំបូងដែលអាជ្ញាសាលាស្ថិតនៅ។

# អនុសាសន៍

# អនុសាសន៍

បន្ទាប់ពីការសិក្សាស្រាវជ្រាវកន្លងមក សង្កេតឃើញថាការអនុវត្តនីតិវិធីនៃការចាត់ចែងជាបណ្ដោះ-អាសន្ននៅព្រះរាជាណាចក្រកម្ពុជាមានការកើនឡើងជាច្រើន ពោលគឺស្ទើរតែរៀងរាល់ថ្ងៃ។ នេះក៏ដោយសារតែកំណើនស្ថានភាពគតិយុត្តដែលកើតមានឡើងនៅក្នុងសង្គមនាពេលបច្ចុប្បន្ន ហើយភាគីនៃទំនាក់ទំនងគតិយុត្តទាំងនោះ បង្កើតឱ្យមានបុគ្គលមានបុគ្គលដែលមានសិទ្ធិ និងបុគ្គលដែលត្រូវបំពេញកាតព្វកិច្ច។ នៅពេលដែលភាគីដែលត្រូវបំពេញកាតព្វកិច្ច ពុំបានបំពេញកាតព្វកិច្ចរបស់ខ្លួន នោះវិវាទនឹងកើតមានឡើង។ ក៏ប៉ុន្តែ ទោះបីជាការអនុវត្តនីតិវិធីនេះធ្វើឡើងជាប្រចាំក៏ដោយ ក៏គេនៅសង្កេតឃើញមានកង្វះខាតមួយចំនួនដែលអាចនឹងបំពេញបន្ថែមដើម្បីពង្រឹងនូវការអនុវត្តនីតិវិធីនេះឱ្យបានកាន់តែរលូន និងកាន់តែមានប្រសិទ្ធិភាព។ ដូច្នេះដើម្បីចូលរួមឱ្យដំណើរការនៃការអនុវត្តនីតិវិធីនៃការចាត់ចែងជាបណ្ដោះអាសន្នចំពោះអចលនវត្ថុប្រព្រឹត្តទៅបានប្រសើរ យើងខ្ញុំមានសំណូមពរចំនួន៣ រួមមាន៖

**សំណូមពរទី១៖** រាជរដ្ឋាភិបាល ក៏ដូចជាក្រសួងស្ថាប័នពាក់ព័ន្ធ ពិសេសក្រសួងយុត្តិធម៌គួរបង្កើតច្បាប់ និងលិខិតបទដ្ឋានគតិយុត្តបន្ថែមឱ្យបានកាន់តែច្រើន។ ជាការពិតណាស់ នាពេលបច្ចុប្បន្នលិខិតបទដ្ឋានគតិយុត្តចម្បងដែលមានចែងខ្លឹមសារពាក់ព័ន្ធនឹងនីតិវិធី និងដំណើរការនៃនីតិវិធីនៃការចាត់ចែងរក្សាការពារ នីតិវិធីនៃការចាត់ចែងជាបណ្ដោះអាសន្នចំពោះអចលនវត្ថុ គឺមានតែក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាដែលត្រូវបានរដ្ឋសភាអនុម័តកាលពីថ្ងៃទី ២៦ ខែឧសភា ឆ្នាំ២០០៦ ប៉ុណ្ណោះ។ ចំណែកឯកសារជំនួយរួមមានត្រឹមសេចក្ដីពន្យល់ក្រមនីតិវិធី សេចក្ដីកំណត់ចំពោះមាត្រានីមួយៗនៃក្រមនីតិវិធី និងលិខិតបទដ្ឋានគតិយុត្តមួយចំនួន ដូចជាប្រកាសអន្តរក្រសួងស្ដីពី ការចុះបញ្ជីអចលនវត្ថុទាក់ទងនឹងក្រមនីតិវិធីរដ្ឋប្បវេណីជាដើមប៉ុណ្ណោះ។ ការបង្កើតលិខិតបទដ្ឋានគតិយុត្តសំខាន់ៗមួយចំនួន ដូចជាច្បាប់ស្ដីពីលក្ខន្តិកៈអាជ្ញាសាលា ប្រកាសអន្តរក្រសួងរវាងក្រសួងយុត្តិធម៌ និងក្រសួងដែនដី នគរូបនីយកម្ម និងសំណង់ និងលិខិតបទដ្ឋានគតិយុត្តនានាដែលពាក់ព័ន្ធ ប្រាកដណាស់នឹងចូលរួមជុំរុញឱ្យដំណើរការនីតិវិធីបានកាន់តែប្រសើរ រលូន និងយុត្តិធម៌ជាក់ជាមិនខាន។

**សំណូមពរទី២៖** សំណូមពរឱ្យមានការបង្កើតច្បាប់ ឬលិខិតបទដ្ឋានគតិយុត្តដែលមានកំណត់តម្លៃប្រាក់ប្រដាប់ក្ដីឱ្យជាក់លាក់សមស្របតាមស្ដង់ដារ មានទំហំមួយសមល្មមដែលភាគីមកពឹងពាក់តុលាការអាចទទួលយកបាន។ ស្របនឹងគ្នានេះ ការកំណត់នូវរយៈពេលច្បាស់លាស់សមរម្យសម្រាប់ឱ្យ មន្ត្រី និងអាជ្ញាធរមានសមត្ថកិច្ចអនុវត្តនូវភារកិច្ចរបស់ខ្លួន ក៏ជាកត្តាមួយចាំបាច់គួរពិចារណាដើម្បីឱ្យដំណើរការនីតិវិធីប្រព្រឹត្តទៅដោយរលូន និងរហ័ស ចៀសវាងការពន្យារនីតិវិធីដោយប្រការណាមួយជាហេតុអាចនាំឱ្យមានការកកស្ទះសំណុំរឿងនៅតាមសាលាដំបូងរាជធានីខេត្តជាយថាហេតុ។

**សំណូមពរទី៣៖** ចំពោះវិស័យតុលាការ គួរពិចាណាក្នុងការបង្កើតឱ្យមានចៅក្រមជំនាញទទួលបន្ទុកជំនុំជម្រះតាមប្រភេទរឿងក្តី រួមមានដូចជាចៅក្រមទទួលបន្ទុកផ្នែករដប្បវេណី ព្រហ្មទណ្ឌ ឬផ្នែកពាណិជ្ជកម្ម ដោយឡែកៗពីគ្នា។ ការធ្វើបែបនេះចូលរួមលើកស្ទួយការវិនិច្ឆ័យក្តីឱ្យប្រព្រឹត្តទៅដោយមានសង្គតិភាព មានភាពយុត្តិធម៌ មានតម្លាភាព ស្របតាមជំនាញប្រាកដមែន។ បន្ថែមពីលើនេះទៅទៀត ដោយសារតែវិវាទរដ្ឋប្បវេណីកើតមានជារៀងរាល់ថ្ងៃនៅក្នុងសង្គម ដូចទៅនឹងរឿងព្រហ្មទណ្ឌដែរ នោះការពិចារណាបង្កើតជាកញ្ចប់ថវិកាបង្កើតជាក្រុមមេធាវីស្ម័គ្រចិត្តសម្រាប់ការពារក្តី ឬផ្តល់ការប្រឹក្សាច្បាប់ផ្នែករដ្ឋប្បវេណី ស្រដៀងទៅនឹងក្រុមមេធាវីស្ម័គ្រចិត្តរបស់រាជរដ្ឋាភិបាលដែលមានតួនាទីការពារក្តី ស្វែងរកយុត្តិធម៌ជូនភាគីក្នុងសំណុំរឿងព្រហ្មទណ្ឌ ក៏ជាចំណែកដែលអាចជុំរុញឱ្យវិស័យយុត្តិធម៌នៅព្រះរាជាណាចក្រកម្ពុជាកាន់តែប្រសើរ និងមានតម្លាភាពជាងមុនផងដែរ។

# ឯកសារយោង

## ប្រភពច្បាប់ និងបទដ្ឋានគតិយុត្ត


១. ក្រមរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧។

២. ក្រមនីតិវិធីរដ្ឋប្បវេណីព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៦។

៣. ប្រកាសអន្តរក្រសួង រវាងក្រសួងដែនដី នគរូបនីយកម្ម និង សំណង់ និងក្រសួងយុត្តិធម៌ ស្តីពី ការចុះបញ្ជីអចលនវត្ថុទាក់ទងនឹងក្រមនីតិវិធីរដ្ឋប្បវេណី លេខ៥៩ ប្រក.ដ.ន.ស/១១ ចុះថ្ងៃទី ០៣ ខែឧសភា ឆ្នាំ ២០១១។

៤. សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ២០០៧។

៥. ក្រុមការងារក្រុមការងារជប៉ុនទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា, ឆ្នាំ ២០០៩, សេចក្តីពន្យល់អំពីចំណុចសំខាន់ៗនៃក្រមនីតិវិធីរដ្ឋប្បវេណី ភាគ ១៖ នីតិវិធីចេញសាលក្រម។

៦. ក្រុមការងារក្រុមការងារជប៉ុនទទួលបន្ទុកធ្វើសេចក្តីព្រាងក្រមនីតិវិធីរដ្ឋប្បវេណីកម្ពុជា, ឆ្នាំ ២០០៩, សេចក្តីពន្យល់អំពីក្រមនីតិវិធីរដ្ឋប្បវេណី ភាគ ២៖ ការអនុវត្តដោយបង្ខំ និងការចាត់ចែងរក្សាការពារ។


## ប្រភពស្នាដៃសៀវភៅ


១. សៀវភៅ នីតិវិធីរដ្ឋប្បវេណី ដោយសាស្ត្រាចារ្យ ហ៊ី សោភា ឆ្នាំ ២០១៦។

២. សៀវភៅ នីតិវិធីរដ្ឋប្បវេណី ដោយសាស្ត្រ ហេង បូរ៉ា ឆ្នាំ ២០២៣ - ២០២៤។

៣. ក្រុមការងារគ្រូបង្គោលអនាគត នៃសាលាភូមិន្ទចៅក្រម នៃរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ, ឆ្នាំ ២០០៧, មេរៀនស្តីពីនីតិវិធីរដ្ឋប្បវេណី។


## ប្រភពផ្សេងៗ


១. កម្មវិធីវចនានុក្រមអេឡិចត្រូនិចរបស់តម្រាច្បាប់ ឆ្នាំ ២០២២។

២. ស្លាយបទបង្ហាញ "ការអនុវត្តដោយបង្ខំ និងការចាត់ចែងរក្សាការពារ" ឧទ្ទេសនាមដោយ សាស្ត្រាចារ្យមេធាវី ហេង បូរ៉ា ឆ្នាំ២០២៣។

៣. ស្លាយបទបង្ហាញ "ការរក្សាការពារក្នុងរឿងក្តីរដ្ឋប្បវេណី ផ្នែកទី៤" ដោយ ជំនាញការនៃគម្រោងអភិវឌ្ឍន៍ប្រព័ន្ធច្បាប់ MAEDA Yuta ថ្ងៃទី ២៥ ខែ មេសា ឆ្នាំ២០១៨។

៤. កិច្ចពិភាក្សាស្តីពី«ដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្នចំពោះវត្ថុដែលជាកម្មវត្ថុនៃវិវាទ» រៀបចំដោយគណៈមេធាវី និងវិភាគទានច្បាប់។

**ប្រភពគេហទំព័រ**

១. គេហទំព័រផ្លូវការរបស់ ក្រសួងយុត្តិធម៌ https://www.moj.gov.kh/ ចូលមើលថ្ងៃទី០៨ ខែកក្កដា ឆ្នាំ ២០២៤។

២. គេហទំព័រផ្លូវការរបស់ ក្រសួងព័ត៌មាន https://www.information.gov.kh/articles/117209 ចូលមើលថ្ងៃទី ១០ ខែកក្កដា ឆ្នាំ ២០២៤។

# ឧបសម្ព័ន្ធ

# បញ្ជីឧបសម្ព័ន្ធ

| | |
|---|---|
| **ឧបសម្ព័ន្ធទី១** | ពាក្យសុំឱ្យចេញដីកាសម្រេចរក្សាការពារ (ហាមឃាត់ការចាត់ចែង) |
| **ឧបសម្ព័ន្ធទី២** | ឧបសម្ព័ន្ធនៃបញ្ជីភាគី និងឧបសម្ព័ន្ធនៃបញ្ជីអចលនវត្ថុ |
| **ឧបសម្ព័ន្ធទី៣** | របាយការណ៍សង្ខេបស្តីពីការវាយតម្លៃអចលនវត្ថុ |
| **ឧបសម្ព័ន្ធទី៤** | ដីកាសម្រេចបង្គាប់ឱ្យដាក់ប្រាតិភោគ |
| **ឧបសម្ព័ន្ធទី៥** | ដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្ន |
| **ឧបសម្ព័ន្ធទី៦** | ពាក្យសុំឱ្យអនុវត្តរក្សាការពារ |
| **ឧបសម្ព័ន្ធទី៧** | លិខិតផ្ទុកផ្តាក់ឱ្យចុះបញ្ជីអំពីការចាត់ចែងជាបណ្តោះអាសន្នដែលហាមឃាត់ការចាត់ចែងអចលនវត្ថុ |
| **ឧបសម្ព័ន្ធទី៨** | លិខិតផ្ទុកផ្តាក់ឱ្យលុបការចុះបញ្ជីអំពីការចាត់ចែងជាបណ្តោះអាសន្ន ដែលហាមឃាត់ការចាត់ចែងអចលនវត្ថុ |
| **ឧបសម្ព័ន្ធទី៩** | ឯកសារចម្លងនៃសេចក្តីបញ្ជាក់ចុះបញ្ជីអំពីការចាត់ចែងជាបណ្តោះអាសន្ន |
| **ឧបសម្ព័ន្ធទី១០** | ពាក្យសុំឱ្យចេញដីកាសម្រេចរក្សាការពារ(ហាមឃាត់ការផ្ទេរការកាន់កាប់) |
| **ឧបសម្ព័ន្ធទី១១** | ឧបសម្ព័ន្ធនៃបញ្ជីភាគី និងឧបសម្ព័ន្ធនៃបញ្ជីអចលនវត្ថុ |
| **ឧបសម្ព័ន្ធទី១២** | របាយការណ៍សង្ខេបស្តីពីការវាយតម្លៃអចលនវត្ថុ |
| **ឧបសម្ព័ន្ធទី១៣** | ដីកាសម្រេចបង្គាប់ឱ្យដាក់ប្រាតិភោគ |
| **ឧបសម្ព័ន្ធទី១៤** | ដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្ន |
| **ឧបសម្ព័ន្ធទី១៥** | ពាក្យសុំឱ្យអនុវត្តរក្សាការពារ |
| **ឧបសម្ព័ន្ធទី១៦** | កំណត់ហេតុអនុវត្ត ដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្នដែលហាមឃាត់ការផ្ទេរការកាន់កាប់ |
| **ឧបសម្ព័ន្ធទី១៧** | ពាក្យសុំតវ៉ាចំពោះការរក្សាការពារ |
| **ឧបសម្ព័ន្ធទី១៨** | ដីកាសម្រេចអំពីពាក្យសុំតវ៉ាចំពោះដីកាសម្រេចរក្សាការពារ |
| **ឧបសម្ព័ន្ធទី១៩** | ពាក្យសុំលុបចោលដីកាសម្រេចរក្សាការពារ |

| | |
|---|---|
| **ឧបសម្ព័ន្ធទី២០** | ដីកាសម្រេចអំពីពាក្យលុបចោលដីកាសម្រេចរក្សាការពារ |
| **ឧបសម្ព័ន្ធទី២១** | ពាក្យសុំលុបចោលការចាត់ចែងការអនុវត្តរក្សាការពារ |

# ឧបសម្ព័ន្ធទី១៧

# ពាក្យសុំតវ៉ា

# ចំពោះការរក្សាការពារ

**ឧបសម្ព័ន្ធទី១៧**

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

## ទម្រង់គំរូ[7]

## ពាក្យសុំតវ៉ាចំពោះការរក្សាការពារ[8]

ខ្ញុំ T ជាមេធាវីនៃក្រុមមេធាវី....................មានអាសយដ្ឋាននៅអគារ......... ជាន់ទី..... បន្ទប់...... ផ្លូវលេខ..........សង្កាត់..................ខណ្ឌ...............រាជធានីភ្នំពេញ ដែលមានទូរស័ព្ទលេខ...............។

## សូមគោរពជូន

## ឯកឧត្តមប្រធានសាលាដំបូងរាជធានីភ្នំពេញ

**កម្មវត្ថុ៖** សំណើសុំតវ៉ានឹងដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្នលេខ ២១ «ខ» ដ.រ ចុះថ្ងៃទី២០ ខែមេសា ឆ្នាំ២០២១ របស់សាលាដំបូងរាជធានីភ្នំពេញ។

**យោង ៖** សំណុំរឿងរក្សាការពារលេខ ១០ ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០២១

### ក. គោលបំណងនៃការតវ៉ា

១. លុបចោលដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្នលេខ ២១ «ខ» ដ.រ ចុះថ្ងៃទី២០ ខែមេសា ឆ្នាំ២០២១ របស់សាលាដំបូងរាជធានីភ្នំពេញ។

២. ប្រាក់ប្រដាប់ក្ដីជាបន្ទុករបស់ម្ចាស់បំណុល។

៣. ដីកាសម្រេចនេះមានអានុភាពអនុវត្តភ្លាម។

### ខ. មូលហេតុនៃស្នើសុំលុបចោល

① នត្ថិភាពនៃសិទ្ធិ ឬទំនាក់ទំនងគតិយុត្តដែលត្រូវរក្សាការពារ ៖........................................
..................................................................................................................................។

② នត្ថិភាពនៃភាពចាំបាច់ដែលត្រូវរក្សាការពារ ៖.............................................................
..................................................................................................................................។

③ សិទ្ធិលើបំណុលរលត់ដោយការសង ឬការលើកលែង (អង្គហេតុតវ៉ា) ៖ (ប្រសិនបើមាន)
..................................................................................................................................
..................................................................................................................................។

[7] ទម្រង់គំរូនេះ តាក់តែងក្រៅផ្លូវការ ក្នុងគោលបំណងឱ្យសិក្ខាកាមបានស្វែងយល់អំពីរបៀបសរសេរពាក្យសុំតវ៉ាចំពោះការរក្សាការពារដែលដីកាសម្រេចដើមជាដីកាសម្រេចរក្សាការពារប្រភេទទី៣ (ដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្នដោយកំណត់ឋានៈជាបណ្ដោះអាសន្ន)។

[8] មាត្រា ៥៣៤ មាត្រា ៥៥៤ និងមាត្រា ៥៥ ៦នៃក្រមនីតិវិធីរដ្ឋប្បវេណី។


© រក្សាសិទ្ធិគ្រប់យ៉ាងដោយវិភាគទានច្បាប់

ហេតុនេះ សិទ្ធិលើបំណុលរបស់ម្ចាស់បំណុលបានរលត់ដោយការសង ឬគ្មានភាពចាំបាច់ដែលត្រូវរក្សាការពារ។[៩]

**គ. មូលហេតុនៃការស្នើសុំឱ្យមានអានុភាពអនុវត្តភ្លាមៗ**

① អត្ថិភាពនៃមូលហេតុគតិយុត្តច្បាស់លាស់នៃការលុបចោល ៖..........................................
..............................................................................................................................។

② អត្ថិភាពនៃភស្តុតាងច្បាស់លាស់គាំទ្រមូលហេតុនៃការលុបចោល ៖...............................
..............................................................................................................................។

③ ការខូចខាតរបស់កូនបំណុលនឹងមិនអាចធ្វើបដិទានបាន ៖...........................................
..............................................................................................................................។

**ឃ. ភស្តុតាង**

១. លិខិត....................។ (ភស្តុតាង Y1)

២. រូបថតសន្លឹក................។ (ភស្តុតាង Y2)

៣. ខ្សែអាត់វីដេអូ.............។ (ភស្តុតាង Y3)

**ង. ឯកសារភ្ជាប់**

១. លិខិតតំណាងដោយអាណត្តិ «ច្បាប់ដើម»

២. លិខិតថតចម្លងនៃភស្តុតាងនីមួយៗខាងលើចំនួន ០២ (ពីរ) ច្បាប់

សេចក្ដីដូចមានកំណត់ សូម **ឯកឧត្តមប្រធាន** មេត្តាអនុញ្ញាត ដោយក្ដីអនុគ្រោះ។

សូម **ឯកឧត្តមប្រធាន** ទទួលនូវសេចក្ដីគោរពដ៏ជ្រាលជ្រៅអំពីខ្ញុំ។

រាជធានីភ្នំពេញ ថ្ងៃទី១១ ខែឧសភា ឆ្នាំ២០២១

**អ្នកតំណាងដោយអាណត្តិ**

[៩] ការបញ្ជាក់អំពីលក្ខណៈគតិយុត្តនៃការទាមទារឱ្យបានច្បាស់លាស់ ដើម្បីកំណត់អំពីគោលបំណងនៃពាក្យសុំរបស់កូនបំណុល ថាកូនបំណុលទាមទារឱ្យលុបចោលដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន ឬដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្ន ផ្អែកលើមូលហេតុអ្វី ដើម្បីឱ្យតុលាការមានភាពងាយស្រួលក្នុងកំណត់អំពីខ្លឹមសារនៃដីកាសម្រេចអំពីពាក្យសុំតវ៉ាចំពោះដីកាសម្រេចរក្សាការពារ។

# ឧបសម្ព័ន្ធ
# បញ្ជីតាគី

**ម្ចាស់បំណុល៖**

ឈ្មោះ **A** អាសយដ្ឋាន..............................................................................................។

**អ្នកតំណាងដោយអាណត្តិរបស់ម្ចាស់បំណុល៖**

មេធាវី **P** ជាមេធាវីនៃក្រុមមេធាវី....................មានអាសយដ្ឋាននៅអគារ......... ជាន់ទី...........បន្ទប់...... ផ្លូវលេខ.............សង្កាត់................ខណ្ឌ..............រាជធានីភ្នំពេញ ដែលមានទូរស័ព្ទលេខ................។

**ទីកន្លែងបញ្ជូន៖** ការិយាល័យមេធាវី...................................................................................។

**កូនបំណុល៖**

ឈ្មោះ **B** អាសយដ្ឋាន..............................................................................................។

**អ្នកតំណាងដោយអាណត្តិរបស់ម្ចាស់បំណុល៖**

មេធាវី **T** ជាមេធាវីនៃក្រុមមេធាវី....................មានអាសយដ្ឋាននៅអគារ......... ជាន់ទី...........បន្ទប់..... ផ្លូវលេខ.............សង្កាត់................ខណ្ឌ..............រាជធានីភ្នំពេញ ដែលមានទូរស័ព្ទលេខ................។

**ទីកន្លែងបញ្ជូន៖** ការិយាល័យមេធាវី...................................................................................។


© រក្សាសិទ្ធិគ្រប់យ៉ាងដោយភាគទានច្បាប់

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

⑤

សាលាដំបូងរាជធានីភ្នំពេញ

សំណុំរឿងក្សាការពារលេខ ១០

ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០២១

## ទម្រង់គំរូ[10]

## កំណត់ហេតុសួរកូនបំណុល និងម្ចាស់បំណុល

(មាត្រា ៥៥២ នៃក្រមនីតិវិធីរដ្ឋប្បវេណី)

ម៉ោងប្រាំបួនព្រឹក ថ្ងៃទីដប់ប្រាំបី ខែឧសភា ឆ្នាំពីរពាន់ម្ភៃមួយ នៅសាលាដំបូងរាជធានីភ្នំពេញ

**ចៅក្រម** ៖ លោក J ចៅក្រមនៃសាលាដំបូងរាជធានីភ្នំពេញ

**ក្រឡាបញ្ជី** ៖ លោក C ក្រឡាបញ្ជីនៃសាលាដំបូងរាជធានីភ្នំពេញ

**ម្ចាស់បំណុល** ៖ ឈ្មោះ A អាសយដ្ឋាន..........................................................................។

**អ្នកតំណាងដោយអាណត្តិ៖** ឈ្មោះ P ជាមេធាវីនៃក្រុមមេធាវី.................. មានអាសយដ្ឋាននៅអគារ..........ជាន់ទី..........បន្ទប់.......ផ្លូវលេខ........សង្កាត់..................ខណ្ឌ......................រាជធានីភ្នំពេញ ដែលមានលេខទូរស័ព្ទ..............................។

**កូនបំណុល** ៖ ឈ្មោះ B អាសយដ្ឋាន..........................................................................។

**អ្នកតំណាងដោយអាណត្តិ៖** ឈ្មោះ T ជាមេធាវីនៃក្រុមមេធាវី.................. មានអាសយដ្ឋាននៅអគារ..........ជាន់ទី..........បន្ទប់.......ផ្លូវលេខ........សង្កាត់..................ខណ្ឌ......................រាជធានីភ្នំពេញ ដែលមានលេខទូរស័ព្ទ..............................។

**ខ្លឹមសារនៃដីកាសម្រេចដែលអ្នកដាក់ពាក្យសុំទាមទារឱ្យតុលាការចេញ**

១. លុបចោលដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្នលេខ ២១ «ខ» ដ.រ ចុះថ្ងៃទី២០ ខែមេសា ឆ្នាំ២០២១ របស់សាលាដំបូងរាជធានីភ្នំពេញ។

២. ប្រាក់ប្រដាប់ក្ដីជាបន្ទុករបស់ម្ចាស់បំណុល។

៣. ដីកាសម្រេចនេះមានអានុភាពអនុវត្តភ្លាម។

**ខ្លឹមសារនៃការសួរ**

**១.** មូលហេតុអ្វីកូនបំណុល B ស្នើសុំលុបចោលដីកាសម្រេចដើមរបស់ A?

....................................................................................................................................

**២.** មូលហេតុអ្វីកូនបំណុល B ស្នើសុំឱ្យដីកាសម្រេចនេះមានអានុភាពអនុវត្តភ្លាមៗ?

[10] ទម្រង់គំរូនេះ គាត់តែងក្រៅផ្លូវការ ក្នុងគោលបំណងឱ្យសិក្ខាកាមបានស្វែងយល់អំពី ខ្លឹមសារនៃការធ្វើកំណត់ហេតុសួរកូនបំណុល និងម្ចាស់បំណុលដែលជាកិច្ចនីតិវិធីត្រូវបំពេញដោយតុលាការ មុនពេលចេញដីកាសម្រេចអំពីពាក្យសុំតវ៉ាចំពោះដីកាសម្រេចរក្សាការពារ។


© រក្សាសិទ្ធិគ្រប់យ៉ាងដោយភោគទានច្បាប់

..............................................................................................................................................

៣. តើកូនបំណុល **B** មានភស្តុតាងថ្មីអ្វីបញ្ជាក់ជូនតុលាការដើម្បីគាំទ្រការស្នើសុំខាងលើ ?

..............................................................................................................................................

៤. តើម្ចាស់បំណុល **A** យល់យ៉ាងណាចំពោះការស្នើសុំ និងការអះអាងខាងលើរបស់ **B** ?

..............................................................................................................................................

៥. តើម្ចាស់បំណុល **A** មានអ្វីបញ្ជាក់បន្ថែម ឬភស្តុតាងអ្វីថ្មីត្រូវបញ្ជាក់ឬទេ ?

..............................................................................................................................................

បញ្ឈប់កំណត់ហេតុនេះ នៅម៉ោងដប់មួយ នាថ្ងៃខែឆ្នាំដដែល ដោយបានអានឱ្យគូភាគីស្តាប់ និងគូភាគីបានឆ្លើយថា ត្រឹមត្រូវហើយ ហើយបានចុះហត្ថលេខា ឬផ្តិតស្នាមម្រាមដៃលើកំណត់ហេតុនេះ ផងដែរ។

**កូនបំណុល** **អ្នកតំណាងដោយអាណត្តិ** ( **កូនបំណុល** )

**ម្ចាស់បំណុល** **អ្នកតំណាងដោយអាណត្តិ** ( **ម្ចាស់បំណុល** )

**ក្រឡាបញ្ជី** **ចៅក្រម**

# ឧបសម្ព័ន្ធទី១៨
# ដីកាសម្រេចអំពី
# ពាក្យសុំតវ៉ាចំពោះ
# ដីកាសម្រេចរក្សាការពារ

**ឧបសម្ព័ន្ធទី១៨**



សាលាដំបូងរាជធានីភ្នំពេញ

សំណុំរឿងរក្សាការពារលេខ ១០
ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០២១
ដីកាសម្រេចលេខ ២៣ «ខ» ដ.រ
ចុះថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០២១

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ទម្រង់គំរូ**[11]

**ដីកាសម្រេចអំពីពាក្យសុំតវ៉ាចំពោះដីកាសម្រេចរក្សាការពារ**[12]

**យើង J ចៅក្រមនៃសាលាដំបូងរាជធានីភ្នំពេញ**

- បានឃើញមាត្រា ៥៥០ មាត្រា ៥៥២ និងមាត្រា ៥៥៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី
- បានឃើញពាក្យសុំតវ៉ាចំពោះដីកាសម្រេចរក្សាការពារ ចុះថ្ងៃទី១១.០៥.២០២១

**ម្ចាស់បំណុល៖** ឈ្មោះ A អាសយដ្ឋាន..........................................................................។

**អ្នកតំណាងដោយអាណត្តិ៖** ឈ្មោះ P ជាមេធាវីនៃក្រុមមេធាវី.................. មានអាសយដ្ឋាននៅអគារ..........ជាន់ទី.........បន្ទប់.......ផ្លូវលេខ........សង្កាត់.................ខណ្ឌ.....................រាជធានីភ្នំពេញ ដែលមានលេខទូរស័ព្ទ.............................។

**កូនបំណុល៖** ឈ្មោះ B អាសយដ្ឋាន..........................................................................។

**អ្នកតំណាងដោយអាណត្តិ៖** ឈ្មោះ T ជាមេធាវីនៃក្រុមមេធាវី.................. មានអាសយដ្ឋាននៅអគារ..........ជាន់ទី.........បន្ទប់.......ផ្លូវលេខ........សង្កាត់.................ខណ្ឌ.....................រាជធានីភ្នំពេញ ដែលមានលេខទូរស័ព្ទ.............................។

**ក.ដីកាសម្រេចចាត់ចែងជាបណ្ដោះអាសន្ន** លេខ២១ «ខ» ដ.រ ចុះថ្ងៃទី២០ ខែមេសា ឆ្នាំ២០២១ របស់សាលាដំបូងរាជធានីភ្នំពេញ

១. កំណត់ថាម្ចាស់បំណុលមានសិទ្ធិទាមទារប្រាក់ពីកូនបំណុលជាបណ្ដោះអាសន្ន។

២. បង្គាប់ឱ្យកូនបំណុលបង់ប្រាក់ជាបណ្ដោះអាសន្នចំនួន $ 400 (បួនរយ) ដុល្លារអាមេរិក ត្រឹមថ្ងៃទី០៥ ជារៀងរាល់ខែ គិតចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០២១ រហូតដល់គ្រប់ចំនួន $ 8,000 (ប្រាំបីពាន់) ដុល្លារអាមេរិក ទៅឱ្យម្ចាស់បំណុល។

៣. ប្រាក់ប្រដាប់ក្ដីជាបន្ទុករបស់កូនបំណុល។

[11] ទម្រង់គំរូនេះ គាក់តែងក្រៅផ្លូវការ ក្នុងគោលបំណងឱ្យសិក្ខាកាមបានស្វែងយល់អំពីខ្លឹមសារនៃដីកាសម្រេចអំពីពាក្យសុំតវ៉ាចំពោះដីកាសម្រេចរក្សាការពារ ទាក់ទងនឹងចំណុចនៃសេចក្ដីសម្រេចបញ្ចប់។

[12] ទម្រង់នៃដីកាសម្រេចនេះមានលក្ខណៈជាឧបាស្រ័យ បើឧបាស្រ័យទាក់ទងនឹងដីកាសម្រេចរក្សាការពារប្រភេទទី១ និងទី២ ត្រូវប្រើលំនាំតាមដីកាសម្រេចរក្សាការពារប្រភេទទី១ និងទី២ បើទាក់ទងនឹងដីកាសម្រេចរក្សាការពារប្រភេទទី៣ ត្រូវប្រើលំនាំដីកាសម្រេចរក្សាការពារប្រភេទទី៣ ផ្អែកតាមមាត្រា ៥៣៩ មាត្រា ២១៦ មាត្រា ១៨៩ នៃក្រមនីតិវិធីរដ្ឋប្បវេណី។


© រក្សាសិទ្ធិគ្រប់យ៉ាងដោយភាគទានច្បាប់

**ខ.ការសង្ខេបអំពីរឿងក្តី**

នៅក្នុងរឿងក្តីនេះ ម្ចាស់បំណុលទាមទារឱ្យកូនបំណុលបង់ប្រាក់ជាបណ្តោះអាសន្នចំនួន **$ 400** (បួនរយ) ដុល្លារអាមេរិក ត្រឹមថ្ងៃទី០៥ ជារៀងរាល់ខែ គិតចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០២១ រហូតដល់គ្រប់ចំនួន **$8,000** (ប្រាំបីពាន់) ដុល្លារអាមេរិក ឱ្យម្ចាស់បំណុល ហៅកាត់ថា «ការបង់ប្រាក់ជាបណ្តោះអាសន្ននៃរឿងក្តីនេះ» ដោយមូលហេតុការរំលោយកិច្ចសន្យាការងាររបស់កូនបំណុលបំពានសិទ្ធិរបស់ម្ចាស់បំណុល។

**គ.ចំណុចវិវាទ**

១.តើម្ចាស់បំណុលបានលួចប្រាក់ និងកែបំបាត់ប្រាក់កូនបំណុល?

២.តើម្ចាស់បំណុលមានភាពចាំបាច់ ដែលត្រូវឱ្យកូនបំណុលធ្វើការបង់ប្រាក់ជាបណ្តោះអាសន្ននៃរឿងក្តីនេះឬទេ?

**ឃ.គោលបំណងនៃការតវ៉ា**

១. លុបចោលដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្នលេខ ២១ «ខ» ដ.រ ចុះថ្ងៃទី២០ ខែមេសា ឆ្នាំ២០២១ របស់សាលាដំបូងរាជធានីភ្នំពេញ។

២. ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ម្ចាស់បំណុល។

៣. ដីកាសម្រេចនេះមានអានុភាពអនុវត្តភ្លាម។

**ង.កំណត់ហេតុសួរកូនបំណុល និងម្ចាស់បំណុល** ចុះថ្ងៃទី១៨-០៥-២០២១

**១.** មូលហេតុអ្វីកូនបំណុល **B** ស្នើសុំលុបចោលដីកាសម្រេចដើមរបស់ **A**?

.......................................................................................................................................

.......................................................................................................................................

**២.** មូលហេតុអ្វីកូនបំណុល **B** ស្នើសុំឱ្យដីកាសម្រេចនេះមានអានុភាពអនុវត្តភ្លាមៗ?

.......................................................................................................................................

.......................................................................................................................................

**៣.** តើកូនបំណុល **B** មានភស្តុតាងថ្មីអ្វីបញ្ជាក់ជូនតុលាការដើម្បីគាំទ្រការស្នើសុំខាងលើ?

.......................................................................................................................................

.......................................................................................................................................

**៤.** តើម្ចាស់បំណុល **A** យល់យ៉ាងណាចំពោះការស្នើសុំ និងការអះអាងខាងលើរបស់ **B**?

.......................................................................................................................................

**៥.** តើម្ចាស់បំណុល **A** មានអ្វីបញ្ជាក់បន្ថែម ឬភស្តុតាងអ្វីថ្មីត្រូវបញ្ជាក់ឬទេ?

.......................................................................................................................................

## សំអាងហេតុ

ផ្អែកតាមភស្តុតាង $Y_1$ តុលាការមិនអាចទទួលស្គាល់ថា ម្ចាស់បំណុលបានគៃបំបាត់ប្រាក់ក្រុមហ៊ុនកូនបំណុលនោះទេ។

ផ្អែកតាមភស្តុតាង $Y_2$ តុលាការមិនអាចទទួលស្គាល់ការអះអាងរបស់កូនបំណុល ដែលបានលើកឡើងថា ម្ចាស់បំណុលបានទទួលប្រាក់ចំនួន........... (............) ដុល្លារអាមេរិក ដោយចាត់ទុកជាប្រាក់បញ្ចប់វិវាទរវាងម្ចាស់បំណុល និងកូនបំណុលនោះទេ។

ផ្អែកតាមភស្តុតាង $Y_3$ តុលាការមិនអាចទទួលស្គាល់ថា កូនបំណុលនឹងក្ស័យធន បើបន្តអត្ថិភាពនៃការអនុវត្តរក្សាការពារ ហើយមូលហេតុនៃការស្នើសុំលុបចោលដីកាសម្រេចដើមរបស់កូនបំណុលមានភាពមិនត្រឹមត្រូវតាមច្បាប់ ផ្អែកតាមមាត្រា .......នៃក្រមរដ្ឋប្បវេណី និងគ្មានភស្តុតាងបញ្ជាក់អង្គហេតុជាមូលហេតុនៃការលុបចោលនេះឡើយ។

នៅក្នុងរឿងក្តីនេះ ដោយសារកូនបំណុលចាញ់ក្តីទាំងស្រុង ហេតុនេះ បន្ទុកនៃប្រាក់ប្រដាប់ក្តីជារបស់កូនបំណុល (មាត្រា ៦៤ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។

## សេចក្តីសម្រេចបញ្ចប់

១. ទទួលស្គាល់ដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្នលេខ២១ «ខ» ដ.រ ចុះថ្ងៃទី២០ ខែមេសា ឆ្នាំ២០២១ របស់សាលាដំបូងរាជធានីភ្នំពេញ។

២. ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់កូនបំណុល។

ដីកាសម្រេចនេះ អាចប្តឹងជំទាស់បានតាមមាត្រា ៥៦១ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

រាជធានីភ្នំពេញ ថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០២១

**ចៅក្រម**


© រក្សាសិទ្ធិគ្រប់យ៉ាងដោយវិកាគទានច្បាប់

# ឧបសម្ព័ន្ធទី១៩
# ពាក្យសុំលុបចោល
# ដីកាសម្រេចរក្សាការពារ

**ឧបសម្ព័ន្ធទី១៩**



# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

①

## ទម្រង់គំរូ[7]

## ពាក្យសុំលុបចោលដីកាសម្រេចរក្សាការពារ[8]

ខ្ញុំ T ជាមេធាវីនៃក្រុមមេធាវី....................មានអាសយដ្ឋាននៅអគារ......... ជាន់ទី..... បន្ទប់...... ផ្លូវលេខ..........សង្កាត់..................ខណ្ឌ...............រាជធានីភ្នំពេញ ដែលមានទូរស័ព្ទលេខ................។

## សូមគោរពជូន

## ឯកឧត្តមប្រធានសាលាដំបូងរាជធានីភ្នំពេញ

**កម្មវត្ថុ**៖សំណើសុំលុបចោលដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នលេខ ២១ «ខ» ដ.រ ចុះថ្ងៃទី០៩ ខែមីនា ឆ្នាំ២០២០ របស់សាលាដំបូងរាជធានីភ្នំពេញ។

**យោង** ៖សំណុំរឿងរក្សាការពារលេខ ១០ ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០២០

**ក. គោលបំណងនៃការទាមទារ**

១. លុបចោលដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នលេខ២១ «ខ» ដ.រ ចុះថ្ងៃទី០៩ ខែមីនា ឆ្នាំ២០២០ របស់សាលាដំបូងរាជធានីភ្នំពេញ។

២. ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់កូនបំណុល។

៣. ដីកាសម្រេចនេះមានអានុភាពអនុវត្តភ្លាម។

**ខ. មូលហេតុនៃការស្នើសុំលុបចោល**

① ម្ចាស់បំណុលមិនដាក់បណ្តឹងអង្គសេចក្តី ៖.......................................................................
..........................................................................................................................ឬ

② ការផ្លាស់ប្តូរស្ថានភាព ៖...........................................................................................
..........................................................................................................................ឬ

③ ស្ថានភាពពិសេស ៖..................................................................................................
..........................................................................................................................។

[7] ទម្រង់គំរូនេះ តាក់តែងក្រៅផ្លូវការ ក្នុងគោលបំណងឱ្យសិក្ខាកាមបានស្វែងយល់អំពីរបៀបសរសេរពាក្យសុំទាមទារឱ្យលុបចោលដីកាសម្រេចរក្សាការពារ។

[8] មាត្រា ៥៣៤ មាត្រា ៥៥៤ និងមាត្រា ៥៥៦នៃក្រមនីតិវិធីរដ្ឋប្បវេណី។

ហេតុនេះ គ្មានភាពចាំបាច់ក្នុងការការពារសិទ្ធិលើបំណុលរបស់ម្ចាស់បំណុលនោះទេ ដោយសារ ម្ចាស់បំណុលមិនដាក់បណ្តឹងអង្គសេចក្តី ឬដោយម្ចាស់បំណុលបានចាញ់បណ្តឹងអង្គសេចក្តី ឬដោយសារ កូនបំណុលបានបង់ប្រាក់ឱ្យម្ចាស់បំណុលតាមខ្លឹមសារនៃការបង្គាប់ឱ្យបង់ប្រាក់ជាបណ្តោះអាសន្ន។[9]

**គ. មូលហេតុនៃការស្នើសុំឱ្យមានអានុភាពអនុវត្តភ្លាមៗ** (ករណីស្ថានភាពផ្លាស់ប្តូរ ឬពិសេស)

① អត្ថិភាពនៃមូលហេតុគតិយុត្តច្បាស់លាស់នៃការលុបចោល ៖.......................................
.................................................................................................................................។

② អត្ថិភាពនៃភស្តុតាងច្បាស់លាស់គាំទ្រមូលហេតុនៃការលុបចោល ៖...............................
.................................................................................................................................។

③ ការខូចខាតរបស់កូនបំណុលនឹងមិនអាចធ្វើបដិទានបាន ៖............................................
.................................................................................................................................។

**ឃ. ភស្តុតាង**

១. លិខិត....................។ (ភស្តុតាង $Y_1$)

២. រូបថតសន្លឹក................។ (ភស្តុតាង $Y_2$)

៣. ខ្សែអាត់វីដេអូ.............។ (ភស្តុតាង $Y_3$)

**ង. ឯកសារភ្ជាប់**

១. លិខិតតំណាងដោយអាណត្តិ «ច្បាប់ដើម»

២. លិខិតថតចម្លងនៃភស្តុតាងនីមួយៗខាងលើចំនួន ០២ (ពីរ) ច្បាប់

សេចក្តីដូចមានកំណត់ សូម **ឯកឧត្តមប្រធាន** មេត្តាអនុញ្ញាត ដោយក្តីអនុគ្រោះ។

សូម **ឯកឧត្តមប្រធាន** ទទួលនូវសេចក្តីគោរពដ៏ជ្រាលជ្រៅអំពីខ្ញុំ។

រាជធានីភ្នំពេញ ថ្ងៃទី០២ ខែឧសភា ឆ្នាំ២០២២

**អ្នកតំណាងដោយអាណត្តិ**

[9] ការបញ្ជាក់អំពីលក្ខណៈគតិយុត្តនៃការទាមទារឱ្យបានច្បាស់លាស់ ដើម្បីអាចកំណត់អំពីគោលបំណងនៃពាក្យសុំរបស់ម្ចាស់បំណុល ថាតើទាមទារចាត់ចែងជាបណ្តោះអាសន្នដោយកំណត់ឋានៈជាបណ្តោះអាសន្ន ផ្អែកលើសិទ្ធិ ឬទំនាក់ទំនងគតិយុត្តណាមួយនៃបណ្តឹងអង្គសេចក្តី ដើម្បីឱ្យតុលាការមានភាពងាយស្រួលក្នុងការកំណត់អំពីខ្លឹមសារនៃការចាត់ចែងបណ្តោះអាសន្ន។


© រក្សាសិទ្ធិគ្រប់យ៉ាងដោយភាគទានច្បាប់

# ឧបសម្ព័ន្ធ
# បញ្ជីតាគី

**ម្ចាស់បំណុល៖**

ឈ្មោះ A អាសយដ្ឋាន..........................................................................................................។

**អ្នកតំណាងដោយអាណត្តិរបស់ម្ចាស់បំណុល៖**

មេធាវី P ជាមេធាវីនៃក្រុមមេធាវី....................មានអាសយដ្ឋាននៅអគារ......... ជាន់ទី...........បន្ទប់...... ផ្លូវលេខ.............សង្កាត់................ខណ្ឌ..............រាជធានីភ្នំពេញ ដែលមានទូរស័ព្ទលេខ................។

**ទីកន្លែងបញ្ជូន៖** ការិយាល័យមេធាវី..........................................................................................។

**កូនបំណុល៖**

ឈ្មោះ B អាសយដ្ឋាន..........................................................................................................។

**អ្នកតំណាងដោយអាណត្តិរបស់ម្ចាស់បំណុល៖**

មេធាវី T ជាមេធាវីនៃក្រុមមេធាវី....................មានអាសយដ្ឋាននៅអគារ......... ជាន់ទី...........បន្ទប់..... ផ្លូវលេខ.............សង្កាត់................ខណ្ឌ..............រាជធានីភ្នំពេញ ដែលមានទូរស័ព្ទលេខ................។

**ទីកន្លែងបញ្ជូន៖** ការិយាល័យមេធាវី..........................................................................................។


© រក្សាសិទ្ធិគ្រប់យ៉ាងដោយវិភាគទានច្បាប់

ព្រះរាជាណាចក្រកម្ពុជា ②

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

សំណុំរឿងក្សាការពារលេខ ១០
ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០២០

## ទម្រង់គំរូ[10]

## កំណត់ហេតុសួរកូនបំណុល និងម្ចាស់បំណុល

(មាត្រា ៥៥២ នៃក្រមនីតិវិធីរដ្ឋប្បវេណី)

ម៉ោងប្រាំបួនព្រឹក ថ្ងៃទីម្ភៃមួយ ខែឧសភា ឆ្នាំពីរពាន់ម្ភៃពីរ នៅសាលាដំបូងរាជធានីភ្នំពេញ

**ចៅក្រម** ៖ លោក **J** ចៅក្រមនៃសាលាដំបូងរាជធានីភ្នំពេញ

**ក្រឡាបញ្ជី** ៖ លោក **C** ក្រឡាបញ្ជីនៃសាលាដំបូងរាជធានីភ្នំពេញ

**ម្ចាស់បំណុល** ៖ ឈ្មោះ **A** អាសយដ្ឋាន.......................................................................។

**អ្នកតំណាងដោយអាណត្តិ៖** ឈ្មោះ **P** ជាមេធាវីនៃក្រុមមេធាវី................. មានអាសយដ្ឋាន នៅអគារ..........ជាន់ទី.........បន្ទប់.......ផ្លូវលេខ........សង្កាត់.................ខណ្ឌ....................រាជធានីភ្នំពេញ ដែលមានលេខទូរស័ព្ទ.............................។

**កូនបំណុល** ៖ ឈ្មោះ **B** អាសយដ្ឋាន.......................................................................។

**អ្នកតំណាងដោយអាណត្តិ៖** ឈ្មោះ **T** ជាមេធាវីនៃក្រុមមេធាវី................. មានអាសយដ្ឋាន នៅអគារ..........ជាន់ទី.........បន្ទប់.......ផ្លូវលេខ........សង្កាត់.................ខណ្ឌ....................រាជធានីភ្នំពេញ ដែលមានលេខទូរស័ព្ទ.............................។

**ខ្លឹមសារនៃដីកាសម្រេចដែលអ្នកដាក់ពាក្យសុំទាមទារឱ្យតុលាការចេញ**

១. លុបចោលដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នលេខ២១ «ខ» ដ.រ ចុះថ្ងៃទី០៩ ខែមីនា ឆ្នាំ២០២០ របស់សាលាដំបូងរាជធានីភ្នំពេញ។

២. ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់កូនបំណុល។

៣. ដីកាសម្រេចនេះមានអានុភាពអនុវត្តភ្លាម។

**ខ្លឹមសារនៃការសួរ**

**១.** មូលហេតុអ្វីកូនបំណុល **B** ស្នើសុំលុបចោលដីកាសម្រេចដើមរបស់ **A**?

[10] ទម្រង់គំរូនេះ គាត់តែងក្រៅផ្លូវការ ក្នុងគោលបំណងឱ្យសិក្ខាកាមបានស្វែងយល់អំពី ខ្លឹមសារនៃការធ្វើកំណត់ហេតុសួរកូនបំណុល ដែលជាកិច្ចនីតិវិធីត្រូវបំពេញដោយតុលាការ មុនពេលចេញដីកាសម្រេចចាត់ចែងជាបណ្តោះអាសន្ន។


© រក្សាសិទ្ធិគ្រប់យ៉ាងដោយវិភាគទានច្បាប់

..................................................................................................................................

២. មូលហេតុអ្វីកូនបំណុល **B** ស្នើសុំឱ្យដីកាសម្រេចនេះមានអានុភាពអនុវត្តភ្លាមៗ?

..................................................................................................................................

៣. តើកូនបំណុល **B** មានភស្តុតាងអ្វីបញ្ជាក់ជូនតុលាការដើម្បីគាំទ្រការស្នើសុំខាងលើ?

..................................................................................................................................

៤. តើម្ចាស់បំណុល **A** យល់យ៉ាងណាចំពោះការស្នើសុំ និងការអះអាងខាងលើរបស់ **B**?

..................................................................................................................................

៥. តើម្ចាស់បំណុល **A** មានអ្វីបញ្ជាក់បន្ថែម ឬភស្តុតាងអ្វីថ្មីត្រូវបញ្ជាក់ឬទេ?

..................................................................................................................................

បញ្ឍប់កំណត់ហេតុនេះ នៅម៉ោងដប់មួយ នាថ្ងៃខែឆ្នាំដដែល ដោយបានអានឱ្យគូភាគីស្តាប់ និងគូភាគីបានឆ្លើយថា ត្រឹមត្រូវហើយ ហើយបានចុះហត្ថលេខា ឬផ្តិតស្នាមមេដៃលើកំណត់ហេតុនេះ ផងដែរ។

**កូនបំណុល** **អ្នកតំណាងដោយអាណត្តិ** (**កូនបំណុល**)

**ម្ចាស់បំណុល** **អ្នកតំណាងដោយអាណត្តិ** (**ម្ចាស់បំណុល**)

**ក្រឡាបញ្ជី** **ចៅក្រម**


© រក្សាសិទ្ធិគ្រប់យ៉ាងដោយភោគទានច្បាប់

# ឧបសម្ព័ន្ធទី២០
# ដីកាសម្រេចអំពី
# ពាក្យលុបចោល
# ដីកាសម្រេចរក្សាការពារ

**ឧបសម្ព័ន្ធទី២១**



③

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

សំណុំរឿងរក្សាការពារលេខ ១០
ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០២០
ដីកាសម្រេចលេខ ២៧ «ខ» ដ.រ
ចុះថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០២២

**ទម្រង់គំរូ**[11]

**ដីកាសម្រេចអំពីពាក្យសុំលុបចោល**

**ដីកាសម្រេចរក្សាការពារ**[12]

**យើង J ចៅក្រមនៃសាលាដំបូងរាជធានីភ្នំពេញ**

- បានឃើញមាត្រា ៥៥៨ មាត្រា ៥៦០ និងមាត្រា ៥៥៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី
- បានឃើញពាក្យសុំលុបចោលដីកាសម្រេចរក្សាការពារ ចុះថ្ងៃទី០២.០៥.២០២២

**ម្ចាស់បំណុល៖** ឈ្មោះ A អាសយដ្ឋាន...........................................................................។

**អ្នកតំណាងដោយអាណត្តិ៖** ឈ្មោះ P ជាមេធាវីនៃក្រុមមេធាវី.................. មានអាសយដ្ឋាន នៅអគារ..........ជាន់ទី.........បន្ទប់.......ផ្លូវលេខ........សង្កាត់..................ខណ្ឌ.....................រាជធានីភ្នំពេញ ដែលមានលេខទូរស័ព្ទ..............................។

**កូនបំណុល៖** ឈ្មោះ B អាសយដ្ឋាន...........................................................................។

**អ្នកតំណាងដោយអាណត្តិ៖** ឈ្មោះ T ជាមេធាវីនៃក្រុមមេធាវី.................. មានអាសយដ្ឋាន នៅអគារ..........ជាន់ទី.........បន្ទប់.......ផ្លូវលេខ........សង្កាត់..................ខណ្ឌ.....................រាជធានីភ្នំពេញ ដែលមានលេខទូរស័ព្ទ..............................។

**ក.សេចក្តីសម្រេចបញ្ចប់នៃដីកាសម្រេចរឹបអូសជាបណ្តោះអាសន្ន** លេខ២១«ខ» ដ.រ ចុះថ្ងៃទី០៩ ខែមីនា ឆ្នាំ ២០២០ របស់សាលាដំបូងរាជធានីភ្នំពេញ

១. រឹបអូសជាបណ្តោះអាសន្ននូវអចលនវត្ថុដែលជាកម្មសិទ្ធិរបស់កូនបំណុល ដូចមានកំណត់នៅក្នុងបញ្ជីឧបសម្ព័ន្ធនៃវត្ថុ។

២. កូនបំណុលត្រូវផ្ញើប្រាក់រំដោះចំនួន ១២០.០០០ (មួយសែនពីរម៉ឺន) ដុល្លារអាមេរិក ដើម្បី

---

[11] ទម្រង់គំរូនេះ តាក់តែងក្រៅផ្លូវការ ក្នុងគោលបំណងឱ្យសិក្ខាកាមបានស្វែងយល់អំពីខ្លឹមសារនៃដីកាសម្រេចអំពីពាក្យសុំតវ៉ាចំពោះដីកាសម្រេចរក្សាការពារ ទាក់ទងនឹងចំណុចនៃសេចក្តីសម្រេចបញ្ចប់។

[12] ទម្រង់នៃដីកាសម្រេចនេះមានលក្ខណៈជាឧបាស្រ័យ បើឧបាស្រ័យទាក់ទងនឹងដីកាសម្រេចរក្សាការពារប្រភេទទី១ និងទី២ ត្រូវប្រើលំនាំតាមដីកាសម្រេចរក្សាការពារប្រភេទទី១ និងទី២ បើទាក់ទងនឹងដីកាសម្រេចរក្សាការពារប្រភេទទី៣ ត្រូវប្រើលំនាំដីកាសម្រេចរក្សាការពារប្រភេទទី៣ ផ្អែកតាមមាត្រា ៥៣៩ មាត្រា ២១៦ មាត្រា ១៨៩ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

ទទួលបានការលុបចោលការអនុវត្តការរឹបអូសជាបណ្តោះអាសន្ន។

៣. ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់កូនបំណុល។

**ខ.គោលបំណងនៃការទាមទាររបស់កូនបំណុល**

១. លុបចោលដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នលេខ២១ «ខ» ដ.វ ចុះថ្ងៃទី០៩ ខែមីនា ឆ្នាំ២០២០ របស់សាលាដំបូងរាជធានីភ្នំពេញ។

២. ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់កូនបំណុល។

៣. ដីកាសម្រេចនេះមានអានុភាពអនុវត្តភ្លាម។

**គ.កំណត់ហេតុសួរកូនបំណុល និងម្ចាស់បំណុល** ចុះថ្ងៃទី២១-០៥-២០២២

**១.** មូលហេតុអ្វីកូនបំណុល **B** ស្នើសុំលុបចោលដីកាសម្រេចដើមរបស់ **A**?

....................................................................................................................................

**២.** មូលហេតុអ្វីកូនបំណុល **B** ស្នើសុំឱ្យដីកាសម្រេចនេះមានអានុភាពអនុវត្តភ្លាមៗ?

....................................................................................................................................

**៣.** តើកូនបំណុល **B** មានភស្តុតាងអ្វីបញ្ជាក់ជូនតុលាការដើម្បីគាំទ្រការស្នើសុំខាងលើ?

....................................................................................................................................

**៤.** តើម្ចាស់បំណុល **A** យល់យ៉ាងណាចំពោះការស្នើសុំ និងការអះអាងខាងលើរបស់ **B**?

....................................................................................................................................

**៥.** តើម្ចាស់បំណុល **A** មានអ្វីបញ្ជាក់បន្ថែម ឬភស្តុតាងអ្វីថ្មីត្រូវបញ្ជាក់ឬទេ?

....................................................................................................................................

## សំអាងហេតុ

ផ្អែកតាមភស្តុតាង $Y_1$ តុលាការទទួលស្គាល់ថា ម្ចាស់បំណុលបានចាញ់បណ្តឹងអង្គសេចក្តី ដោយសាលាឧទ្ធរណ៍ភ្នំពេញបានចេញសាលដីកាដែលមានខ្លឹមសារលុបចោលសាលក្រមរបស់សាលាដំបូង និងប្រាក់ប្រដាក់ក្តីជាបន្ទុករបស់ម្ចាស់បំណុល (ដើមចោទ)។

ផ្អែកតាមភស្តុតាង $Y_2$ តុលាការទទួលស្គាល់ថា សាលដីការបស់សាលាឧទ្ធរណ៍ខាងលើបានចូលជាស្ថាពរ។

ផ្អែកតាមភស្តុតាង $Y_3$ តុលាការទទួលស្គាល់ថា កូនបំណុលនឹងក្ស័យធន បើបន្តអត្ថិភាពនៃការអនុវត្តរក្សាការពារ ហើយមូលហេតុនៃការស្នើសុំលុបចោលដីកាសម្រេចដើមរបស់កូនបំណុលមានភាព

ត្រឹមត្រូវតាមច្បាប់ ផ្អែកតាមមាត្រា ៥៥៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី និងមានកស្តុតាងបញ្ជាក់អង្គហេតុជាមូលហេតុនៃការលុបចោលនេះច្បាស់លាស់។

នៅក្នុងរឿងក្តីនេះ ដោយសារម្ចាស់បំណុលចាញ់ក្តីទាំងស្រុង ហេតុនេះ បន្ទុកនៃប្រាក់ប្រដាប់ក្តីជារបស់ម្ចាស់បំណុល (មាត្រា ៦៤ កថាខណ្ឌទី១ នៃក្រមនីតិវិធីរដ្ឋប្បវេណី)។

## សេចក្តីសម្រេចបញ្ចប់

១. លុបចោលដីកាសម្រេចរឹបអូសជាបណ្តោះអាសន្នលេខ ២១ «ខ» ដ.រ ចុះថ្ងៃទី០៩ ខែមីនា ឆ្នាំ២០២០ របស់សាលាដំបូងរាជធានីភ្នំពេញ។

២. ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់កូនបំណុល។

៣. ដីកាសម្រេចនេះមានអានុភាពអនុវត្តភ្លាម។

ដីកាសម្រេចនេះ អាចប្តឹងជំទាស់បានតាមមាត្រា ៥៦១ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

រាជធានីភ្នំពេញ ថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០២២

**ចៅក្រម**

# ឧបសម្ព័ន្ធទី២២
# ពាក្យសុំលុបចោលការចាត់ចែង
# ការអនុវត្តក្បួនការពារ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

④

## ទម្រង់គំរូ[13]

## ពាក្យសុំលុបចោលការចាត់ចែងការអនុវត្តរក្សាការពារ[14]

ខ្ញុំ T ជាមេធាវីនៃក្រុមមេធាវី...................មានអាសយដ្ឋាននៅអគារ......... ជាន់ទី..... បន្ទប់...... ផ្លូវលេខ..........សង្កាត់..................ខណ្ឌ...............រាជធានីភ្នំពេញ ដែលមានទូរស័ព្ទលេខ................។

**សូមគោរពជូន**

**ឯកឧត្តមប្រធានសាលាដំបូងរាជធានីភ្នំពេញ**

**កម្មវត្ថុ៖** សំណើសុំលុបចោលការចាត់ចែងការអនុវត្តការរឹបអូសជាបណ្ដោះអាសន្ន

**យោង** ៖សំណុំរឿងអនុវត្តរក្សាការពារលេខ ១២ ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ២០២០

**ក. គោលបំណងនៃការទាមទារ**

លុបចោលការចាត់ចែងការអនុវត្តការរឹបអូសជាបណ្ដោះអាសន្ន ដែលបានធ្វើឡើងផ្អែកតាមដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្នលេខ២១ «ខ» ដ.រ ចុះថ្ងៃទី០៩ ខែមីនា ឆ្នាំ២០២០ របស់សាលាដំបូងរាជធានីភ្នំពេញ។

**ខ. មូលហេតុនៃស្នើសុំលុបចោល**

កូនបំណុលបានដាក់ប្រាក់រំដោះគ្រប់ចំនួន ដូចមានកំណត់នៅក្នុងដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្នលេខ ២១ «ខ» ដ.រ ចុះថ្ងៃទី០៩ ខែមីនា ឆ្នាំ២០២០។

**គ. សេចក្ដីបញ្ជាក់ជំរុំ**

១. លិខិតផ្ញើប្រាក់។ (ភស្តុតាង $Y_1$)

២. ដីកាសម្រេចរឹបអូសជាបណ្ដោះអាសន្ន។ (ភស្តុតាង $Y_2$)

**ឃ. ឯកសារភ្ជាប់**

១. លិខិតតំណាងដោយអាណត្តិ «ច្បាប់ដើម»

២. លិខិតថតចម្លងនៃភស្តុតាងនីមួយៗខាងលើចំនួន ០២ (ពីរ) ច្បាប់

សេចក្ដីដូចមានកំណត់ សូម **ឯកឧត្តមប្រធាន** មេត្តាអនុញ្ញាត ដោយក្ដីអនុគ្រោះ។

សូម **ឯកឧត្តមប្រធាន** ទទួលនូវសេចក្ដីគោរពដ៏ជ្រាលជ្រៅអំពីខ្ញុំ។

រាជធានីភ្នំពេញ ថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០២០

**អ្នកតំណាងដោយអាណត្តិ**

[13] ទម្រង់គំរូនេះ គាត់តែងក្រៅផ្លូវការក្នុងគោលបំណង ឱ្យសិក្ខាកាមបានស្វែងយល់អំពីរបៀបសរសេរពាក្យសុំទាមទារឱ្យលុបចោលការចាត់ចែងការអនុវត្តការរឹបអូសជាបណ្ដោះអាសន្ន ផ្អែកតាមមាត្រា ៣៧០ និងមាត្រា ៥៦៤ នៃក្រមនីតិវិធីរដ្ឋប្បវេណី ហើយប្រការ ១៧ កថាខណ្ឌទី៣ ចំណុច «ខ» នៃប្រកាសអន្តរក្រសួងស្ដីពីការចុះបញ្ជីអចលនវត្ថុទាក់ទងនឹងក្រមនីតិវិធីរដ្ឋប្បវេណី។

[14] មាត្រា ៥៣៤ មាត្រា ៥៥៤ និងមាត្រា ៥៥៦នៃក្រមនីតិវិធីរដ្ឋប្បវេណី។


© រក្សាសិទ្ធិគ្រប់យ៉ាងដោយភាគទានច្បាប់

# ឧបសម្ព័ន្ធ
# បញ្ជីតាគី

**ម្ចាស់បំណុល៖**

ឈ្មោះ **A** អាសយដ្ឋាន..........................................................................................................។

**អ្នកតំណាងដោយអាណត្តិរបស់ម្ចាស់បំណុល៖**

មេធាវី **P** ជាមេធាវីនៃក្រុមមេធាវី....................មានអាសយដ្ឋាននៅអគារ......... ជាន់ទី...........បន្ទប់...... ផ្លូវលេខ.............សង្កាត់................ខណ្ឌ..............រាជធានីភ្នំពេញ ដែលមានទូរស័ព្ទលេខ................។

**ទីកន្លែងបញ្ជូន៖** ការិយាល័យមេធាវី.............................................................................................។

**កូនបំណុល៖**

ឈ្មោះ **B** អាសយដ្ឋាន..........................................................................................................។

**អ្នកតំណាងដោយអាណត្តិរបស់ម្ចាស់បំណុល៖**

មេធាវី **T** ជាមេធាវីនៃក្រុមមេធាវី....................មានអាសយដ្ឋាននៅអគារ......... ជាន់ទី...........បន្ទប់..... ផ្លូវលេខ.............សង្កាត់................ខណ្ឌ..............រាជធានីភ្នំពេញ ដែលមានទូរស័ព្ទលេខ................។

**ទីកន្លែងបញ្ជូន៖** ការិយាល័យមេធាវី.............................................................................................។


© រក្សាសិទ្ធិគ្រប់យ៉ាងដោយវិភាគទានច្បាប់